- គ្មាននរណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ ដែលមិនបានអមដំណើរដោយឪពុកម្តាយ គួរត្រូវបានអនុញ្ញាតអោយចូលសណ្ឋាគារ ឬកន្លែងកំសាន្តសំរាប់មនុស្សពេញវ័យដ៏ទៃឡើយ ។
- សណ្ឋាគារ និងក្រុមហ៊ុនទេសចរណ៍រាប់បញ្ចូលទាំងសមាគម គួរតែចុះហត្ថលេខាលើក្រមសីលធម៌ និងធ្វើការងារបង្កើនការយល់ដឹងអំពីក្រមនោះ និងអនុវត្តនូវគោលការណ៍ ៦ ដែលត្រូវបានគូសបញ្ជាក់នៅក្នុងនោះ ។



ស.ធ.ក.ក.
COSECAM

COSECAM

# ទេសចរណ៍ផ្លូវភេទកុមារ



## ការសិក្សាលើវិសាលភាពនៃបញ្ហា និងការវាយតម្លៃលើការផ្តួចផ្តើមប្រឆាំងនឹងទេសចរណ៍ផ្លូវភេទដែលមានស្រាប់

Caroline Putman-Cramer

កិច្ចសហប្រតិបត្តិការរវាងគំរោងផ្នែកការពារនៅសកលវិទ្យាល័យ Johns Hopkins

និងសម្ព័ន្ធអង្គការដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅប្រទេសកម្ពុជា

# មាតិកា

ទំព័រ


សេចក្តីសង្ខេបប្រតិបត្តិ ..................... ១

សេចក្តីផ្តើម ..................... ៥

វិធីសាស្ត្រ..................... ៩

របកគំហើញ ..................... ១៣

១. វិស័យទេសចរណ៍នៅកម្ពុជា ..................... ១៣

១.១ ហេតុអ្វីបានជាប្រទេសកម្ពុជាជាទិសដៅទេសចរណ៍ផ្លូវភេទលើកុមារ ? .....................១៤

២. វិស័យទេសចរណ៍ផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា .....................១៦

២.១ សញ្ជាតិ .....................២១

២.២ ទិសដៅ/កន្លែងដែលត្រូវធ្វើដំណើរឆ្ពោះទៅកាន់ .....................២៤

៣. ទំនាក់ទំនងរវាងភ្ញៀវទេសចរណ៍ផ្លូវភេទលើកុមារហើយនឹងកុមារ . ៣២

៣.១ អ្នកបើកបរតាក់ស៊ី និង អ្នករត់ម៉ូតូឌុប .....................៣៤

៣.២ បុគ្គលិកសណ្ឋាគារ និង ផ្ទះសំណាក់..................... ៣៨

៣.៣ អ្នកនាំភ្ញៀវទេសចរណ៍ និង ក្រុមហ៊ុនទេសចរណ៍ .....................៤១

៣.៤ បញ្ហាដ៏ទៃ .....................៤៣

៤. ទំនាក់ទំនងរវាងទេសចរណ៍ផ្លូវភេទលើកុមារ និងការជួញដូរកុមារ ... ៤៥


- ធ្វើឱ្យកិច្ចសហប្រតិបត្តិការប្រសើរឡើងជាមួយស្ថានទូតដែលពាក់ព័ន្ធ និងការអនុវត្តន៍ច្បាប់ប្រព្រឹត្តបទល្មើសក្រៅទឹកដី ។
- ការលើកកំពស់កិច្ចសហប្រតិបត្តិការជាមួយអជ្ញាធរមូលដ្ឋានតាមខេត្ត គឺត្រូវការចាំបាច់ណាស់ ។
- ការស្រាវជ្រាវអំពីហេតុការណ៍ ដែលបានកើតមានឡើងទាក់ទងនឹងការរំលោភផ្លូវភេទលើកុមារ ដោយប្រជាជនកម្ពុជាគួរត្រូវបានគេធ្វើឡើងបន្ថែមទៀត ។

## ១០.៣ ផ្នែកឯកជន

- ផ្នែកឯកជនគួរតែចូលរួមបន្ថែមទៀតក្នុងការទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ ។
- ទោះបីជាយើងអនុញ្ញាតអោយភ្ញៀវរក្សាសិទ្ធិឯកជនរបស់ពួកគេក៏ដោយ ម្ចាស់ជំនួញគួរតែបង្កើននូវការត្រួតពិនិត្យភ្ញៀវ ដូច្នេះពួកមិនអាចលាក់បាំងការប្រព្រឹត្តិដែលគួរឱ្យសង្ស័យនោះបានទេ ។
- ការរាយការណ៍គឺសំខាន់ណាស់ ។ ម្ចាស់ជំនួញគួរតែរាយការណ៍រាល់ហេតុការណ៍ដែលកើតឡើង ទោះបីជាវាទំនងជាមិនសំខាន់យ៉ាងណាក៏ដោយ ។
- បុគ្គលិកសណ្ឋាគារ និងក្រុមហ៊ុនទេសចរណ៍គួរតែគោរពបំណងរបស់ភ្ញៀវ ប៉ុន្តែប្រសិនបើបំណងនោះពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទលើកុមារ បុគ្គលិកទាំងនោះមិនត្រូវរំលោភច្បាប់ ដើម្បីបំពេញតាមបំណងនោះទេ ។

- រាជរដ្ឋាភិបាលកម្ពុជា គួរតែធ្វើវិមជ្ឈការពាណិជ្ជកម្មទៅតាមខេត្ត ដើម្បីបង្កើតឱកាសការងារបន្ថែម (នាពេលបច្ចុប្បន្នការងារទាំងអស់នេះមានច្រើនបំផុតនៅក្នុងកណ្តាលក្រុងប៉ុណ្ណោះ)។

### ១០.២ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ

- គំនិតផ្តួចផ្តើមត្រូវការអោយមានការសំរបសំរួលឱ្យកាន់តែប្រសើរឡើង ដើម្បីចៀសវាងចំនុចខ្វះខាត, មិនឱ្យមានការងារជាន់គ្នា, និងដើម្បីធ្វើអោយមានប្រសិទ្ធិភាពខ្លាំងបំផុត ។
- អង្គការក្រៅរដ្ឋាភិបាលគួរតែព្យាយាមធ្វើការយ៉ាងជិតស្និតបន្ថែមទៀតជាមួយផ្នែកឯកជន ។
- ការបង្កើនការយល់ដឹងគួរតែត្រូវបានផ្តោតទិសដៅ ឬធ្វើនៅក្នុងប្រទេសដែលភ្ញៀវទេសចរផ្លូវភេទបានប្រព្រឹត្តដំបូង។
- តែងតែមានទិន្នាការ និងគំរូថ្មីៗក្នុងចំណោមជនល្មើសផ្លូវភេទ ដូច្នេះការសិក្សាមួយដែលមានកំរិតតូច គួរតែត្រូវបានអនុវត្តជាប្រក្រតី ដើម្បីអាចឱ្យគេផ្លាស់ប្តូរវិធីសាស្ត្រស៊ើបអង្កេតឱ្យត្រូវទៅតាមនិន្នាការថ្មីៗទាំងនោះ។
- អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិគួរតែផ្តល់ព័ត៌មានដល់ប្រជាជនកម្ពុជា អំពីសារៈសំខាន់នៃការរាយការណ៍អំពីហេតុការណ៍ដែលកើតមានឡើងទាក់ទងនឹងទេសចរណ៍ផ្លូវភេទលើកុមារ។



៥. ឥទ្ធិពលនៃក្រមសីលធម៌សំរាប់ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងការធ្វើដំណើរ និងទេសចរណ៍ ........ ៤៨
៦. ក្របខ័ណ្ឌនីតិបញ្ញត្តិដែលទាក់ទងទៅនិងទេសចរណ៍ផ្លូវភេទលើកុមារហើយនឹងសកម្មភាពពាក់ព័ន្ធ ........ ៥០
៧. ការអនុវត្តន៍ច្បាប់ និង ដំណើរការកាត់ទោសប្រឆាំងនឹងភ្ញៀវទេសចរណ៍ផ្លូវភេទ ........ ៦០
៧.១ និយាយដោយឡែកពីករណីសហរដ្ឋអាមេរិក ........ ៧៣
៨. គំនិតផ្តួចផ្តើមដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ ........ ៧៩
៨.១ រាជរដ្ឋាភិបាលកម្ពុជា ........ ៨០
៨.២ អង្គការក្រៅរដ្ឋាភិបាល និង អង្គការអន្តរជាតិ ........ ៩១
៨.៣. ផ្នែកឯកជន ........ ១០០
៨.៣.១ សណ្ឋាគារ ........ ១០០
៨.៣.២ ភ្នាក់ងារទេសចរណ៍ ........ ១០៣
៩. សរុបសេចក្តី ........ ១០៥
១០. អនុសាសន៍ ........ ១០៩
១០.១ រាជរដ្ឋាភិបាលកម្ពុជា ........ ១០៩
១០.២ អង្គការក្រៅរដ្ឋាភិបាល និង អង្គការអន្តរជាតិ ........ ១១១
១០.៣ ផ្នែកឯកជន ........ ១១២

# សេចក្តីសង្ខេបប្រតិបត្តិ

ការកើនឡើងនៃចំនួនអ្នកធ្វើដំណើរមកដល់ក្នុងបណ្តាប្រទេសប៉ែកអាស៊ីអាគ្នេយ៍ ហើយជាពិសេសក្នុងប្រទេសកម្ពុជាបានធ្វើឱ្យមានប្រយោជន៍ទាំងសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ព្រមជាមួយគ្នានោះដែរ វាក៏ធ្វើឱ្យមានផលប៉ះពាល់ដ៏ខ្លាំងក្លាចំពោះប្រជាជន, បរិស្ថាន, ហើយនឹងកេរ្តិ៍តំណែលវប្បធម៌របស់ប្រទេសនេះដែរ។ វិស័យទេសចរណ៍ក៏ដូចជា វិស័យកសិកម្ម និងឧស្សាហកម្មវាយនភ័ណ្ឌដែរ គឺវាជាប្រភពប្រាក់ចំណូលដ៏សំខាន់មួយក្នុងចំណោមប្រភពចំណូលសំខាន់ៗនៅក្នុងប្រទេសកម្ពុជា។ តាមពិតទៅវាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ចំពោះរដ្ឋាភិបាលក្នុងការបន្ត និងធ្វើឱ្យប្រសើរឡើងផ្នែកវិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែរដ្ឋាភិបាលត្រូវតែយកចិត្តទុកដាក់ និងទទួលខុសត្រូវដើម្បីព្យាយាមធ្វើឱ្យវិស័យទេសចរណ៍មាននិរន្តភាព។ ជាអកុសលភ្ញៀវទេសចរមួយចំនួនតូច ដែលមកប្រទេសកម្ពុជាក្នុងមួយឆ្នាំៗ (ទោះជាយ៉ាងណាក៏ដោយ វាគឺជាបុគ្គលមួយចំនួនដែលគួរឱ្យកត់សំគាល់) ពួកគេនឹងពាក់ព័ន្ធទៅនឹងសកម្មភាពផ្លូវភេទជាមួយនឹងអនីតិជន ទោះបីជា ពេលដែលពួកគេបានចាកចេញពីផ្ទះរបស់ពួកគេមកដោយបានគិតទុកជាមុន ឬមិនបានគិតទុកជាមុនក៏ដោយ ។

ក្នុងការកត់សំគាល់នៃសញ្ជាតិភាគច្រើននៃជន ដែលបានប្រព្រឹត្តផ្លូវភេទលើកុមារ ហើយនឹងតំបន់ពិសេសមួយចំនួនសំរាប់វិស័យទេសចរណ៍ផ្លូវភេទ យើងអាចលើកឡើងនូវចំណុចសំខាន់ៗ ដែលគួឱ្យចាប់អារម្មណ៍មួយចំនួន។ ខេត្តចំនួន ៥ កំពុងប្រឈមមុខនឹងការរំលោភបំពានបែបនេះខ្លាំងជាងគេគឺ ខេត្តបន្ទាយមាន



- រាជរដ្ឋាភិបាល ត្រូវតែដោះស្រាយនូវសេចក្តីត្រូវការនៃទេសចរណ៍ផ្លូវភេទលើកុមារ ។
- គួរតែធ្វើយ៉ាងណាឱ្យផ្នែកនៃវិស័យឯកជនមានការចូលរួមច្រើនជាងនេះទៀត។ រាជរដ្ឋាភិបាលគួរតែមានបំណងស្វែងរកការលើកទឹកចិត្តចំពោះឧស្សាហកម្មទេសចរណ៍ ដើម្បីអោយពួកគេចូលរួមបន្ថែមទៀត។
- នីតិបញ្ញត្តិបច្ចុប្បន្នត្រូវការអោយមានការប្រសើរឡើង។ ការអនុម័តសេចក្តីព្រៀងច្បាប់ជួញដូរមួយក្នុងចំណោមសេចក្តីព្រៀងច្បាប់ទាំងអស់ដែលថ្មីៗនេះកំពុងត្រូវបានគេពិនិត្យគួរតែជាអទិភាព។ លើសពីនេះទៅទៀតរាជរដ្ឋាភិបាលគួរតែអនុម័តសេចក្តីព្រៀងច្បាប់ទេសចរណ៍។
- ការអនុវត្តន៍ច្បាប់មានភាពប្រសើរឡើងរយៈពេលពីរ-បីឆ្នាំកន្លងទៅនេះ ប៉ុន្តែគេអាចអនុវត្តឱ្យបានកាន់តែប្រសើរឡើងបន្ថែមទៀត។ ចាំបាច់ត្រូវតែអនុវត្តច្បាប់ឱ្យបានតឹងតែងបន្ថែមទៀត។
- មន្ត្រីរាជរដ្ឋាភិបាល ដែលយកអំណាចរបស់ខ្លួនទៅប្រើប្រាស់ខុសត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់។
- រាជរដ្ឋាភិបាលគួរតែព្យាយាមធ្វើឱ្យប្រព័ន្ធយុត្តាធិការមានភាពឯករាជ្យ។ ប្រព័ន្ធយុត្តាធិការ ចាំបាច់ត្រូវតែធ្វើអោយប្រសើរឡើងចំពោះទាំងអំពើពុករលួយទាំងការបកស្រាយច្បាប់/ការអនុវត្តន៍ច្បាប់។

ច្រើនថែមទៀត គួរតែត្រូវបានបង្កើតតាមខេត្តដើម្បីបង្កើតនូវឱកាសការងារបន្ថែមទៀត។

សាធារណៈជនទូទៅជាពិសេសកុមារដែលងាយនឹងរងគ្រោះ, ឪពុកម្តាយ, និងជនទាំងឡាយណាដែលធ្វើការក្នុងឧស្សាហកម្មទេសចរណ៍ - ជាបន្ទាន់ត្រូវតែទទួលបានការអប់រំ ដែលពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទលើកុមារ : ច្បាប់, ផលប៉ះពាល់លើជនរងគ្រោះទាំងរយៈពេលខ្លី និងរយៈពេលវែង, ផ្នែករាងកាយ និងចិត្តសាស្ត្រ ហើយនឹងទោសដែលត្រូវបានកាត់សំរាប់ភ្ញៀវទេសចរផ្លូវភេទ។ កិច្ចខិតខំប្រឹងប្រែងត្រូវតែបានគេសំរបសំរួល និងរាល់ផ្នែកទាំងអស់ត្រូវសហការរួមគ្នាដើម្បីទទួលបាននូវលទ្ធផលដ៏មានប្រសិទ្ធិភាពបំផុត ដែលអាចធ្វើទៅបាន។ គំនិតផ្តួចផ្តើមគួរតែខិតខំបង្កើនការចូលរួមរបស់កុមាររងគ្រោះ ដើម្បីរួមចំណែកជួយលើកកំពស់ការយល់ដឹង និងការពារកុមារដ៏ទៃទៀតកុំអោយធ្លាក់ខ្លួនជាចំណីរបស់ជនល្មើសផ្លូវភេទលើកុមារ។

## ១០. អនុសាសន៍

### ១០.១. រាជរដ្ឋាភិបាលកម្ពុជា

- នៅពេលដែលគំនិតផ្តួចផ្តើមថ្មីត្រូវបានបង្កើតឡើង សន្ទស្សន៍ក៏គួរតែបង្កើតឡើងជាមួយគ្នានោះដែរដើម្បីគេអាចវាស់ស្ទង់ដឹងថា តើគោលនយោបាយទាំងអស់នេះកំពុងមានឥទ្ធិពលវិជ្ជមាន និងមានវិសាលភាពប៉ុណ្ណា។



ជ័យ, កំពង់សោម, បាត់ដំបង, ភ្នំពេញ, និងសៀមរាប។ ក្នុងការសិក្សានេះគឺយើងផ្តោតលើក្រុងភ្នំពេញ, សៀមរាប, និងកំពង់សោម ពីព្រោះតំបន់ទាំងនេះបានទាក់ទាញភ្ញៀវទេសចរណ៍ភាគច្រើន ហើយមួយផ្នែកទៀតដោយសារតែអត្រារាលដាលនៃទេសចរណ៍ផ្លូវភេទលើកុមារហាក់ដូចជាមានការកើនឡើង។ ពាក់ព័ន្ធទៅនឹងសញ្ជាតិជនប្រព្រឹត្តផ្លូវភេទលើកុមារភាគច្រើន គឺជាជនជាតិកម្ពុជា។ សូម្បីតែប្រជាជនកម្ពុជាក៏អាចត្រូវបានចាត់ទុកថា ជាភ្ញៀវទេសចរក្នុងប្រទេសផ្ទាល់របស់ពួកគេដែរ នៅពេលដែលពួកគេធ្វើដំណើរទៅកាន់ខេត្តដ៏ទៃទៀត។ បន្ទាប់មកគឺ ភ្ញៀវទេសចរមកពីបណ្តាប្រទេសអាស៊ី គឺជាភ្ញៀវទេសចរក្នុងតំបន់ដែលជារឿយៗទំនងជាមានការពាក់ព័ន្ធច្រើន បំផុតក្នុងវិស័យទេសចរណ៍ផ្លូវភេទលើកុមារ។ តាមពិតមួយចំនួនតូចនៃភ្ញៀវទេសចរស្បែកស គឺជាអ្នកទេសចរផ្លូវភេទលើកុមារ ប៉ុន្តែដោយសារកិច្ចប្រឹងប្រែង ដើម្បីទប់ស្កាត់វិស័យទេសចរណ៍ផ្លូវភេទលើកុមារ ដែលបានផ្តោតយ៉ាងខ្លាំងលើការរំលោភ ដែលប្រព្រឹត្តដោយពួកបច្ចឹមប្រទេសគឺស្របពេលជាមួយគ្នានោះហើយ ដែលបណ្តាលធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីខាងប្រព័ន្ធសារព័ត៌មាននោះ។ ហេតុផលដែលស្ថិតនៅខាងក្រោយបញ្ហានេះទំនងជាដោយសារតែរដ្ឋាភិបាលបច្ចឹមប្រទេសកំពុងចាត់វិធានការណ៍ ដើម្បីចាប់យកមកកាត់ទោសជនជាតិរបស់ពួកគេ ដែលបានប្រព្រឹត្តរំលោភផ្លូវភេទលើកុមារបរទេស ដូច្នេះហើយពួកបច្ចឹមប្រទេសដែលជាជនប្រព្រឹត្តបទល្មើសត្រូវបានគេដឹងនិងឃើញភ្លាមៗហើយច្រើនជាងគេ។ លើសពីនេះទៅទៀត ជនបរទេសអាចចាកចេញយ៉ាងងាយស្រួលពីប្រទេសដែលការរំលោភបានកើតឡើង ហើយអាច

គេចផុតពីការកាត់ទោស។ បញ្ហានេះវាប្រហែលជាអាចស្ថិតនៅត្រង់ថា យុទ្ធនាការប្រឆាំងទេសចរណ៍ផ្លូវភេទលើកុមារជាច្រើនក្នុងប្រទេសកម្ពុជា គឺបានទទួលមូលនិធិពីរដ្ឋាភិបាលប្រទេសទាំងនេះ។ លើសពីនេះទៅទៀត ក្នុងការប្រៀបធៀបលក្ខណៈខុសគ្នារវាងខាងបូព៌ាប្រទេស និងខាងបច្ចឹមប្រទេសគឺ ពួកបូព៌ាប្រទេសមានការប្រុងប្រយ័ត្ន ឬធ្វើសកម្មភាពស្ងាត់ៗដើម្បីរកមនុស្សដែលពួកគេចង់បាន ចំណែកឯពួកបច្ចឹមប្រទេសវិញគេធ្វើសកម្មភាពដែលអាចឱ្យគេដឹង និងជាញឹកញាប់គេមានអ្នកជួយទាក់ទងឱ្យ។ លើសពីរនេះទៅទៀត ពួកជនស្បែកស គឺងាយស្រួលធ្វើឱ្យគេកត់សំគាល់នៅក្នុងទីក្រុងនៃទ្វីបអាស៊ី ដូច្នេះជាលទ្ធផលគឺ ពួកគេជារឿយៗត្រូវបានគេចាប់ខ្លួន ។

ជនល្មើសមិនយល់ដឹងអំពីការគ្រោះថ្នាក់ដែលត្រូវបានគេចាប់ខ្លួនពិតប្រាកដ ឬការគំរោមកំហែង។ ជនល្មើសតិចតួចណាស់ដែលត្រូវបានគេចាប់ខ្លួន ហើយពួកគេភាគច្រើនមានឱកាសក្នុងការសូកប៉ាន់ ដើម្បីធានាក្នុងការដោះលែងរបស់ពួកគេ។ ទាំងការអនុវត្តន៏ច្បាប់ និងប្រព័ន្ធយុត្តាធិការក្នុងប្រទេសកម្ពុជាត្រូវបានគេដឹងថាមានភាពទន់ខ្សោយ និងធូរលុង។ ទោះបីជាយ៉ាងណាក៏ដោយបញ្ហានេះនឹងមានការផ្លាស់ប្តូរទាំងតថភាព និងការយល់ដឹង។ អំពើពុករលួយនៅតែកើតមានហើយមានឧបសគ្គដ៏ច្រើនកំពុងរារាំងក្នុងកាទប់ស្កាត់ទេសចរណ៏ផ្លូវភេទលើកុមារ។ ទោះបីជាយ៉ាងណាក៏ដោយ វិធានការដែលរាជរដ្ឋាភិបាលកំពុងតែអនុវត្តគឺ អាចបង្ហាញឱ្យឃើញពីការរីកចំរើនជាច្រើន។ រដ្ឋាភិបាលមានសកម្មភាពយ៉ាងខ្លាំងក្នុងការទប់ស្កាត់ទេសចរណ៏ផ្លូវភេទលើកុមារ ឥឡូវនេះរដ្ឋាភិបាលបានពួតដៃគ្នាជាមួយនឹង



ខ្លះជឿនោះទេ។ ប៉ុន្តែវិលត្រឡប់មកនិយាយពីជនបរទេសដែលរំលោភកុមារកម្ពុជាវិញ កិច្ចខិតខំប្រឹងប្រែងប្រហែលជាត្រូវបញ្ជូនទៅកាន់ប្រទេសកំណើតនៃភ្ញៀវទេសចរ។ ជាឧទាហរណ៏ យុទ្ធនាការការការពារគួរតែត្រូវបានធ្វើក្នុងសហរដ្ឋអាមេរិក, ជប៉ុន, ឬកូរ៉េខាងត្បូងដើម្បីដោះស្រាយអំពីតំរូវការនៅទីនោះ។

ដើម្បីឱ្យកុមារចាកចេញពីឧស្សាហកម្មផ្លូវភេទ ហើយដើម្បីអោយរួចផុតពីបញ្ហានេះ រឺក៏មិនឱ្យពួកគេធ្លាក់ខ្លួនក្នុងបញ្ហាបែបនេះតាំងពីដំបូង គឺពួកគេត្រូវការជំរើសប្រាកដប្រជាដែលអាចធ្វើទៅបាន និងអាចសំរេចបំណងបាន ហើយដែលអាចផ្តល់ផលប្រយោជន៏/រកលុយបានដូចគ្នានោះដែរ។ សំរាប់គោលបំណងនេះគឺទាមទាឱ្យមានកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាច្រើន ហើយកម្មវិធីទាំងអស់នេះគឺ គេត្រូវតែធ្វើការស្រាវជ្រាវ និងរៀបចំអោយបានគ្រប់គ្រាន់។ កុមាររងគ្រោះដោយសារការរំលោភបំពានផ្លូវភេទគួរតែត្រូវបានវាយតំលៃដើម្បីកំណត់ឱ្យបាននូវសេចក្តីត្រូវការរបស់គេ, ផលប្រយោជន៏/ចំណាប់អារម្មណ៏, ចំនុចខ្លាំង, និងចំនុចខ្សោយរបស់ពួកគេ។ ក្រោយពីបានដឹងអំពីតំរូវការរបស់ពួកគេ ហើយកម្មវិធីអប់រំ និងបណ្តុះបណ្តាល (ផ្អែកលើអាយុរបស់ពួកគេ) អាចត្រូវបានបង្កើតឡើង និងផ្តល់ឱ្យពួកគេ។ អង្គការក្រៅរដ្ឋាភិបាលគួរតែព្យាយាមបង្កើតការងារបន្ថែមទៀតសំរាប់អ្នកក្រ ដើម្បីអោយឪពុកម្តាយរបស់ពួកគេអាចផ្គត់ផ្គង់ដល់កូនរបស់ពួកគេជាជាងឱ្យកូនរបស់ពួកគេធ្វើការងារ ដើម្បីផ្គត់ផ្គង់គ្រួសារទៅវិញ។ រោងចក្រកាត់ដេរក្នុងទីក្រុងភ្នំពេញ ជួលស្រីវ័យក្មេងជាច្រើនឱ្យធ្វើការអ្នកខ្លះក្នុងចំណោមនោះត្រូវបានគេសង្គ្រោះចេញពីឧស្សាហកម្មផ្លូវភេទ។ រោងចក្រ

ស្វែងរកកុមារដើម្បីរំលោភបំពាន”។[៥៧] ក្រៅពីជនស្បែកសដែលប្រើឧបាយកលដើម្បីធ្វើឱ្យកុមារកម្ពុជាជឿទុកចិត្ត និងអ្នកដែលមកពីទ្វីបអាស៊ីដែលស្វែងរកព្រហ្មចារីយ៍បរិសុទ្ធនោះ-ចរិកលក្ខណៈពិសេសទូទៅទាំងអស់នេះ ជួនកាលគេច្រឡំនឹងបទដ្ឋានបុរសកម្ពុជាក៏ត្រូវបានគេទទួលស្គាល់ថា បានរំលោភបំពានលើកុមារដែរ។ កិច្ចខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើអនីតិជននោះមិនត្រូវបញ្ចប់ជាមួយតែជនបរទេសនោះទេ។ គំនិតផ្តួចផ្តើមត្រូវការផ្តោតទៅលើតំរូវការ ពីព្រោះដ៏រាបណាមានតំរូវការវាក៏នឹងមានការផ្គត់ផ្គង់ដែរ។ ហើយវាទំនងថា សមាមាត្រដ៏ធំនៃតំរូវការកើតឡើងក្នុងប្រទេសកម្ពុជា។ លើសពីនេះទៅទៀត ក្នុងការបង្កើនការយល់ដឹង គឺត្រូវតែគិតពិចារណាយ៉ាងប្រុងប្រយ័ត្នទៅដល់ការប៉ះពាល់វប្បធម៌ ហើយនឹងធ្វើយ៉ាងណាអោយត្រូវទៅនឹងខួរក្បាលប្រជាជនកម្ពុជា។ ប្រសិនបើប្រជាជនកម្ពុជាមួយចំនួនធំជាជនប្រព្រឹត្តដែលពាក់ព័ន្ធនឹងសីលធម៌ផ្លូវភេទជាមួយអនីតិជន យើងត្រូវតែឱ្យពួកគេយល់ដឹងអំពើពេស្យាកម្មលើកុមារ។ មានជំនឿមិនពិតជាច្រើនជុំវិញបញ្ហាក្មេងស្រី និងមូលហេតុនៃបុរសអាស៊ីមួយចំនួនចូលចិត្តស្រីក្មេងៗជាពិសេសស្រីក្រមុំបរិសុទ្ធ។ បុរសអាស៊ីត្រូវការដឹងថា ការរួមភេទជាមួយអនីតិជននឹងមិនធ្វើអោយពួកគេមានសុខភាពល្អជាងមុន ឬមានវ័យក្មេងជាងមុនទេ ស្ត្រីវ័យក្មេងអាចមានគភ៌ និងស្ត្រីវ័យកាន់តែក្មេងគឺ កាន់តែប្រឈមមុខនឹងគ្រោះថ្នាក់នៃបញ្ហាសុខភាព។ ហើយការរួមភេទជាមួយស្ត្រីវ័យក្មេងនឹងមិនអាចព្យាបាលជំងឺអេដស៍ដល់ពួកគេ ដូចដែលអ្នក

[57] Haugen, Gary A. with Hunter, Gregg, *Terrify No More*, International Justice Mission (IJM), 2005; p. 212.



អង្គការក្រៅរដ្ឋាភិបាល (NGOs) ហើយនឹងអង្គការអន្តរជាតិ (IOs)។ រាជរដ្ឋាភិបាលបានសហការជាមួយស្ថានទូតបរទេស ហើយមានគោលបំណងធ្វើឱ្យផ្នែកឯកជនសហការគ្នា ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ ។

រដ្ឋាភិបាលទាំងអស់ កំពុងជំរុញឱ្យមានការកាត់ទោសពីបទអសីលធម៌ផ្នែកផ្លូវភេទលើអនីតិជន ហើយនឹងការកាត់ទោសដែលត្រូវបានគេកំណត់ទោសទាំងនៅក្នុងប្រទេសកម្ពុជាទាំងនៅក្នុងប្រទេសកំណើតរបស់ជនល្មើស ពួកគេនឹងផ្សព្វផ្សាយឱ្យអ្នកដែលអាចនឹងក្លាយជាជនល្មើសបានដឹងថា ទោះជាអំពើទាំងនេះត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសរបស់ខ្លួន ឬនៅបរទេសក៏ដោយពួកគេនឹងមិនមានសុវត្ថិភាពចំពោះការប្រព្រឹត្តបទឧក្រិដ្ឋដ៏សាហាវដោយពុំមានការរំពឹងថា នឹងមានទណ្ឌកម្មនោះទេ។ ប៉ុន្តែចាំបាច់ត្រូវតែជំរុញធ្វើឱ្យការរីកចំរើនទាំងអស់នេះបន្តដំណើរទៅមុខទៀត ហើយមានមេរៀនជាច្រើនថែមទៀតដែលត្រូវរៀនសូត្រ។ ប៉ុន្តែផ្លូវដែលយើងកំពុងតែដើរនោះ គឺឆ្ពោះទៅកាន់ទិសដៅមួយដែលត្រឹមត្រូវ ហើយទោះបីជារាជរដ្ឋាភិបាល និងផ្នែកអង្គការក្រៅរដ្ឋាភិបាលកំពុងប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ យ៉ាងណាក៏ដោយមានកិច្ចការជាច្រើនទៀតដែលនឹងត្រូវធ្វើ ហើយនឹងកិច្ចប្រឹងប្រែងទាំងអស់ត្រូវការឱ្យមានសហប្រតិបត្តិការឱ្យបានប្រសើរជាងមុន។ ជាញឹកញាប់សេចក្តីត្រូវការ/តំរូវការ ត្រូវបានគេមើលរំលង ព្រោះយើងដឹងហើយថា មានតំរូវការទើបមានការផ្គត់ផ្គង់ ដូច្នេះយើងត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើអ្នកដែលពាក់ព័ន្ធពិតប្រាកដក្នុងសកម្មភាពផ្លូវភេទជាមួយនឹងអនីតិជន។ លើសពី

នេះទៅទៀត ចាំបាច់ត្រូវតែបញ្ចូលវិស័យឯកជនទៅក្នុងសកម្មភាពជួយប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារនេះ។ បុគ្គលនៅក្នុងវិស័យឯកជនត្រូវតែមានតួនាទីយ៉ាងសកម្មបន្ថែមទៀតក្នុងការប្រយុទ្ធប្រឆាំងជាជាងធ្វើជាមិនដឹងថា វាជាអំពើខុសឆ្គងនោះ ។

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា (RGC) ថ្មីៗនេះបានផ្តល់សច្ចាបន័លើពិធីសារអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់, ការគាប់សង្កត់, ហើយនឹងដាក់ទណ្ឌកម្មចំពោះការជួញដូរមនុស្ស, ជាពិសេសការជួញដូរស្ត្រី និងកុមារឆ្នាំ ២000 (UN Protocol) បន្ថែមលើកត្តិកាសញ្ញាអង្គការសហប្រជាជាតិប្រឆាំងទៅនឹងបទឧក្រិដ្ឋ ដែលត្រូវបានរៀបចំជាអន្តរកាល។ ពិធីសារអង្គការសហប្រជាជាតិបានគូសបញ្ជាក់នូវទំរង់រូបភាព ៧ចំនុច ដែលមានដូចខាងក្រោមៈ ការជួញដូរក្នុងគោលបំណងកេងប្រវ័ញ្ចលើពេស្យាកម្មរបស់ជនដទៃ, ក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ តាមរូបភាពផ្សេងៗ, ក្នុងគោលបំណងបង្ខំអោយធ្វើការ ឬបំរើសេវាកម្មផ្សេងៗទៀត, ក្នុងគោលបំណងឱ្យធ្វើជាទាសករ ឬការប្រព្រឹត្តិដែលមានរូបភាពរបៀបជាទាសករ, ក្នុងគោលបំណងធ្វើអោយពួកគេធ្លាក់ក្នុងស្ថានភាពដូចជា ទាសករ, និងក្នុងគោលបំណងយកសរីរាង្គណាមួយពីរាងកាយរបស់មនុស្ស (មាត្រា៣)។ ទោះបីមិនមានចែងជាក់លាក់យ៉ាងណាក៏ដោយ ក៏ទេសចរណ៍ផ្លូវភេទលើកុមារអាចរាប់បញ្ចូលបានទៅក្នុង "ទំរង់រូបភាពកេងប្រវ័ញ្ចលើផ្លូវភេទដទៃៗទៀត" ដែរ។



កុមារទេ។ ពួកគេភាគច្រើនបានអះអាងថា រាជរដ្ឋាភិបាលកំពុងសកម្មក្នុងការព្យាយាមលុបបំបាត់ការកេងប្រវ័ញ្ចលើកុមារ ក៏ប៉ុន្តែមិនបានផ្តល់ជាគំរូនៃគំនិតផ្តួចផ្តើម ឬបទបញ្ជាទេ។ រាជរដ្ឋាភិបាលកម្ពុជា និងផ្នែកអង្គការក្រៅរដ្ឋាភិបាលត្រូវការបង្កើនការធ្វើយុទ្ធនាការដើម្បីលើកកំពស់យល់ដឹងស្តី ពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃទេសចរណ៍ផ្លូវភេទលើកុមារ គឺធ្វើក្នុងចំណោមជនដែលទំនាក់ទំនងផ្ទាល់ជាមួយភ្ញៀវទេសចរ និងធ្វើការក្នុងឧស្សាហកម្មទេសចរណ៍ ថែមទាំងដល់សាធារណៈជនទៀតផង។ អ្វីដែលត្រូវការគឺ សុចនាករ/សន្ទស្សន៍ដែលអាចវាស់ស្ទង់ឱ្យដឹងពីទំហំនៃឥទ្ធិពលនៃយុទ្ធនាការដែលបានធ្វើ។ យុទ្ធសាស្រ្តដែលមានស្រាប់ទាំងនោះគឺ ខ្វះសន្ទស្សន៍សំខាន់ៗសំរាប់វាស់ស្ទង់ឱ្យដឹងពីទំហំនៃឥទ្ធិពលរបស់យុទ្ធសាស្រ្តទាំងនោះ។ បើគ្មានសន្ទស្សន៍ទាំងនោះទេ វាមានការលំបាកក្នុងការវាស់ស្ទង់ឱ្យដឹងច្បាស់លាស់ពីប្រសិទ្ធិភាពនៃការខិតខំប្រឹងប្រែង ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារនោះណាស់។

យុទ្ធនាការដែលធ្វើឡើង ដើម្បីដោះស្រាយបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារត្រូវតែចាប់ផ្តើមផ្តោតលើតំរូវការ : អ្នករំលោភផ្លូវភេទលើកុមារ។ "ធ្វើការ...ដើម្បីកាត់ទោសអតិថិជនផ្លូវភេទនៅកន្លែងណាក៏ដោយ ដែលអាចធ្វើទៅបានវានឹងជួយកាត់បន្ថយនូវតំរូវការនោះផងដែរ។ នៅពេលដែលភ្ញៀវទេសចរផ្លូវភេទយល់ឃើញថា ពួកគេមិនអាចសង្ឃឹមថា នឹងបន្តអំពើដ៏ឃោឃៅរបស់ពួកគេបានដោយគ្មានឧបស័គ្គបានទៀតនោះពួកគេនឹងគិតមួយដង ហើយមួយដងទៀតអំពីការធ្វើដំណើរទេសចរណ៍ទៅកាន់ផ្នែកដាច់ស្រយាលនៃពិភពលោកដើម្បី

## ៩. សរុបសេចក្តី

ប្រទេសកម្ពុជាគឺ ជាតំបន់គោលដៅថ្មីមួយសំរាប់ទេសចរណ៍ផ្លូវភេទលើកុមារ ប៉ុន្តែស្ថានភាពនេះអាចរិតតែខ្លាំងឡើងយ៉ាងឆាប់រហ័ស ប្រសិនបើរដ្ឋាភិបាលកម្ពុជា, អង្គការក្រៅរដ្ឋាភិបាល, និងផ្នែកឯកជនមិនបានចាត់វិធានការឱ្យមានប្រសិទ្ធិភាព និងដាក់ចេញដំណោះស្រាយរយៈពេលយូរទេនោះ។ តាមពិតទៅអ្នករាល់គ្នាទទួលផលប៉ះពាល់ដោយសារស្ថានភាពបែបនេះ ដូច្នេះគ្រប់សមាជិកសង្គមទាំងអស់គួរតែចូលរួមប្រឹងប្រែង ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។ ក្រុងភ្នំពេញ, សៀមរាប, និងក្រុងព្រះសីហនុ គឺជាតំបន់ទិសដៅសំខាន់សំរាប់ភ្ញៀវទេសចរដែលធ្វើដំណើរក្នុងប្រទេសកម្ពុជា។ ហើយកន្លែងទាំងអស់នេះ គឺជាកន្លែងដែលភ្ញៀវទេសចរផ្លូវភេទធ្វើដំណើរទៅកាន់។ ជនល្មើសមានភ្ញៀវទេសចរផ្លូវភេទឱកាសនិយមច្រើនជាងជនអនាចារពិត។ ជនប្រព្រឹត្តមកពីកូរ៉េខាងត្បូង, ចិន, ជប៉ុន, និងសហរដ្ឋអាមេរិកជាសំខាន់។ ទោះបីជាយ៉ាងក៏ដោយភ្ញៀវទេសចរផ្លូវភេទត្រូវបានគេដឹងថា មកពីប្រទេសបារាំង, អាឡឺម៉ង់ និងអូស្ត្រាលីផងដែរ។

តាមពិតទៅមានវិធានការ និងយុទ្ធសាស្ត្រមួយចំនួនធំកំពុងអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា, អង្គការក្រៅរដ្ឋាភិបាល, អង្គការអន្តរជាតិ, ព្រមទាំងវិស័យឯកជន (ទោះបីមានវិសាលភាពតិចតួចស្តួចស្តើងយ៉ាងណាក៏ដោយ)។ ជាអកុសលវិធានការទាំងនេះទំនងជាមិនបានទៅដល់សាធារណៈជនទេ។ បុគ្គលិកក្នុងសណ្ឋាគារ និងក្រុមហ៊ុនទេសចរណ៍ ជនទាំងឡាយដែលធ្វើការផ្ទាល់ក្នុងឧស្សាហកម្មទេសចរណ៍ ភាគច្រើនមិនបានដឹងនូវយុទ្ធសាស្ត្រទាំងនេះ ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើ



កត្តិកាសញ្ញា ឆ្នាំ២០០០ ស្តីពីការការពារជនរងគ្រោះដោយសារការជួញដូរ (TVPA) បានគូសបញ្ជាក់នូវបញ្ជីនៃសកម្មភាពសំរាប់ "ក្រុមការងារអន្តរស្ថាប័នដើម្បីតាមដាន និងទប់ស្កាត់ការជួញដូរ" ។ កាតព្វកិច្ចមួយ គឺត្រូវតែត្រួតពិនិត្យនូវសកម្មភាពនៃឧស្សាហកម្មទេសចរណ៍ផ្លូវភេទអន្តរជាតិក្នុងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើមនុស្ស ជាពិសេសលើស្ត្រី និងកុមារ[1] ។

ការជួញដូរមនុស្សមិនមែនជាហេតុការណ៍ថ្មីទេ ទោះបីជាមានវិធីសាស្ត្រនៃការជួញដូរថ្មីៗជាបន្តបន្ទាប់ និងនិន្នាការកើតឡើងយ៉ាងណាក៏ដោយ។ នៅក្នុងការឯកសារនេះ ទេសចរណ៍ផ្លូវភេទលើកុមារ (CST) ត្រូវបានគេចាត់ទុកថា ជាសមាសភាគមួយនៃការជួញដូរ ហើយការជួញដូរនេះគឺ ស្ថិតនៅក្នុងទំរង់មួយដែលគេហៅថា "ការជួញដូរក្នុងបំណងដើម្បីកេងប្រវ័ញ្ចលើផ្លូវភេទ" ។ ប្រទេសថៃ និងប្រទេសហ្វីលីពីន គឺជាប្រទេសដែលស្ថិតនៅក្នុងទិសដៅដ៏សំខាន់នៅក្នុងចំណោមបណ្តាប្រទេសក្នុងទ្វីបអាស៊ីសំរាប់ទេសចរណ៍ផ្លូវភេទអន្តរជាតិ។ ក្នុងមួយឆ្នាំៗ ជនជាតិជប៉ុនប្រហែល ៣០០០០០ នាក់ បានធ្វើដំណើរទៅកាន់ប្រទេសហ្វីលីពីនដើម្បីទេសចរណ៍ផ្លូវភេទ[2] ។ តំបន់ទាំងអស់នេះ ត្រូវបានគេគិតថាជា "ទិសដៅចាស់សព្វថ្ងៃនេះ" ហើយទិសដៅថ្មីមានដូចជា CostaRica, Guatemala,

[1] Article 105 (d) (5).

[2] Dr. Mohamed Mattar, Co-Director, The Protection Project, *Comparative* Analysis of the Elements of Anti-Trafficking Legislation in the Asia-Pacific Region: What Countries in the Region Have to do to Comply with the 2000 UN Protocol to Prevent, Suppress and Punish Trafficking in Persons, Especially Women and Children, The Human Rights Challenge of Globalisation in Asia-Pacific – US: The Trafficking in Persons, Especially Women and Children, Honolulu, Hawaii; November 13-15, 2002.

Northerm Russia, South-South-easternEurope, Cameroon, Kenya, Cambodia, and Bali[៣] ។

ការជួញដូរភាគច្រើនដែលចូលមកប្រទេសកម្ពុជា, ចេញពីប្រទេសកម្ពុជា និងមាននៅក្នុងប្រទេសកម្ពុជា (ជាប្រទេសកំណើត, ប្រទេសដែលត្រូវឆ្លងកាត់, និងប្រទេសដែលជាទិសដៅសំរាប់ការជួញដូរស្ត្រី និងកុមារ) គឺជាការជួញដូរក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ចាលើផ្លូវភេទ[៤] ។ ស្ត្រី និងកុមារ ភាគច្រើនចាកចេញពីស្រុកកំណើតរបស់ពួកគេ ដែលជាតំបន់ជនបទតំបន់ដាច់ស្រយាលដូចជា ខេត្តព្រៃវែង ឬខេត្តតាកែវ (ឬក៏តំបន់ក្រីក្រក្នុងក្រុង) មកកាន់ទីក្រុង ឧទាហរណ៏ ទីក្រុងភ្នំពេញ, ខេត្តសៀមរាប, និងក្រុងព្រះសីហនុ ព្រមទាំងតំបន់ជាយដែនដូចជា ប៉ោយប៉ែត និងបាត់ដំបង[៥] ។ ដោយសារក្រុងទាំងអស់នេះបានទាក់ទាញភ្ញៀវទេសចរណ៏ដ៏ច្រើន ហើយបានក្លាយទៅជាតំបន់អភិវឌ្ឍនោះធ្វើឱ្យពួកគេកាន់តែគិតថា ពួកគេនឹងអាចមានឱកាសច្រើនក្នុងការរកប្រាក់ចំណូលនៅក្នុងតំបន់បែបនេះផងដែរ។ ហេតុដូច្នេះហើយទើបមានមនុស្សជាច្រើនបានព្យាយាមទៅកាន់ទីនោះ ដោយមានសេចក្តីសង្ឃឹមថា នឹងអាចស្វែងរកការងារធ្វើដែលអាចទទួលបានប្រាក់កំរៃច្រើន។ ផលប៉ះពាល់ដែលបណ្តាលមកពីបញ្ហានេះគឺ កុមារ

[៣] Presentation by Luc Ferran, Program Officer for combating CST, ECPAT International, BKK given at the National Workshop on Child Safe Tourism, 7-8 December 2005; 7 December 2005.
[៤] 2005 Human Rights Report on Trafficking in Persons, Especially Women and Children – Cambodia; www.theprotectionproject.org
[៥] International Labour Organisation (ILO) Regional Office for Asia and the Pacific and International Programme on the Elimination of Child Labour (IPEC), Where We Work – Cambodia; http://www.ilo.org/public/english/region/asro/bangkok/child/trafficking/wherewework-cambodiadetails.htm (updated June 2005).



បើកអង្គប្រជុំមួយសំរាប់អ្នកនាំភ្ញៀវទេសចរណ៏ទាំងអស់ ដោយប្រាប់ពួកគេឱ្យពន្យល់ក្រុមពួកគេថា ការរួមភេទជាមួយអនីតិជន គឺជារឿងខុសច្បាប់ ហើយទទួលទណ្ឌកម្មពីអាជ្ញាធរកម្ពុជា។ វាមិនអាចត្រូវបានធ្វើអោយដឹងច្បាស់ថា តើគ្រប់អ្នកនាំភ្ញៀវទេសចរទាំងអស់ បានពន្យល់នូវផលវិបាកនៃទេសចរណ៏ផ្លូវភេទលើកុមារទៅកាន់ក្រុមថ្មីនៃភ្ញៀវទេសចរនីមួយៗដែររឺទេ។ ភាគច្រើននៃសមាគមទេសចរណ៏អន្តរជាតិ បានបង្កើតនៅគោលការណ៏ណែនាំដែលពាក់ព័ន្ធនឹងការការពារនៃទេសចរណ៏ផ្លូវភេទលើកុមារ។ គោការណ៏ណែនាំទាំងនេះត្រូវបានគេធ្វើឡើងដើម្បីជួយអោយសមាជិក និងដៃគូបង្កើតបាននូវយុទ្ធសាស្ត្រថ្នាក់ជាតិ។ ឧទាហរណ៏ សមាគមទេសចរណ៏អន្តរជាតិ បានបង្កើតក្រុមរួមគ្នាមួយ ដោយជំរុញឱ្យក្រុមហ៊ុនទេសចរណ៏ប្រាប់បុគ្គលិក និងប្រកាសប្រាប់អ្នកដំណើរអំពីវិធីសាស្ត្រដើម្បីបញ្ឈប់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ សមាគមសណ្ឋាគារ និងភោជនីយដ្ឋានអន្តរជាតិបានអះអាងថា ពួកគេនឹងផ្តល់អនុសាសន៏ដល់សមាជិករបស់ពួកគេទំាងអស់ឱ្យឈប់យកកន្លែងរកស៊ីរបស់ពួកគេមកប្រើសំរាប់ផ្លូវភេទលើកុមារ។ សមាគមទេសចរណ៏អាស៊ីប៉ាស៊ីហ្វិកបានបង្កើនការធ្វើដំណើរទេសចរណ៏ទៅកាន់តំបន់នេះជំរុញអោយមានវិស័យទេសចរណ៏កើនឡើង និងបង្កើននូវឱកាសការងារ។ សមាគមទេសចរណ៏អាស៊ីប៉ាស៊ីហ្វិក មានកិច្ចព្រមព្រៀងមួយជាមួយគណៈកម្មាធិការលុបបំបាត់អំពើពេស្យាចារ, រំលោភ, និងការជួញដូរកុមារថា ពួកគេនឹងដកចេញនូវសមាជិកណាមួយ ដែលគេរកឃើញថា មានការពាក់ព័ន្ធទេសចរណ៏ផ្លូវភេទលើកុមារ រឺសកម្មភាពដែលទាក់ទិន។

ការណ៍របស់សណ្ឋាគារនេះ គឺត្រូវទូរស័ព្ទទៅប៉ូលីសប្រសិន បើភ្ញៀវមានបំណងនាំកុមារចូលបន្ទប់របស់គេ ។

### ៤.៣.២ ភ្នាក់ងារទេសចរណ៍

ភ្នាក់ងារទេសចរណ៍ជាច្រើនដែលគេបានជួបនៅក្នុងតំបន់ បី បានអះអាងថា ពួកគេមិនបានផ្តល់ព័ត៌មាន ដែលពាក់ព័ន្ធនឹងទីកន្លែង រឺរបៀបទទួលបានសេវាកម្មផ្លូវភេទនោះទេ។ ពួកគេក៏បាននិយាយផងដែរថា ភ្ញៀវកម្រសួររកសេវាកម្មផ្លូវភេទណាស់។ ភ្នាក់ងារទេសចរណ៍ភ្នំពេញមួយបានប្រាប់អ្នកស្រាវជ្រាវថា ពួកគេរក្សាទុកសៀវភៅមគ្គុទេសន៍ទេសចរណ៍ភ្នំពេញ ដោយមានរូបភាពនៅលើទំព័រខាងក្រោយដែលអាចឱ្យមើលឃើញដោយព្រមានថា ការរួមភេទជាមួយកុមារគឺជាបទឧក្រិដ្ឋ ហើយប្រសិនបើភ្ញៀវស្នើសុំសៀវភៅមគ្គុទេសន៍នេះគេនឹងបង្ហាញទំព័រខាងក្រោយនេះមុនគេ។ អ្នកចាត់ការទូទៅនៃភ្នាក់ងារទេសចរណ៍មួយផ្សេងទៀតដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញ (ដោយមានសាខានៅក្នុងខេត្តជាច្រើន) តឹងតែងណាស់ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ គាត់បានព្រមានបុគ្គលិកទាំងអស់, អ្នកនាំភ្ញៀវទេសចរ, និងដៃគូថា ប្រសិនបើពួកគេមានការពាក់ព័ន្ធណាមួយទៅនឹងបញ្ហានេះ ពួកគេនឹងឈានដល់ការបញ្ចប់ការងារ។ ការិយាល័យនៅសៀមរាបក៏ត្រូវបានចុះទៅដល់ផងដែរ។ នៅទីនោះបុគ្គលិកព្រមានអតិថិជន ដែលត្រូវការសេវាកម្មផ្លូវភេទដែលខុសនឹងច្បាប់កម្ពុជា ទោះបីជាអ្វីដែលពួកគេធ្វើនៅពេលយប់គឺ ជាកាទទួលខុសត្រូវផ្ទាល់របស់ពួកគេយ៉ាងណាក៏ដោយ។ ក្រុមហ៊ុនទេសចរណ៍មួយទៀតដែលមានមូលដ្ឋាននៅទីក្រុងភ្នំពេញបាន



និងស្ត្រីវ័យក្មេងជាច្រើនបានធ្លាក់ចូលក្នុងស្ថានភាពគ្រោះថ្នាក់ដោយខ្លួនឯង ដោយសារការស្វែងរកលុយដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ។

គោលបំណងនៃការសិក្សានេះ គឺស្វែងរកនូវវិសាលភាពដែលទេសចរណ៍ផ្លូវភេទលើកុមារកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ព្រមទាំងធ្វើការស្វែងយល់ថា តើបញ្ហានេះវាបណ្តាលមកពីការកើនឡើងនៃអាំងតង់ស៊ីតេ ឬមិនមែន។ ការស្រាវជ្រាវនេះ គឺផ្តោតទៅលើតំបន់ទិសដៅទេសចរណ៍សំខាន់ៗបំផុត ៣ កន្លែង ហើយនឹងមានគោលបំណងរកអោយឃើញថា តើភាគច្រើនជនជាតិណាជាភ្ញៀវទេសចរណ៍ផ្លូវភេទដែលពាក់ព័ន្ធក្នុងសកម្មភាពផ្លូវភេទជាមួយនឹងអនីតិជននៅក្នុងប្រទេសកម្ពុជា។ ផ្នែកមួយនៃឯកសារនេះ គឺផ្តោតទៅលើអ្នកទេសចរណ៍ផ្លូវភេទជាពិសេស គឺជនជាតិអាមេរិកក្នុងគោលបំណងដើម្បីវាយតំលៃថា តើជនជាតិអាមេរិកបានពាក់ព័ន្ធក្នុងឧស្សាហកម្មផ្លូវភេទក្នុងប្រទេសកម្ពុជា មានកំរិតប៉ុណ្ណាលើសពីនេះទៅទៀត គឺដើម្បីពិភាក្សាលើកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលអាមេរិកដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។ របាយការណ៍នេះក៏មានគោលបំណងដើម្បីពិនិត្យឡើងវិញនូវក្របខ័ណ្ឌនីតិបញ្ញាតិ ហើយនឹងសកម្មភាពអនុវត្តច្បាប់ក្នុងប្រទេសកម្ពុជាដែលពាក់ព័ន្ធទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ បន្ទាប់មកទៀតឯកសារនេះនឹងនិយាយអំពីការពិនិត្យនូវគំនិតផ្តួចផ្តើមដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា, អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។ ឯកសារនេះនឹងធ្វើសេចក្តីសរុបដោយមាន

អនុសាសន៍មួយចំនួនសំរាប់កិច្ចប្រឹងប្រែងបន្ថែមទៀត ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា។

## វិធីសាស្ត្រ

ការសិក្សានេះ បង្កើតបានជាសមាសភាគមួយក្នុងចំណោមសមាសភាគជាច្រើននៃកាសិក្សាដ៏ធំមួយ ដែលធ្វើឡើងដោយគំរោងការពារ[6] ទេសចរណ៍ផ្លូវភេទលើកុមារ។ ការសិក្សាដែលមានទ្រង់ទ្រាយធំលំដាប់ពិភពលោកនឹងធ្វើលើប្រទេសប្រហែលជា ៥ ក្នុងតំបន់នីមួយៗនៃតំបន់ទាំង ៣ ដូចជា តំបន់អាស៊ីអាគ្នេយ៍, តំបន់អាហ្វ្រិក, និងតំបន់អាមេរិកកណ្តាល។ គំរោងការពារបានអនុញ្ញាតឱ្យអង្គការ COSECAM (សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា) ដើម្បីពិនិត្យមើលស្ថានភាពទេសចរណ៍ផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា។ ការស្រាវជ្រាវនៅក្នុងរបាយការណ៍នេះ ភាគច្រើនធ្វើតាមវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព រួមទាំងវិធីសាស្ត្រថ្មីៗទៀតផង។ ជាដំបូងអ្នកស្រាវជ្រាវបានពិនិត្យឯកសារដែលពាក់ព័ន្ធឡើងវិញ គឺមានតាំងពីឯកសារ ដែលទាក់ទងនឹងនីតិបញ្ញត្តិ រហូតដល់ឯកសារស្តីពីការសិក្សាស្រាវជ្រាវមុនៗដែលពាក់ព័ន្ធនឹងប្រធានបទនេះ។ ដំណាក់កាលបន្ទាប់មកទៀត គឺមានការសំភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗរបស់មន្ត្រីរដ្ឋាភិបាលដែលពាក់ពន្ធ័, អង្គការក្រៅរដ្ឋាភិបាល (NGOs), ហើយនឹងអង្គការ

[6] The Protection Project is a human rights research institute that was founded in 1994 and is based at the Johns Hopkins University School of Advanced International Studies (SAIS) in Washington, DC.



ដេកតែ ២-៣ ម៉ោង ប៉ុណ្ណោះ គាត់យកថ្លៃដូចដែលគាត់ជួលពេញមួយយប់ដែរ ដើម្បីការពារមនុស្សទាំងនោះចូលសណ្ឋាគារដើម្បីរួមភេទតែប៉ុណ្ណោះ។

ម្ចាស់សណ្ឋាគារ, ហាងកាហ្វេ, និងភោជនីយដ្ឋានដែលស្ថិតនៅក្បែរមាត់ទន្លេក្នុងក្រុងភ្នំពេញ ហាមឃាត់បុគ្គលិករបស់គាត់ពីការសំរបសំរួលរវាងភ្ញៀវ និង ស្ត្រីរកស៊ីផ្លូវភេទ ឬក៏ស្រីដ៏ទៃទៀតរាប់បញ្ចូលទាំងការទាក់ទងស្រីឱ្យមកកាន់បន្ទប់សណ្ឋាគាររបស់ភ្ញៀវ។ សមាជិកបុគ្គលិកត្រូវបានហាមឃាត់មិនអោយចេញទៅក្រៅជាមួយភ្ញៀវទេ ទោះបីពួកគេត្រូវបានគេអោយលុយក៏ដោយ។ ជាទូទៅ នៅទីនេះភ្ញៀវមិនមានបំណងនាំអនីតិជនមកកាន់បន្ទប់របស់គេទេ។ មានពេលមួយជនជាតិបារាំងម្នាក់បានព្យាយាមនាំក្មេងស្រី ដែលមានអាយុប្រហែល ១៥ ឆ្នាំ មកក្នុងសណ្ឋាគារ ក៏ប៉ុន្តែម្ចាស់សណ្ឋាគារនោះមិនអនុញ្ញាតឱ្យភ្ញៀវនោះស្នាក់នៅបានទេ ពីព្រោះគាត់ភ័យខ្លាចអាជ្ញាធរនឹងដកអាជ្ញាប័ណ្ណរកស៊ីរបស់គាត់។ នេះគឺ ជាអ្វីដែលគាត់បានធ្វើនៅពេលដែលគាត់សង្ស័យថា ភ្ញៀវនាំនរណាម្នាក់ដែលជាអនីតិជនមកក្នុងសណ្ឋាគារ។ សណ្ឋាគារ និងផ្ទះសំណាក់ភាគច្រើន ដែលត្រូវបានគេចូលមើលនៅក្នុងក្រុងភ្នំពេញ, សៀមរាប, និងក្រុងព្រះសីហនុនោះគឺមានទាំងស្ទីឃ័រ, ផ្ទាំងរូបភាព, ខិតប័ណ្ណ, វីព័ត៌មានមគ្គុទេសទេសចរណ៍ ដែលមានសារីការព្រមានមួយចំនួនប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ព្រមទាំងលេខ Hotline របស់ក្រសួងមហាផ្ទៃដើម្បីទូរស័ព្ទ ប្រសិនបើមានលក្ខណៈសង្ស័យ។ សណ្ឋាគារមួយបានអះអាងថា ខ្លួនបានបិទផ្ទាំងរូបភាពនៅខាងក្រោយនៃមាត់ទ្វារបន្ទប់សណ្ឋាគារនីមួយៗ ដោយព្រមានប្រឆាំងនឹងទេសចរណ៍ផ្លូវភេទ។ គោល

សណ្ឋាគារ ដោយមានស្ត្រីរកស៊ីផ្លូវភេទស្ត្រីនោះត្រូវតែប្រើច្រកចូលផ្សេង ហើយអត្តសញ្ញាណប័ណ្ណរបស់នាងត្រូវបានរក្សាទុកនៅមាត់ទ្វាររហូតដល់នាងចាកចេញ។ ប្រសិនបើ ភ្ញៀវទេសចរចូលក្នុងសណ្ឋាគារនោះដោយមានអនីតិជន (ឬមនុស្សដែលមើលទៅអាចមានអាយុតិចជាង ១៨ ឆ្នាំ) សណ្ឋាគារនឹងទាក់ទងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែប្រសិនបើស្ត្រីវ័យក្មេងមើលទៅអាយុលើស ១៨ ឆ្នាំ សណ្ឋាគារមិនអាចហាមឃាត់នាងទេ។ សណ្ឋាគារដ៏ទៃទៀតដែលមានឋានៈស្រដៀងគ្នាមានបំណងរក្សានូវបទបញ្ជាផ្ទៃក្នុងដ៏តឹងរឹងដូចគ្នានេះដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពលំបាកមានការកើតឡើងនៅពេលដែលមានហាងកាហ្វេ ឬកន្លែងលេងកីឡាដែលអាចត្រូវបានចូលដោយមនុស្សដែលមិនមែនជាភ្ញៀវសណ្ឋាគារ ពីព្រោះជាធម្មតាបញ្ហានេះមានន័យថា មានច្រកចូលសណ្ឋាគារច្រើនជាងមួយ។ វាត្រូវតែពុះពារការលំបាកក្នុងបំណងត្រួតពិនិត្យចំពោះមនុស្សគ្រប់រូប ដែលចេញចូលក្នុងសណ្ឋាគារនោះ និងបែងចែកឱ្យច្បាស់រវាងអតិថិជន និងភ្ញៀវដែលស្នាក់នៅពេញមួយយប់ ហើយនិងមិត្តភ័ក្តិរបស់ភ្ញៀវ។ ផ្ទះសំណាក់ដ៏តូចមួយនៅកណ្តាលក្រុងភ្នំពេញតំរូវឱ្យសុំអត្តសញ្ញាណប័ណ្ណពីគ្រប់អ្នកដែលមកកាន់សណ្ឋាគារជាមួយនឹងភ្ញៀវ ដែលជាអ្នកស្នាក់នៅក្នុងផ្ទះសំណាក់នោះ។ ម្ចាស់ផ្ទះសំណាក់នោះជាធម្មតាអង្គុយនៅតុទទួលភ្ញៀវខាងមុខ រហូតដល់ភ្ញៀវទាំងអស់ត្រឡប់មកវិញ ហើយនៅពេលនោះទើបគាត់ចាក់សោទ្វារ។ អ្នកគ្រប់គ្រងសណ្ឋាគារខ្នាតមធ្យម/ខ្នាតទាបមួយបានប្រាប់អ្នកស្រាវជ្រាវថា ប្រសិនបើសង្សារ ១ គូ ចង់ជួលបន្ទប់



អន្តរជាតិដ៏ទៃៗទៀត (IOs) ដែលធ្វើការងារពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ ការសំភាសន៍ទាំងនេះគឺ មានលក្ខណៈពាក់កណ្តាលផ្លូវការក្នុងគោលបំណងដើម្បីអនុញ្ញាតឱ្យអ្នកផ្តល់ព័ត៌មានបាននិយាយដោយសេរីបានច្រើន និងឱ្យមានភាពក្បោះក្បាយ ហើយពេលខ្លះមានការសួរកាត់ជាដើមដែលអាចធ្វើទៅបាន។ អ្នកស្រាវជ្រាវយើង ក៏បានបញ្ចេញគំនិតដូចគ្នាទៅនឹងព័ត៌មានដែលទទួលបានពីអ្នកផ្តល់បទសំភាសន៍នីមួយៗ ដូច្នេះធ្វើឱ្យពួកគេអាចទទួលបានព័ត៌មានជាច្រើនទៅតាមសំណួររបស់ពួកគេ។ នៅខណៈពេលគេកំពុងតែធ្វើការស្រាវជ្រាវនេះ ក្រសួងទេសចរណ៍ (MoT), អង្គការទស្សនៈពិភពលោកកម្ពុជា (WVC), និងគណៈកម្មាធិការលុបបំបាត់អំពើពេស្យាកម្មលើកុមារ, រូបភាពអាសអាភាសលើកុមារ, ហើយនឹងការជួញដូរកុមារសំរាប់គោលបំណងលើផ្លូវភេទ (ECPAT) បានធ្វើសន្និសីទជាតិមួយស្តីពី ទេសចរណ៍សុវត្ថិភាពលើកុមារ។ ជាភ័ព្វសំណាងអ្នកស្រាវជ្រាវ មានលទ្ធភាពចូលរួមប្រជុំក្នុងអំឡុងពេលដែលមន្ត្រីរាជរដ្ឋាភិបាលព្រមទាំងអង្គការក្រៅរដ្ឋាភិបាលបានធ្វើបទឧទ្ទេសនាម/ការបង្ហាញអំពីបញ្ហានេះ។

ដំណាក់កាលបន្ទាប់ទៀត គឺចុះស្រាវជ្រាវដល់ទីកន្លែង។ ទោះបីជាការស្រាវជ្រាវនេះ មានបំណងពិនិត្យមើលនូវវិសាលភាពនៃបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ក៏លទ្ធផលដែលទទួលបាននោះមិនតំណាងឱ្យស្ថានភាពក្នុងប្រទេសទាំងមូលនោះដែរ។ អ្នកស្រាវជ្រាវមានលទ្ធភាពធ្វើតែនៅក្រុងភ្នំពេញ, ខេត្តសៀមរាប និងក្រុងព្រះសីហនុប៉ុណ្ណោះ ដោយសារតែឧបសគ្គនៃពេលវេលា, សមាមាត្រដ៏ធំបំផុតនៃពេលវេលា ត្រូវបានផ្តោតទៅលើ

ក្រុងភ្នំពេញ គឺមានតែ៥ថ្ងៃប៉ុណ្ណោះសំរាប់ខេត្តសៀមរាប និងក្រុងព្រះសីហនុ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកស្រាវជ្រាវមានលទ្ធភាពទទួលបាននូវព័ត៌មានសំខាន់ៗមួយចំនួនអំពីស្ថានភាពក្នុងតំបន់នីមួយៗនៃតំបន់ទាំងនេះ។ នៅក្នុងខេត្តសៀមរាប ការសំភាសន៍ត្រូវបានរៀបចំឡើងជាមួយអ្នកផ្តល់ព័ត៌មានដែលមកពីសមាគមសណ្ឋាគារ, សណ្ឋាគារមួយចំនួនដែលមានស្តង់ដាខុសៗគ្នា, ផ្ទះសំណាក់, ក្រុមហ៊ុនទេសចរណ៍ ហើយនឹងជាមួយអ្នករត់ម៉ូតូឌុប, ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ ព្រមទាំងមន្ត្រីរាជរដ្ឋាភិបាល ដែលមកពីនាយកដ្ឋានទេសចរណ៍។ ក្នុងក្រុងព្រះសីហនុ អ្នកស្រាវជ្រាវបាននិយាយជាមួយមនុស្សសំខាន់ៗនៅឯសណ្ឋាគារដែលមានស្តង់ដាផ្សេងៗគ្នា, ផ្ទះសំណាក់, ក្រុមហ៊ុនទេសចរណ៍ (ទោះបីជាអ្នកប្រតិបត្តិការទេសចរណ៍ ភាគច្រើនទំនងជាក្រុមហ៊ុនជួលឡានទេសចរណ៍ ដែលជាអ្នករៀបចំការធ្វើដំណើរ និងដំណើរកំសាន្ត), មន្ត្រីនាយកដ្ឋាន ទេសចរណ៍ ហើយនិងនាយប៉ូលីសទេសចរណ៍។ ជាអកុសល អ្នកស្រាវជ្រាវមិនមានលទ្ធភាពបានជួបជាមួយមន្ត្រីណាម្នាក់មកពីនាយកដ្ឋានប្រឆាំងនឹងការជួញដូរមនុស្ស និងការពារអនីតិជននៅក្នុងខេត្តសៀមរាប ឬក៏ក្រុងព្រះសីហនុ ដោយសារតែមិនមានពេលវេលាគ្រប់គ្រាន់ក្នុងក្រុងនីមួយៗ ហើយនឹងតំរូវការពេលវេលារបស់មន្ត្រីទាំងនោះ។

នៅក្នុងទីក្រុងភ្នំពេញ អ្នកស្រាវជ្រាវបានទៅជួបសួរបុគ្គលិកសណ្ឋាគារក្នុងសណ្ឋាគារ ដែលចាប់ផ្តើមពីផ្ទះសំណាក់រហូតដល់សណ្ឋាគារផ្កាយបួន។ ក្រុមហ៊ុនទេសចរណ៍មួយចំនួនក៏ត្រូវបានគេចុះទៅដែរ (ទោះបីជាអ្នកស្រាវជ្រាវត្រូវ



នេះមានអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកជាសមាជិកចំនួន ២៣ ហើយមានបំណងសំរបសំរួលកិច្ចប្រឹងប្រែងនៃអង្គការទាំងអស់នេះ ដើម្បីអោយទទួលបាននូវភាពជោគជ័យ និងប្រសិទ្ធិភាពច្រើនបំផុត។ គណៈកម្មាធិការលុបបំបាត់អំពើពេស្យាចារ, រំលោភ, និងការជួញដូរកុមារ គឺជាបណ្តាញមួយផ្សេងទៀតដែលមានគោលការណ៍ដឹកនាំស្រដៀងៗគ្នា ។

## ៤.៣. ផ្នែកឯកជន

ក្នុងការសិក្សានេះ ផ្នែកឯកជន គឺមានសណ្ឋាគារ, ផ្ទះសំណាក់, ភ្នាក់ងារទេសចរណ៍, និងក្រុមហ៊ុនទេសចរណ៍ ដែលត្រូវបានបង្កើតក្នុងបរិបទទេសចរណ៍។ គោលបំណងនៃក្រុមហ៊ុនបែបនេះគឺ ផ្តល់នូវសេចក្តីត្រូវការផ្សេងៗដល់ភ្ញៀវទេសចរ។ ភាគច្រើនការរកស៊ីទាំងនេះត្រូវបានគ្រប់គ្រងដោយឯកជន ទោះបីជាយ៉ាងណា ក៏ដោយក៏មានការរកស៊ីជាច្រើនដែលជាកម្មសិទ្ធិរបស់មន្ត្រីរដ្ឋាភិបាលដែលមានបុណ្យស័ក្តិខ្ពស់។

## ៤.៣.១. សណ្ឋាគារ

សណ្ឋាគារខ្លះមានគោលការណ៍តឹងរឹង ដែលពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ ជាអកុសលសណ្ឋាគារទាំងនេះមានភាគតិច ពីព្រោះម្ចាស់សណ្ឋាគារភាគច្រើនខ្លាចបាត់បង់នូវការរកស៊ី ហើយគេជឿជាក់ថា អតិថិជនគឺ ជាស្តេចទោះជាតំរូវការរបស់អតិថិជនជាអ្វីក៏ដោយ។ សណ្ឋាគារសាន់វេ ក្នុងក្រុងភ្នំពេញមានច្បាប់តឹងតែងដែលពាក់ព័ន្ធនឹងបញ្ហានេះ។ នៅពេលដែលភ្ញៀវចូលមក

អតិថិជននោះ ស្រាប់តែមានគេទំលាក់ចោលកូនសៀវភៅអប់រំតូចៗនោះគាត់គិតថា សៀវភៅនោះគឺគេបានមកពីបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ។

ផ្នែកនេះមិនមានបំណងរៀបរាប់គ្រប់រាល់កិច្ចខិតខំប្រឹងប្រែង ដែលធ្វើឡើង ដោយផ្នែកអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងបរិបទទេសចរណ៍នោះទេ។ អ្នកនិពន្ធផ្តោតអារម្មណ៍លើយុទ្ធនាការ ដែលត្រូវបានកំណត់ទិសដៅយ៉ាងជាក់លាក់ទៅលើទេសចរណ៍ផ្លូវភេទលើកុមារ ព្រមទាំងគំនិតផ្តួចផ្តើមដែលគេយល់ថា ប្លែកហើយថ្មី។ អង្គការលីកាដូបានស្វែងរកការរំលោភសិទ្ធិមនុស្ស និងស៊ើបអង្កេតករណីរំលោភ និងការរំលោភផ្លូវភេទលើកុមារដ៏ទៃទៀត។ អង្គការ AFESIP ផ្តល់ជំរកដល់ស្ត្រី (និងកុមារមួយចំនួន) ដែលជាជនរងគ្រោះនៃការជួញដូររាប់បញ្ចូលទាំងដើម្បីគោលបំណងផ្លូវភេទផងដែរ។ អង្គការពលកម្មអន្តរជាតិ មានបំណងទប់ស្កាត់នូវទម្រង់រូបភាពអាក្រក់បំផុតនៃពលកម្មកុមារ ដែលគ្របដណ្តប់ទៅលើការកេងប្រវ័ញ្ចផ្លូវភេទលើកុមាររាប់បញ្ចូលទាំងក្នុងវិស័យទេសចរណ៍។ អង្គការ UNICEF ធ្វើការដើម្បីលើកកំពស់សិទ្ធិកុមារ ហើយមានកម្មវិធីមួយក្នុងប្រទេសកម្ពុជាដែលព្យាយាមការពារកុមារដែលកំពុងរស់នៅក្នុងស្ថានភាពមួយដ៏អាក្រក់បំផុត។ ហើយក៏មានបណ្តាញជាច្រើនមួយចំនួនផងដែរ ដែលខិតខំព្យាយាមបញ្ចូលគ្នានូវការខិតខំប្រឹងប្រែងរបស់អង្គការក្រៅរដ្ឋាភិបាលដែលកំពុងតែធ្វើការដែលមានគោលដៅស្រដៀងៗគ្នា។ អង្គការ COSECAM គឺជាសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា។ សម្ព័ន្ធអង្គការ



បានគេបដិសេធមិនព្រមជួប ដោយសារតែអ្នកគ្រប់គ្រងនោះពុំមានពេលវេលាហើយមិនមានលេខទំនាក់ទំនងសំរាប់ឱ្យពួកយើងអាចធ្វើការណាត់ជួបនៅពេលក្រោយបានក៏ដោយ)។ នគរបាលទេសចរណ៍ មិនមានលទ្ធភាពផ្តល់ព័ត៌មានឱ្យបានច្រើនដល់ពួកយើង ជាអកុសលដោយសារតែបញ្ហានេះឋិតនៅត្រង់ថាអំណាច ឬក៏ការទទួលខុសត្រូវលើរឿងទាំងអស់ដែលពាក់ព័ន្ធទៅនឹងអ្នកទេសចរផ្លូវភេទបរទេសថ្មីៗនេះ ត្រូវបានផ្លាស់ប្តូរទៅអោយនាយកដ្ឋានទេសចរណ៍វិញ។ សំបុត្រមួយច្បាប់ ដែលបានស្នើសុំជួបជាមួយនឹងមនុស្សដែលពាក់ពន្ធ័ត្រូវបានផ្ញើរទៅកាន់នាយកដ្ឋានទេសចរណ៍នោះ ក៏មិនទទួលបានជោគជ័យដែរ ។

ឧបសគ្គធំៗក្នុងការប្រមូលទិន្នន័យចំពោះការសិក្សានេះ គឺការប្រមូលទិន្នន័យដើម, ឬស្ថិតិផ្លូវការ។ មន្ត្រីរដ្ឋាភិបាលដែលមានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញ ហើយដែលបានសហការពីដំបូងនោះ ក្រោយមកមិនបានផ្តល់ព័ត៌មានអំពីស្ថិតិដែលខ្លួនបានសន្យានោះទេ។ អ្នកស្រាវជ្រាវបានតាមអ្នកដែលពួកគេបានសំភាស ហើយដែលបានអះអាងថា ពួកគេនឹងផ្ញើទិន្នន័យបន្ថែមឱ្យទៀត ប៉ុន្តែយើងបានទទួលចំលើយពីអ្នកខ្លះតែប៉ុណ្ណោះ ក៏ប៉ុន្តែរឿងរ៉ាវពិតប្រាកដមួយចំនួននោះ គឺយើងទទួលបានតែពីមនុស្សពីរ-បីនាក់តែប៉ុណ្ណោះ។ ភាពលំបាកក្នុងការប្រមូលទិន្នន័យដើម គឺកាន់តែធ្វើឱ្យវាមានការលំបាកថែមទៀត ក្នុងការបង្ហាញនូវតួលេខដែលគួរឱ្យទុកចិត្តបានស្តីពី វិសាលភាពពិតប្រាកដនៃទេសចរណ៍ផ្លូវភេទលើកុមារ ។

# របកគំហើញ

## ១. វិស័យទេសចរណ៍នៅកម្ពុជា

វិស័យទេសចរណ៍នៅកម្ពុជាកំពុងកើនឡើងជាលំដាប់។ ក្នុងឆ្នាំ ២000 ក្នុងប្រទេសកម្ពុជាមានភ្ញៀវទេសចរ ៤៦៦ ៣៦៥ នាក់ តួលេខនេះបានកើនឡើង រហូតដល់ ៧៨៦ ៥២៤ នាក់ ក្នុងឆ្នាំ ២00២។ ក្នុងឆ្នាំ ២00៤ មានភ្ញៀវទេសចរ ១ 0៥៥ ២0២ នាក់ គឺ មានការកើនឡើង ៥0,៥៣% ច្រើនជាងឆ្នាំមុន។ តួលេខសំរាប់ឆ្នាំ ២00៥ មានភ្ញៀវទេសចរកើនឡើងលើសពីមួយលាននាក់ រួចទៅហើយនៅខែធ្នូ ឆ្នាំ ២00៥ ហើយតួ លេខនេះរាប់បញ្ចូលតាំងពី ខែមករា រហូតដល់ខែកញ្ញា ហើយចំនួន៉បាន់ស្មានសរុបសំរាប់ឆ្នាំ ២00៥ មានភ្ញៀវទេសចរ ១,៣ លាននាក់[7]។ ប្រសិនបើអត្រាផ្សៀវទេសចរណ៍នៅតែកើនឡើងយ៉ាងនេះ ក្រសួងទេសចរណ៍បានទស្សន៍ទាយថា នឹងមានផ្សៀវទេសចរណ៍ ៣ ១២0 000 នាក់មកទស្សនះកិច្ចក្នុងប្រទេសកម្ពុជា ឆ្នាំ ២0១0[8]។ ប្រទេសកម្ពុជាមានការផ្តល់ដល់អ្នកទេសចរច្រើនដូចជា វប្បធម៌, ធម្មជាតិ, និងប្រវត្តិសាស្ត្រ ហើយបច្ចុប្បន្ននេះអ្វីៗដែលរៀបរាប់នេះ គឺនៅតែថ្មីសំរាប់ភ្ញៀវទេសចរគឺ ជាទិសដៅនៅលើផែនទីសំរាប់ភ្ញៀវទេសចរ ដែលត្រូវមកទស្សនា។ បើប្រៀបធៀបទៅនឹងប្រទេសថៃ ដែលជាប្រទេសជិតខាងប្រទេសកម្ពុជា នៅតែជាទីកន្លែងមួយដែលមនុស្សជាច្រើនមិនទាន់បានស្គាល់ច្បាស់, ជាកន្លែងដែលមានអាថ៌កំបាំង, មានលក្ខណះពិសេស

---

[7] Interview with Mr. Hor Sarun, Deputy Director General of Admin. & Finance and Head of CSTC-MOT Secretariat, Ministry of Tourism; 06 December 2005.

[8] Presentation of Mr. Hor Sarun, Deputy Director General of Admin. & Finance and Head of CSTC-MOT Secretariat, Ministry of Tourism at the Child Sex Tourism Prevention Workshop, 28 February & 01 March 2005.



ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។ យោងទៅលើភ្នាក់ងារទេសចរណ៍ដែលត្រូវបានសំភាសក្នុងក្រុងភ្នំពេញបានអោយដឹងថា គណៈកម្មាធិការលុបបំបាត់អំពើពេស្យាចារ, រំលោភ, និងការជួញដូរលើកុមារបានមកដល់កាលពីឆ្នាំទៅមិញ ហើយបានចែកចាយស្ទីយ័រ និងផ្ទាំងរូបភាពប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារ។ បុគ្គលិកដែលធ្វើការងារនៅសណ្ឋាគារភ្នំពេញបានប្រាប់អ្នកស្រាវជ្រាវថា អង្គការមួយឈ្មោះថា ហ្វ្រេន បានមកជួបជាមួយសមាជិកបុគ្គលិកដើម្បីនិយាយអំពីទេសចរណ៍ផ្លូវភេទលើកុមារ ហើយពន្យល់នូវភាពសំខាន់នៃការរាយការណ៍នូវហេតុការណ៍ដែលកើតឡើងទៅកាន់ទូរស័ព្ទលេខ Hotline របស់ក្រសួងមហាផ្ទៃ។ អង្គការម្លប់ត្រពាំង រៀបចំសិក្ខាសាលាសំរាប់កុមារ និងគ្រួសាររបស់គេនៅក្នុងទីក្រុងព្រះសីហនុ។ ប្រជាជនកម្ពុជាជាច្រើនមិនយល់នូវគំនិតដែលបង្កប់នូវឧបាលកលបោកបញ្ឆោត ដោយធ្វើអោយជនរងគ្រោះមានសេចក្តីទុកចិត្ត។ ប្រជាជនកម្ពុជាទាំងនោះមួយផ្នែកពួកគេមិនគិតថា នេះគឺជាឧបាយកលទេ ប៉ុន្តែម្យ៉ាងពួកគេត្រូវការលុយ និងការផ្គត់ផ្គង់ ដែលពួកគេបានទទួលនោះយ៉ាងខ្លាំង។ ឧបាយកលបោកបញ្ឆោតនេះគឺ ជាប្រធានបទមួយដែលមាននៅក្នុងវគ្គបណ្តុះបណ្តាលមួយពេល : សិក្ខាកាមតក់ស្លុតដោយមិននឹកស្មានថា គំនិតនេះមានបង្កប់នូវឧបាយកលរបៀបនេះសោះ ប៉ុន្តែយ៉ាងហោចណាស់ពួកគេត្រូវបានគេប្រាប់ឱ្យដឹងថា វាពិតជាមានរឿងដូច្នេះកើតមានឡើងប្រាកដមែន។ អ្នករត់ម៉ូតូឌុបក្នុងក្រុងព្រះសីហនុម្នាក់បានអះអាងថា មួយដងនោះគាត់ទទួលបានកូនសៀវភៅអប់រំតូចៗស្តីពីទេសចរណ៍ផ្លូវភេទលើកុមារ គឺនៅពេលដែលគាត់កំពុងរង់ចាំ

ទៅក្នុងផ្ទះបនវិញ[៥៦] ។ ក្នុងឆ្នាំ ២០០១ អង្គការទស្សនៈពិភពលោកកម្ពុជា បានបង្កើតគំរោងមួយឈ្មោះថា គំរោងការពារទេសចរណ៏ផ្លូវភេទលើកុមារ។ អង្គការទស្សនៈពិភពលោកកម្ពុជារៀបចំវគ្គបណ្តុះបណ្តាល ដើម្បីបង្រៀនសិក្ខាកាមអំពីរបៀបជៀសវាងការក្លាយជាជនរងគ្រោះនៃទេសចរណ៏ផ្លូវភេទលើកុមារ។ អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិនេះ ចូលរួមក្នុងការបង្កើតផ្ទាំងរូបភាពពាណិជ្ជកម្មធំៗ និង ផ្ទាំងរូបភាពតូចៗ ដែលអាចត្រូវបានគេមើលឃើញទូទាំងប្រទេសកម្ពុជា។ មានផ្ទាំងរូបភាពពាណិជ្ជកម្មធំៗ ៨ ជុំវិញទីក្រុងភ្នំពេញរាប់បញ្ចូលទាំងក្បែរមាត់ទន្លេ និងក្បែរព្រលានយន្តហោះ។ "កេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅទីនេះនឹងជាប់ពន្ធនាគារនៅក្នុងប្រទេសរបស់អ្នក"។ ប្រតិកម្មដែលត្រូវបានទទួលផ្អែកទៅលើដំណើររឿងដ៏គួរឱ្យចាប់អារម្មណ៏នោះទំនងជាបង្ហាញថា ការផ្សព្វផ្សាយទាំងនេះបន្តិចម្តងៗបានធ្វើឱ្យមានការភ័យខ្លាច និងការរំជួលញាប់ញ័រក្នុងចិត្តនៅក្នុងចំណោមភ្ញៀវទេសចរ ដែលពាក់ព័ន្ធក្នុងការស្វែងរកផ្លូវភេទជាមួយនឹងអនីតិជន។ យុទ្ធនាការភាគច្រើន គឺសំដៅលើពួកបច្ចឹមប្រទេស។ យុទ្ធនាការទាំងអស់នេះត្រូវតែធ្វើឱ្យបានចំគោលដៅជាក់លាក់ជាងនេះទៀត ហើយគួរតែដាក់ទិសដៅឱ្យជាក់លាក់លើភ្ញៀវទេសចរណ៏ជនជាតិណាមួយ ដែលភាគច្រើនពួកគេមានតំរូវការបែបនេះ ។

អង្គការទស្សនៈពិភពលោកកម្ពុជាធ្វើការរួមគ្នាជាមួយក្រសួងទេសចរណ៏និងគណកម្មាធិការលុបបំបាត់អំពើពេស្យាចារ, រំលោភ, និងការជួញដូរលើកុមារ

[56] Dr. Thomas, Frederic, commissioned by AIDéTouS and COSECAM, Impact of Closing Svay Pak – Study of police and international NGO-assisted interventions in Svay Pak, Kingdom of Cambodia, January 2005.



របស់ប្រទេស, ហើយនឹងមិនចំណាយថវិកាច្រើនផង។ លក្ខណៈពិសេសទាំងអស់នេះបានទាក់ទាញភ្ញៀវទេសចរជាច្រើន រាប់បញ្ចូលទាំងជនទាំងឡាយណាដែលអាចពាក់ព័ន្ធក្នុងសកម្មភាពផ្លូវភេទជាមួយនឹងអនីតិជនផងដែរ។ នៅខណៈពេលដែលមានភ្ញៀវទេសចរកើនឡើងនឹងទទួលផលប្រយោជន៏ទាំងសេដ្ឋកិច្ច ទាំងការអភិវឌ្ឍន៏របស់ប្រទេសកម្ពុជាផងនោះ វិស័យទេសចរណ៏ក៏មានផលប៉ះពាល់ដ៏មានគ្រោះថ្នាក់ផងដែរ។ ដោយមានការកើនឡើងក្នុងវិស័យទេសចរណ៏វានឹងអាចមានការកើនឡើងនៃភ្ញៀវទេសចរណ៏ផ្លូវភេទ ប្រសិនបើការអនុវត្តន៏ច្បាប់មិនបានរឹតបន្តឹងឱ្យខ្លាំងជាងមុនទេ នោះក្នុងករណីនេះភ្ញៀវទេសចរផ្លូវភេទនឹងស្វែងរកទិសដៅថ្មី។ ពិតណាស់ចំនួនភ្ញៀវទេសចរណ៏នឹងបន្តកើនឡើងជាមួយនឹងការបើកឡើងវិញនៃអាកាសយានដ្ឋានក្នុងក្រុងព្រះសីហនុ ដូចដែលត្រូវបានគ្រោងទុកសំរាប់ឆ្នាំនេះ ហើយកន្លងមកក៏ចាប់ផ្តើមមានទូកដួលដែលនាំភ្ញៀវមកពីប្រទេសម៉ាឡេស៊ី។ មានផែនការជាច្រើនផងដែរ ដើម្បីរៀបចំពិធីបុណ្យរាប់បញ្ចូលទាំងការប្រគំតន្ត្រី, កីឡា, និងវប្បធម៌ដែលអាចទាក់ទាញភ្ញៀវទេសចរកាន់តែច្រើន។

## ១.១ ហេតុអ្វីបានជាប្រទេសកម្ពុជាជាទិសដៅទេសចរណ៏ផ្លូវភេទលើកុមារ?

ភ្នាក់ងារទេសចរណ៏ ២២ ហើយនឹងក្រុមហ៊ុនទេសចរណ៏បានចូលរួមក្នុងការសិក្សា ដែលត្រូវបានរៀបចំដោយអង្គការទស្សនៈពិភពលោកកម្ពុជាសហការជាមួយក្រសួងទេសចរណ៏ហើយនឹងក្រុមប្រឹក្សាកុមារជាតិកម្ពុជា ដែលបានប៉ាន់ប្រមាណថា មានភ្ញៀវទេសចរណ៏ ២១,៧% មកទស្សនៈកិច្ចកម្ពុជាក្នុងគោលបំណង

ទេសចរណ៏ផ្លូវភេទ (៣២,៥% ដើម្បីទេសចរណ៍វប្បធមិ, ២៥% ដើម្បីជំនួញ, ហើយ ២០,៨% ដើម្បីទស្សនៈកិច្ចផ្លូវការ[៩])។ មានហេតុផលផ្សេងៗ ដែលនឹងអាចពន្យល់នូវការកើនឡើងជាក់ស្តែងនៃទេសចរណ៏ផ្លូវភេទក្នុងប្រទេសកម្ពុជា។ ម៉្យាងវិញទៀត ឧស្សាហកម្មទេសចរណ៍កំពុងមានវិសាលភាពយ៉ាងខ្លាំងក្នុងតំបន់អាស៊ីអាគ្នេយ៍ជាពិសេសប្រទេសកម្ពុជា។ ដោយជើងហោះហើរដែលមានតំលៃថោកដែលកន្លងមកមានតែនៅអឺរ៉ុប ឥឡូវនេះចាប់ផ្តើមមាននៅក្នុងបណ្តាប្រទេសនៅអាស៊ី ហើយដូច្នេះធ្វើអោយមនុស្សម្នាជាច្រើនទៀតបានធ្វើដំណើរទេសចរណ៍[១០]។ ប្រទេសកម្ពុជា អាចត្រូវបានគេចាត់ទុកជាទិសដៅថ្មីសំរាប់ទេសចរណ៏ផ្លូវភេទ : ប្រទេសកម្ពុជានៅតែជាទីកន្លែងមួយថ្មី ដែលមនុស្សជាច្រើនមិនទាន់បានស្គាល់ច្បាស់, ជាកន្លែងដែលបង្កប់នៅក្នុងគំនិតពួកគេថា ជាកន្លែងបង្កប់នូវអាថ៌កំបាំងជាច្រើន, មានលក្ខណៈពិសេសរបស់ប្រទេស, ប៉ុន្តែការចំណាយថវិកាបែជាអស់តិចជាងការចំណាយនៅក្នុងប្រទេសថៃ ដែលជាប្រទេសជិតខាង[១១]ទៅវិញ។ លើសពីនេះទៅទៀតគេនិយាយថា រដ្ឋាភិបាលថៃកំពុងចាត់វិធានការទៅនឹងទេសចរណ៏ផ្លូវភេទ ដែលបង្ខំអោយជនល្មើសផ្លូវភេទស្វែងរកទិសដៅថ្មី។ ហើយនៅខណៈពេលដែលប្រទេសកម្ពុជា ទំនងជាមានភាពល្បីល្បាញចំពោះការអនុវត្តន៏ច្បាប់ធូររលុង ជនប្រព្រឹត្តិអំពើអនាចារលើកុមារ ហើយនឹងភ្ញៀវទេសចរផ្លូវភេទ

[៩] Nuon Rithy Niron, Yit Viriya and Laurence Gray for World Vision Cambodia with the cooperation of the Ministry of Tourism and the Cambodian National Council for Children (CNCC), *Children's Work, Adult's Play; Child Sex Tourism – The Problem in Cambodia*, September 2001, World Vision International; p.36.

[10] Presentation by Luc Ferran, Program Officer for combating CST, ECPAT International, Bangkok at the National Workshop on Child Safe Tourism, 7-8 December 2005; 7 December 2005.

[11] Interview with Mr. Christian Guth, Law Enforcement Advisor, LEASEC Project, Ministry of Interior; 05 December 2005.



ជាមួយជនរងគ្រោះពិតប្រាកដ រឺក៏ជនដែលអាចនឹងរងគ្រោះរួចហើយ។ ការស៊ើបអង្កេតទូទៅថ្មីៗនេះអំពីអំពើអនាចារ គឺលទ្ធផលបាននាំអោយអង្គការ APLE ប្រគល់រឿងក្តីពិសេសមួយទៅឱ្យប៉ូលីស ដែលឈានដល់ការចាប់ខ្លួនជនជាតិអាឡឺម៉ង់ម្នាក់ បន្ទាប់មកត្រូវបានចោទប្រកាន់ពីបទអំពើអបាយមុខ។ បុរសនោះត្រូវបានសង្ស័យថា មានទំនាក់ទំនងផ្លូវភេទជាមួយ ក្មេងប្រុសអាយុ ១៤ ឆ្នាំ[៥៥]។ អង្គការបេសកកម្មយុត្តិធមិអន្តរជាតិស៊ើបអង្កេតរឿងក្តីនៃការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទ ហើយបណ្តុះបណ្តាលទាំងប៉ូលីសក្រុង ទាំងមន្ត្រីក្នុងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនូវរបៀបស៊ើបអង្កេតតាមប្រភេទនៃរឿងក្តីទាំងនេះ, របៀបរក្សាភស្តុតាងដែលប្រមូលបានពីកន្លែងកើតហេតុឧក្រិដ្ឋកម្ម និងរបៀបសំភាសសាក្សីកុមារ។ ឥឡូវនេះអង្គការក្រៅរដ្ឋាភិបាលនេះធ្វើការនៅទីក្រុងភ្នំពេញ និងតំបន់ដែលនៅជុំវិញទីនោះ ប៉ុន្តែអង្គការនេះសង្ឃឹមថា នឹងពង្រីកទិសដៅរបស់ខ្លួនទៅកាន់ខេត្តនានា។ អង្គការបេសកកម្មយុត្តិធមិអន្តរជាតិបានវាយឆ្មក់នៅផ្ទះបនមួយចំនួនក្នុងកិច្ចសហប្រតិបត្តិការជាមួយប៉ូលីសកម្ពុជារួមមានតំបន់ស្វាយប៉ាក ហើយវាជាលទ្ធផលនៃការស៊ើបអង្កេតសំងាត់ដ៏គ្រោះថ្នាក់។ បេសកកម្មទាំងនេះនាំទៅរកការចាប់ខ្លួនអ្នកជួញដូរ និងម្ចាស់បនជាច្រើននាក់ព្រមទាំងបានសង្គ្រោះជនរងគ្រោះជាច្រើនភាគច្រើនក្នុងចំនោមពួកគេ គឺមានអាយុតិចជាង ១៥ ឆ្នាំ។ ជាអកុសល ជនរងគ្រោះជាច្រើនត្រូវបានសង្គ្រោះតាមរយៈការវាយឆ្មក់នេះ (និងជនរងគ្រោះដ៏ទៃទៀត) ថ្មីៗនេះត្រូវបានគេឃើញវិលត្រឡប់

[55] Prak Chan Thul and Ethan Plaut, "German National Is Charged With Debauchery", The Cambodia Daily, Friday, 10 February 2006.

រកបានអតិថិជនល្អៗជាច្រើនជំនួសវិញ។ គោលដៅសំខាន់ៗគឺ សំរាប់អ្នករត់ម៉ូតូឌុប ដើម្បីបញ្ឈប់នូវការជួយដល់ជនទាំងនោះក្នុងការស្វែងរកកុមារដើម្បីរួមភេទ។ បច្ចុប្បន្ននេះមានអ្នករត់ម៉ូតូឌុប ១០២ នាក់ បានចូលរួមក្នុងកម្មវិធីនេះក្នុងក្រុងភ្នំពេញ និង ៥១ នាក់ ក្នុងខេត្តសៀមរាប។ អ្នករត់ម៉ូតូឌុបទាំងនេះពាក់អាវពណ៌ខៀវ ដោយមានសញ្ញាស្នាមមេដៃចង្អុលឡើងលើដ៏ធំមួយ និងពាក្យស្លោក "អតិថិជនល្អ, ការរកស៊ីសុច្ចរិត" ដូច្នេះពួកគេងាយនឹងត្រូវបានគេចំណាំ។ អ្នករត់ម៉ូតូឌុប និងអ្នករត់ម៉ូតូរ៉ឺម៉កកង់បីត្រូវបានគេផ្សព្វផ្សាយតាមអ៊ិនធឺណេត ដោយមានទាំងលេខទំនាក់ទំនងចំពោះអ្នកទាំងឡាយណាដែលមានទូរស័ព្ទ។ ផ្ទះសំណាក់សុវត្ថិភាពកុមារក៏ត្រូវបានផ្សព្វផ្សាយតាមវេបសាយរបស់អង្គការហ្វ្រេនអន្តរជាតិផងដែរ[៥៤]។

អង្គការក្រៅរដ្ឋាភិបាលមួយចំនួនផ្តោតធនធានរបស់ពួកគេលើការអនុវត្តន៏ការស៊ើបអង្កេត។ នៅពេលដែលទិន្នន័យត្រូវបានប្រមូលគ្រប់គ្រាន់ដែលអាចចោទប្រកាន់លើជនសង្ស័យថា បានពាក់ពន្ធ័នឹងបទឧក្រិដ្ឋបាន ហើយពួកគេនឹងបញ្ជូនករណីនេះទៅអោយប៉ូលីស បន្ទាប់មកប៉ូលីសបញ្ជូនទៅតុលាការសំរាប់ចេញដីការចាប់ខ្លួន ហើយគេអាចអនុវត្តតាមដីការចាប់ខ្លួននោះបាន។ អង្គការ APLE មានលក្ខណៈសកម្មណាស់ក្នុងការស៊ើបអង្កេតលើជនល្មើសផ្លូវភេទ ដែលត្រូវបានគេសង្ស័យក្នុងក្រុងភ្នំពេញ ហើយថ្មីៗនេះមានច្រើននៅក្នុងក្រុងព្រះសីហនុ ដោយប្រគល់រឿងក្តីនេះទៅអោយប៉ូលីស បន្ទាប់ពីប្រមូលបានព័ត៌មាន និងនិយាយ

[54] http://www.childsafe-cambodia.org/index.asp



ឱកាសនិយមបានមកប្រទេសកម្ពុជា ដើម្បីស្វែងរកទីកន្លែងដែលពួកគេអាចប្រព្រឹត្តអំពើអស់ទាំងនោះបាន។ កត្តាមួយទៀតដែលត្រូវបានគេលើកយកមកពិចារណានោះគឺ ការធ្លាក់ខ្លួនទៅក្នុងស្ថានភាពអស់សង្ឃឹម ដូច្នេះគ្រួសារជាច្រើនបានលង់ខ្លួនដោយខ្លួនឯងដោយលទ្ធផលមកពីភាពក្រីក្រខ្លាំងពេក។ ក្មេងៗជាច្រើនត្រូវបានបង្ខំខ្លួន ដើម្បីស្វែងរកប្រាក់ចំនូលក្នុងការផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ហើយជារឿយៗបានធ្លាក់ខ្លួនទៅក្នុងឧស្សាហកម្មផ្លូវភេទ។ ករណីផ្សេងពីនេះ ពួកគេអាចត្រូវបានគេបញ្ជូនឱ្យទៅធ្វើការតាមចិញ្ចើមថ្នល់ដូចជា អ្នកខាត់ស្បែកជើង, លក់សៀវភៅ, ឬក៏លក់វត្ថុអនុស្សាវរីយ៍ ឬក៏ជាអ្នកសុំទាន ធ្វើឱ្យពួកគេអាចធ្លាក់ទៅក្នុងស្ថានភាពដែលងាយនឹងរងគ្រោះថ្នាក់។ ហើយវប្បធម៌នៅក្នុងអាស៊ីអាគ្នេយ៍ជាវប្បធម៌មួយដែលមនុស្សចាស់ត្រូវបានគេគោរពយ៉ាងខ្លាំង ក្មេងៗត្រូវបានគេចិញ្ចឹមឱ្យធំជាមួយនឹងការនែនាំថា ពួកគេត្រូវធ្វើអ្វីដូចដែលមនុស្សចាស់បានប្រាប់។ ដោយសារការគោរពតាមដំបូន្មាន និងវប្បធម៌បែបនេះហើយទើបនៅពេលដែលជនបរទេសស្នើសុំអ្វីមួយពីពួកគេពួកគេទំនងជាមិនហ៊ានបដិសេធនោះទេ[១២]។

## ២, ទេសចរណ៍ផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា

យោងតាមគណៈកម្មាធិការលុបបំបាត់អំពើពេស្យាកម្ម, រំលោភ, និងការជួញដូរកុមារអន្តរជាតិទេសចរណ៍ផ្លូវភេទលើកុមារ (CST) អាចត្រូវបានគេឱ្យនិយមន័យថា ជា "របររកស៊ីមួយដោយធ្វើការកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារ

[12] Interview with Béatrice Magnier, Country Director, Action pour les Enfants (APLE); 05 December 2005.

ដោយបុរស រឺស្ត្រី ដែលធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយជាទូទៅពីប្រទេសអ្នកមានទៅកាន់ប្រទេសដែលមិនសូវមានការអភិវឌ្ឍន៍ ហើយនៅប្រទេសនោះពួកគេមានការជាប់ពាក់ពន្ធ័អំពើផ្លូវភេទជាមួយកុមារ ដែលត្រូវបានគេកំណត់ថាជាក្មេងអាយុក្រោម ១៨ ឆ្នាំ"[១៣] ពាក្យថា ទេសចរណ៏ផ្លូវភេទលើកុមារមិនកំណត់ថា ទាល់តែអ្នកណាមួយធ្វើដំណើរឆ្លងកាត់ព្រំដែនប្រទេសមួយទើបហៅថា ជាអ្នកទេសចរណ៏ផ្លូវភេទលើកុមារនោះទេ : អ្នកណាមួយដែលធ្វើដំណើរទៅកាន់ទិសដៅកំសាន្ត រឺក៏ទៅកាន់ទីក្រុងដ៏ទៃទៀត រឺភូមិណាមួយផ្សេងទៀតដែលនៅក្នុងប្រទេសរបស់ខ្លួនដដែល ពួកគេទាំងនោះនៅតែត្រូវបានគេអាចចាត់ទុកថា ជា "អ្នកទេសចរណ៏" សំរាប់គោលបំណងទាំងនេះ គឺជាអ្នកទេសចរណ៏ផ្លូវភេទលើកុមារ ពីព្រោះនៅក្នុងឯកសារនេះគេផ្តោតទៅលើទេសចរណ៏ផ្លូវភេទលើកុមារដូច្នេះគេនឹងមិនមានការវាយតំលៃលំអិតអំពីស្ថានភាពនៃស្ត្រីពេញវ័យ ឬវ័យក្មេង (អាយុ ១៨ ឆ្នាំ ឬ ចាប់ពី ១៨ ឆ្នាំឡើងទៅ) ដែលងាយរងគ្រោះថ្នាក់ដោយសារភ្ញៀវទេសចរណ៏ ដែលមានចិត្តប្ញស្យាក្នុងប្រទេសកម្ពុជានោះទេ។ ក្នុងឯកសារនេះ ពាក្យកុមារ និងពាក្យអនីតិជនត្រូវបានគេប្រើប្រាស់ ដើម្បីបង្ហាញគ្រប់វ័យទាំងអស់ដែលមានអាយុ ១៨ ឆ្នាំ រឺក៏ ក្រោម ១៨ ឆ្នាំ ។

ស្ថានភាពនៃទេសចរណ៏ផ្លូវភេទលើកុមារអាចមានការប្រែប្រួល។ ជនល្មើសផ្សេងៗអាចបង្ហាញនូវចំណង់ចំណូលចិត្តផ្សេងៗ ក៏ប៉ុន្តែភ្ញៀវទេសចរណ៏ជាច្រើនអនុវត្តនូវគំរូស្រដៀងៗគ្នា ដើម្បីស្វែងរកកុមារក្នុងគោលបំណងរួមភេទ។

[13] CSEC Definitions: Commercial Sexual Exploitation of Children (CSEC) at http://www.ecpat.net/eng/CSEC/definitions/csec.htm



ផ្លូវភេទ។ ឥឡូវនេះអ្នកបើកបរទាំងនេះត្រូវបានគេបង្រៀននឹងវាយតំលៃលើសុវត្ថិភាពតាមផ្លូវ ដូច្នេះពួកគេនឹងមានសុវត្ថិភាពបន្ថែមទៀត។ វគ្គបណ្តុះបណ្តាលបានប្រើនូវសេណារយោពិត ដោយមានរឿងពិតដែលទទួលបានពីផ្ទះសំណាក់, អ្នករត់ម៉ូតូឌុប, និងកុមារខ្លួនឯងផ្ទាល់។ សិក្ខាកាមត្រូវបានពន្យល់ថា ការរកស៊ីនូវមុខរបរទុច្ចរិតមិនត្រឹម តែផ្តល់ដល់ពួកគេនូវកេរ្តិ៍ឈ្មោះដ៏អាក្រក់ប៉ុណ្ណោះទេថែមទាំងផ្តល់ដល់ប្រទេសកម្ពុជានូវកេរ្តិ៍ឈ្មោះអាក្រក់នោះផងដែរ។ ពួកគេត្រូវបានប្រាប់អោយទូរស័ព្ទទៅប៉ូលីស រឺអង្គការប្រៀនអន្តរជាតិ ប្រសិនបើពួកគេឃើញនូវការរំលោភ។ អ្នកបើកបរចូលរួមវគ្គបណ្តុះបណ្តាល ៥ ដែលក្នុងមួយវគ្គមានរយៈពេល ២០នាទី ហើយក្រោយមកពួកគេត្រូវធ្វើតេស្ត។ តេស្តនេះនឹងប្រព្រឹត្តទៅមួយសប្តាហ៏ក្រោយពីវគ្គចុងក្រោយដើម្បីឱ្យដឹងថា អ្វីខ្លះដែលពួកគេបានចងចាំពីវគ្គបណ្តុះបណ្តាលនេះ។ សិក្ខាកាមប្រហែលជា ៧0 ភាគរយ បានធ្វើតេស្តជាប់ជាលើកដំបូង។ ដោយសារពួកគេរកលុយបានមកពីការនាំភ្ញៀវទៅរកស្រី រឺផ្ទះបនប្រាក់លើកទឹកចិត្តបន្ទិច បន្តួចត្រូវបានផ្តល់ជូនដើម្បីធានាដល់ការចូលរួមរបស់ពួកគេ និងការយកចិត្តទុកដាក់ក្នុងការរៀនសូត្រក្នុងវគ្គ។ លើសពីនេះទៅទៀតអង្គការក្រៅរដ្ឋាភិបាលនេះព្យាយាមសង្កត់ធ្ងន់ទៅលើនីត្យានុកូលភាព និងសីលធម៌។ សេចក្តីសង្ឃឹមនោះស្ថិតនៅត្រង់ថា អ្នករត់ម៉ូតូឌុបនឹងមានអារម្មណ៏មោទនភាព ដែលបានចូលរួមក្នុងគំនិតផ្តួចផ្តើមបែបនេះ។ លុយដែលពួកគេបាត់បង់ ដោយសារមិនបានសំរបសំរួលទេសចរណ៏ផ្លូវភេទលើកុមារនោះពួកគេនឹងរកបានមកវិញ ដោយការចូលរួមក្នុងកម្មវិធីនេះ ដែលនឹងនាំទៅដល់ការ

ខ្មែរ បន្ទាប់មកជនជាតិតំបន់អាស៊ីដ៏ទៃទៀត ហើយចុងក្រោយគឺពួកបច្ចឹមប្រទេស។ ឥឡូវនេះមានការហោះហើរផ្ទាល់ពីប្រទេសកូរ៉េមកកាន់ខេត្តសៀមរាបថែមទាំងមានភ្ញៀវទេសចរជនជាតិជប៉ុន និងអាមេរិកជាច្រើន។ ខិតប័ណ្ណត្រូវបានចែកចាយនៅព្រលានយន្តហោះ, កន្លែងឆែកឆេរ ១០ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងផ្នែកឯកជនមានសណ្ឋាគារ, ផ្ទះសំណាក់, និងក្រុមហ៊ុនទេសចរណ៍។ តាំងពីអង្គការ AIDéTouS តាមការងារនៅតាមសណ្ឋាគារ ក្នុងក្រុងភ្នំពេញដើម្បីផ្ទៀងផ្ទាត់ថាតើពួកគេនៅតែមានខិតប័ណ្ណដាក់តាំងដែររឺទេ មកគេឃើញថា សណ្ឋាគារភាគច្រើននៅតែមានខិតប័ណ្ណអប់រំទាំងនោះ។ ក្នុងពេលអនាគតអង្គការ AIDéTouS ចង់ផលិតខិតប័ណ្ណ ដែលមានកាន់តែច្រើនភាសាបន្ថែមទៀត (ជាពិសេសភាសាក្នុងតំបន់អាស៊ីអោយបានច្រើន)។ ការអង្កេតមួយបានធ្វើឡើងក្នុងឆ្នាំ ២០០២ ក្នុងចំណោមអ្នករកស៊ីផ្លូវភេទក្នុងក្រុងភ្នំពេញ និងក្រុងសៀមរាបបានឃើញថា ជនជាតិភាគច្រើននៃអតិថិជនចុងក្រោយរបស់ពួកគេគឺ ជនជាតិជប៉ុន, អាមេរិក, និង បារាំង។

អង្គការហ្វ្រេនអន្តរជាតិ គឺជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិកំពុងធ្វើការនៅប្រទេសកម្ពុជា, ឡាវ, ភូមា, ថៃ, និងហុងឌូរ៉ាស។ ឆ្នាំ ២០០៥ កម្មវិធីសុវត្ថិភាពកុមារកម្ពុជា ត្រូវបានធ្វើឡើងនៅក្រុងភ្នំពេញ ហើយក៏កំពុងដំណើរការក្នុងខេត្តសៀមរាបរហូតដល់ឥឡូវនេះ។ គំនិតផ្តួចផ្តើមនេះមានទិសដៅចំពោះអ្នករត់ម៉ូតូឌុប និងម៉ូតូរ៉ឺម៉កកង់បី។ កម្មវិធីនេះក៏ធ្វើការងារពាក់ព័ន្ធនឹងការបណ្តុះបណ្តាលពួកគេអំពីសិទ្ធិកុមារ និងពន្យល់អំពីឥទ្ធិពលដ៏គ្រោះថ្នាក់នៃទេសចរណ៍



ភ្ញៀវទេសចរផ្លូវភេទមានស្ថានភាព/ប្រវត្តិខុសៗគ្នា និងមកពីតំបន់ផ្សេងៗទូទាំងពិភពលោក។ អ្នកខ្លះធ្វើដំណើរមកប្រទេសកម្ពុជា ដែលមានបំណងតែមួយគត់គឺសកម្មភាពផ្លូវភេទជាមួយនឹងអនីតិជន អ្នកខ្លះមានបំណងមកទីនេះគ្រាន់តែជាការរកស៊ីប៉ុណ្ណោះ ហើយអ្នកខ្លះទៀតគ្រាន់តែឆ្លៀតឱកាសដើម្បីរួមភេទជាមួយនឹងអនីតិជនតែប៉ុណ្ណោះ នៅពេលដែលឱកាសហុចឱ្យហើយនោះ។ ប៉ុន្តែភ្ញៀវទេសចរផ្លូវភេទភាគច្រើនមិនបានមកប្រទេសកម្ពុជា ដោយមានគោលបំណងពាក់ពន្ធ័នឹងសកម្មភាពផ្លូវភេទជាមួយនឹងអនីតិជនជាចាំបាច់នោះទេ។ ចំនួនអ្នកទេសចរដ៏គួរឱ្យកត់សំគាល់នៅថ្ងៃឈប់សំរាក ដែលបានឃ្លាតឆ្ងាយពីក្រុមគ្រួសាររបស់ពួកគេ ត្រូវបានទាក់ទាញចិត្តដោយការផ្តល់នូវកុមារក្មេងៗត្រៀមជាស្រេចដើម្បីកំដរពួកគេទៅកាន់សណ្ឋាគារ រឺក៏ផ្ទះសំណាក់ដោយមានតំលៃថោក។ អត្តចរិតឱកាសនិយមបែបនេះត្រូវបានផ្តល់កំលាំងចិត្ត ពីព្រោះពួកគេដឹងថា ករណីចាប់ខ្លួនក្នុងការប្រព្រឹត្តបែបនេះមិនសូវកើតមាននោះទេ ហើយក្នុងករណីបែបនេះការអនុវត្តន៏ច្បាប់ក៏មានភាពទន់ខ្សោយ។ បញ្ហានេះត្រូវបានគេចាត់ទុកជាភ្ញៀវទេសចរផ្លូវភេទឱកាសនិយមៈ ពួកគេមិនចាកចេញពីស្រុកកំណើតក្នុងគោលបំណងរួមភេទជាមួយកុមារនោះទេ ប៉ុន្តែនៅពេលដែលឱកាសមកដល់ពួកគេក៏ចាប់យកភ្លាម។ វាហាក់បីដូចជាមានការទំនាក់ទំនងគ្នាខ្លះរវាងពេស្យាកម្មមនុស្សពេញវ័យ ហើយនឹងកុមារ។ ជនល្មើស "ឱកាសនិយម" ចាប់ផ្តើមដោយស្វែងរកអ្នករកស៊ីផ្លូវភេទពេញវ័យ ហើយបន្ទាប់មកដោយសារតែវាមានតំលៃថោកពេក ហើយអាចរកបានពួកគេក៏បានប្រព្រឹត្តសកម្មភាពផ្លូវភេទជាមួយនឹងអនីតិជនតែម្តងទៅ។ មនុស្ស

ខ្លះមិនខ្វល់ថា តើស្ត្រីរកស៊ីផ្លូវភេទនោះអាយុប៉ុន្មាន រឺក៏ជាធម្មតាពួកគេជឿជាក់ទៅលើអាយុដែលកុមារបានប្រាប់ដល់ពួកគេ (ទោះបីជាអាយុនោះមិនគួរឱ្យជឿយ៉ាងណាក៏ដោយ)។

គេអាចបែងចែកផ្សេងគ្នារវាងភ្ញៀវទេសចរឱកាសនិយម ហើយនឹងជនប្រព្រឹត្តអនាចារលើកុមារ។ ជនប្រព្រឹត្តអនាចារលើកុមារបានបង្ហាញនូវលក្ខណៈពិសេសមួយចំនួនដែលត្រូវបានគេចំណាំជាទូទៅ ព្រោះវាជាលក្ខណៈដោយឡែកពីគេដែលមាននៅក្នុងចំណោមបុរស ឬ (ស្ត្រី) ទាំងនេះ។ លក្ខណៈទាំងអស់នេះរួមទាំងចំណង់ចំណូលចិត្តក្នុងការបំពេញបំណងកាមគុណចំពោះកុមារក្មេងៗ, កលល្បិចដ៏ប៉ិនប្រសព្វក្នុងការលួងលោមជនរងគ្រោះរបស់ពួកគេ, និងការរួមភេទដ៏ចម្លែកៗជាមួយកុមារក្មេងៗ[១៤]។ លក្ខណៈពិសេសដ៏ទៃទៀតដែលគេបានសង្កេតឃើញនៅក្នុងចំណោមក្រុមនោះ គឺស្ថិតនៅត្រង់ថា ពួកគេបានថតរូបជនរងគ្រោះដែលជាកុមារ គឺរូបថតអាសអាភាសមិនគប្បី ហើយជួនកាលជនប្រព្រឹត្តអនាចារលើកុមារនោះក៏មានជាមួយនឹងកុមាររងគ្រោះនោះផងដែរ។ រូបភាពទាំងអស់នេះគេអាចយកមកប្រើប្រាស់សំរាប់ផ្ទាល់ខ្លួន, ការលក់ដូរ រឺក៏ចែកចាយក្នុងចំណោមបណ្តាញអានាចារលើកុមារ រឺសំរាប់គោលបំណងជាច្រើនដ៏ទៃទៀត។ ជនប្រព្រឹត្តអនាចារលើកុមារអាចជាបុរស ពេញវ័យដែលស្វែងរកសកម្មភាពផ្លូវភេទជាមួយក្មេងប្រុស រឺក៏ក្មេងស្រី ជាពិសេសដែលមានអាយុ ១២ ឆ្នាំ រឺក៏ក្មេងជាងនេះ។

[14] Grillot, Caroline for Action pour les Enfants (APLE), *"Street Paedophilia" in Cambodia – A Survey on Phnom Penh's suspects and victims*, sponsored by the British Embassy in Cambodia, September 2005 quoting from Understanding and Investigating Child Sexual Exploitation, Law Enforcement Against Sexual Exploitation of Children Project, Ministry of Interior, General Direction of National Police, Kingdom of Cambodia, Phnom Penh, 2000.



យុទ្ធនាការការពារថ្នាក់ជាតិមួយក្នុងខែមករា ឆ្នាំ ២០០៥។ គេបានបញ្ចាំងវីដេអូដែលបានបង្ហាញនូវចំណុចពិសេស និងទិដ្ឋភាពសំខាន់ៗនៅច្រកធ្វើដំណើរអន្តរជាតិក្នុងក្រុងភ្នំពេញ និងខេត្តសៀមរាប។ ខ្សែភាពយន្តនោះមានពីរ ផ្នែក : ទី១ គឺការផ្សព្វផ្សាយពាណិជ្ជកម្មដែលបង្ហាញនូវអ្វីដែលមានសោភ័ណភាពដែលអាចទាក់ទាញភ្ញៀវទេសចរក្នុងប្រទេសកម្ពុជា ហើយបន្ទាប់មកបានបង្ហាញពីបុរសម្នាក់ដែលត្រូវបានគេឃើញកំពុងលួងលោមកុមារដើម្បីក្នុងគោលបំណងរំលោភផ្លូវភេទ។ សំរាប់ភ្ញៀវទេសចរជាច្រើនដែលបានចូលមកដល់ក្រុងភ្នំពេញ រឺសៀមរាបនេះគឺ ជារឿងដំបូងដែលពួកគេបានឃើញ។ ដូច្នេះវាពិបាកថា ឬមិនជឿថា មិនបានឃើញនូវផ្ទាំងទស្សនីយភាពនោះឡើយ។ ខ្សែភាពយន្តការពារបែបនេះត្រូវបានគេដាក់បញ្ចាំងតាមការធ្វើដំណើររវាងប្រទេសថៃ និងកម្ពុជា។

AIDéTouS ក៏បានផលិតខិតប័ណ្ណ ៥០ ០០០ សន្លឹក ដោយមានដាក់អក្សរមួយឃ្លាថា "ការរំលោភកុមារនឹងធ្វើអោយខូចអនាគតរបស់កុមារ ហើយវានឹងធ្វើឱ្យខូចអនាគតរបស់អ្នកដែរ" ដោយនៅខាងក្រោម មានរូបភាពបុរសម្នាក់ដែលដើរចេញទៅជាមួយកុមារ និងអក្សរមួយឃ្លាទៀតនៅខាងក្រោមរូបភាពសរសេរថា "ការរំលោភកុមារនឹងនាំអោយជាប់ពន្ធនាគារអាចរហូតដល់រយៈពេល ៣០ ឆ្នាំ"។ លេខ Hotline របស់ក្រសួងមហាផ្ទៃគឺ នៅផ្នែកម្ខាងទៀត។ ខិតប័ណ្ណនោះមានសរសេរអក្សរប្រាំភាសា : អង់គ្លេស, ខ្មែរ, បារាំង, អាឡឺម៉ង់, ចិន, និងជប៉ុន។ គោលបំណងនេះគឺ ផ្តោតទិសដៅទៅលើជនល្មើសផ្លូវភេទលើកុមារសំខាន់ៗ ដូច្នេះជំរើសនៃភាសាទាំងនោះអាចឱ្យពួកគេយល់បាន។ ភាគច្រើនគឺជាជនជាតិ

ប៉ូលិសបានវាយឆ្មក់ពិភពលោកមួយក្នុងឆ្នាំ ២០០៥ លទ្ធផលនាំមកនូវការបិទនៃកន្លែងម៉ាស្សានោះ ហើយមានការចាប់ខ្លួនជាច្រើន និងរំដោះបានស្ត្រី ៨៨ នាក់។ បុគ្គលិក ៣ នាក់ ព្រមទាំងថៅកែនៃកន្លែងម៉ាស្សានោះ ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើអបាយមុខ។ ការចោទប្រកាន់ដែលពាក់ព័ន្ធនឹងបុគ្គលិក ៣ នាក់ ត្រូវបានច្រានចោល ហើយវាមិនទាន់ច្បាស់ថា តើការចោទប្រកាន់នោះនៅតែធ្វើឡើងប្រឆាំងនឹងថៅកែដែរឬទេ[៥៣]។ លទ្ធផលប្រភេទនេះនឹងធ្វើអោយប្រជាជនមិនសូវមានការទុកចិត្តជាមួយនឹងប៉ូលិស និងតុលាការ។ ក្រោយពីបិទអស់រយៈពេល ៦ ខែ ឥឡូវនេះកន្លែងនោះត្រូវបានបើករកស៊ីសារជាថ្មីទៀត។ ស្ត្រីក្មេងៗស្លៀកពាក់យ៉ាងប៉ផិតប៉ផើយត្រូវបានគេឃើញនៅកន្លែងនោះ។

## ៤.២ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ

សព្វថ្ងៃនេះ ចំនួនអង្គការដែលធ្វើការងារជាក់លាក់លើបញ្ហាផ្លូវភេទលើកុមារមានចំនួនច្រើនជាងមុន។ យុទ្ធនាការត្រូវបានគេចាប់ផ្តើមឡើងវិធីសាស្ត្រថ្មីៗត្រូវបានគេអនុវត្ត និងមនុស្សដែលត្រូវបានគេបំភ្លេចពីមុននោះ ឥឡូវនេះកំពុងត្រូវបានគេដាក់ទិសដៅនឹងត្រូវបានគេបញ្ចូលអោយពាក់ព័ន្ធទៅនឹងកិច្ចប្រឹងប្រែងដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។ អង្គការក្រៅរដ្ឋាភិបាលរបស់បារាំង AIDéTouS សហការគ្នាជាមួយអ្នកពាក់ព័ន្ធសាធារណៈ និងផ្នែកឯកជនរួមមាន សមាគមសណ្ឋាគារ និងផ្ទះសំណាក់។ អង្គការក្រៅរដ្ឋាភិបាលនេះបានធ្វើ

[៥៣] The Cambodia Daily, "*Raided, Closed Massage Parlour Back in Business*", Wednesday February $22^{nd}$, 2006; p. 17.



ជនប្រព្រឹត្តអនាចារលើកុមារមួយចំនួននៅលីវ, ខ្លះទៀតមានគ្រួសារហើយ, អ្នកខ្លះបានអះអាងថា ពួកគេស្រលាញ់ជនរងគ្រោះដែលជាកុមារផ្ទាល់តែម្តង។ អ្នកខ្លះទៀត "នៅក្នុងបរិបទឧបាយកលបោកបញ្ឆោតឱ្យជឿទុកចិត្ត" ជឿថា ទៅបរទេសដើម្បីប្រព្រឹត្តការរំលោភបំពានលើផ្លូវភេទលើកុមារ គឺជាការប្រព្រឹត្តិដែលអាចទទួលយកបានហើយថា ការពិតពួកគេកំពុងជួយប្រជាជនក្រីក្រ ដើម្បីពួកគេអាចជួយផ្គត់ផ្គង់គ្រួសាររបស់ពួកគេបាន។[១៥]

ជនល្មើសផ្លូវភេទទាំងនេះអាចជាភ្ញៀវទេសចរណ៍ (ជាលើកដំបូង រឺក៏អ្នកចេញចូលប្រក្រតីធម្មតា) រឺក៏ជាជនបរទេសដែលមានទីលំនៅក្នុងប្រទេសកម្ពុជា។ ជនល្មើសមួយចំនួនទៀតកំពុងរស់នៅក្នុងទីក្រុងបាងកក ហើយបានចេញចូលប្រទេសកម្ពុជាជាប្រក្រតី ពួកគេដឹងថានរណាខ្លះដែលត្រូវនិយាយជាមួយ, និងកន្លែងដែលត្រូវទៅ ពួកគេចាត់ចែងឱ្យគេយកក្មេងស្រីទៅអោយពួកគេ ហើយពួកគេបានចាកចេញពីប្រទេសមុនពេលដែលគេមានការសង្ស័យដល់ពួកគេ។ អាយុមធ្យមនៃជនល្មើសដែលត្រូវបានចាប់ខ្លួនគឺអាយុ ៤៥ឆ្នាំ។ លទ្ធផលនៃការចាប់ខ្លួនថ្មីៗនៅក្នុង ខែធ្នូ ឆ្នាំ២០០៥ នេះ គឺបានមកពីការស៊ើបអង្កេតរបស់អង្គការ (APLE) លើការពាក់ព័ន្ធរបស់ជនអូស្ត្រាលីម្នាក់ដែលមានអាយុ ២៦ឆ្នាំ ដែលកំពុងរស់នៅក្នុងទីក្រុងភ្នំពេញអស់រយៈពេលប៉ុន្មានខែកន្លងមកហើយ។ កុមារ ៦ នាក់ ដែលមានអាយុចន្លោះពី ១១ និង ១៤ឆ្នាំ បានអះអាងថា ពួកគេត្រូវបានរំលោភដោយបុរសជនជាតិអូស្ត្រាលីនោះ ហើយកុមារទី៧ ក៏បានធ្វើជាសាក្សី

[15] Grillot, Caroline for Action pour les Enfants (APLE), *"Street Paedophilia" in Cambodia – A Survey on Phnom Penh's suspects and victims*, sponsored by the British Embassy in Cambodia, September 2005; p. 12.

ចំពោះហេតុការរំលោភនោះដែរ។ ជនជាតិអូស្ត្រាលីនោះបានសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តទុច្ចរិតពិតប្រាកដមែន។[១៦]

## ២.១. សញ្ជាតិ

ការប្រៀបធៀប ឆ្នាំ ២០០៤ និង ២០០៥ ប្រទេសនៃភ្ញៀវទេសចរដែលមកប្រទេសកម្ពុជាជាប្រក្រតីមានការខុសប្លែកគ្នាបន្តិចបន្តួច។ តាមពិតទៅជនជាតិ ៣ ដែលមកប្រទេសកម្ពុជាញឹកញាប់បំផុតនោះ គឺ ដូចគ្នានៅក្នុងឆ្នាំទាំងពីរនោះដែរ។ កូរ៉េខាងត្បូង គឺជាប្រទេសដែលប្រជាជនរបស់ពួកគេមកកម្ពុជាញឹកញាប់បំផុត បន្ទាប់មកទៀតគឺ ប្រទេសជប៉ុនហើយប្រទេសដែលជាប់ចំណាត់ទីពាក្នុងចំណោមប្រទេស ដែលមានភ្ញៀវទេសចរច្រើនបំផុតមកកាន់ប្រទេសកម្ពុជានោះ គឺជនជាតិអាមេរិក។ ប្រទេសបារាំង គឺជាប្រទេស ទី៤ ហើយប្រទេសអង់គ្លេស គឺជាប្រទេស ទី៥ ក្នុងឆ្នាំ ២០០៤ ប៉ុន្តែឆ្នាំ ២០០៥ ភ្ញៀវទេសចរមកពីប្រទេសអង់គ្លេសច្រើនជាង ភ្ញៀវមកពីប្រទេសបារាំង[១៧] ។

វាមិនមានការជាប់ទាក់ទងផ្ទាល់ រវាងប្រទេសដើមរបស់ភ្ញៀវទេសចរ ហើយនឹងគោលបំណងរបស់ពួកគេក្នុងសកម្មភាពផ្លូវភេទជាមួយកុមារក្មេងៗនោះទេ។ ភ្ញៀវទេសចរផ្លូវភេទខ្លះគឺ ជនជាតិកម្ពុជានៅប្រទេសកម្ពុជាតែម្តង, ភ្ញៀវទេសចរផ្លូវភេទខ្លះទៀតធ្វើដំណើរមកពីបណ្តាប្រទេសនៅទ្វីបអាស៊ីនេះឯង, ហើយនឹងខ្លះទៀតមកពីខាងបច្ចឹមប្រទេស។ ប្រទេសនៃជនល្មើសផ្លូវភេទលើកុមារក្នុង

[16] APLE Press Release, Phnom Penh; December 14, 2005.

[17] Comparing ‘Top 10 Market Arrivals to Cambodia from Jan-Dec 2004’ and ‘Top 10 Market Arrivals to Cambodia from Jan-Sept 2005’ obtained from the Ministry of Tourism (MoT).



ក្រសួងមហាផ្ទៃ, ស្នងការរាជធានីភ្នំពេញ បានចេញសេចក្តីណែនាំចំពោះម្ចាស់ក្លឹប, បារ, សណ្ឋាគារ, និងផ្ទះសំណាក់ដែលមានសិទ្ធិចុះបញ្ជីវត្តមានអំពី (របាយការណ៏វត្តមាននៃជនបរទេស)។ ម្ចាស់នៃស្ថាប័នបែបនេះត្រូវផ្តល់នូវព័ត៌មានមួយចំនួនអំពីភ្ញៀវអោយទៅប៉ូលីសជារៀងរាល់ថ្ងៃ : ឈ្មោះ, ភេទ, សញ្ជាតិ, មុខរបរ, លេខលិខិតឆ្លងដែន, ថ្ងៃផុតកំណត់ទិដ្ឋាការ, ថ្ងៃចេញ-ចូល, និងរយៈពេលនៃការស្នាក់នៅ។ ប្រសិនបើមិនបានរាយការណ៏ទេនោះម្ចាស់ស្ថាប័ននឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ ជាមួយនឹងគំនិតផ្តួចផ្តើមដែលកំពុងអនុវត្តប្រភេទនេះអាជ្ញាធរមូលដ្ឋាននឹងមានឯកសារទាំងអស់នេះ ហើយមានលទ្ធភាពរក្សាឯកសារដែលទាក់ទងនឹងភ្ញៀវទេសចរទាំងអស់ ដែលធ្វើដំណើរឆ្លងកាត់រាជធានីភ្នំពេញ។ កិច្ចការនេះសង្ឃឹមថា នឹងធ្វើឱ្យដំណើរការស៊ើបអង្កេតបានប្រព្រឹត្តទៅយ៉ាងឆាប់រហ័ស យ៉ាងហោចណាស់សំរាប់ភ្ញៀវទេសចរដែលធ្លាប់បានប្រព្រឹត្តបទល្មើសរំលោភផ្លូវភេទជាមួយអនីតិជនកន្លងមក។ គំនិតផ្តួចផ្តើមនេះគួរតែត្រូវបានអនុវត្តឱ្យបានគ្រប់ខេត្តទាំងអស់។ ព័ត៌មានដែលពាក់ពន្ធ័នឹងឥទ្ធិពលនៃវិធានការនេះគួរតែត្រូវបានប្រមូលឱ្យបានកាន់តែច្រើនថែមទៀត : តើព័ត៌មាននេះត្រូវបានកត់ត្រា/ចំលងត្រឹមត្រូវ និងរក្សាទុកត្រឹមត្រូវដែររឺទេ? តើវិធានការនេះត្រូវបានអនុវត្តដោយរបៀបណា ?

អាជ្ញាធរកម្ពុជាបានបិទនូវកន្លែងមួយចំនួនជាបណ្តោះអាសន្ន ដោយសារមានការពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ : ឆាយហ្វូរពីរ (II), ពិភពលោកមួយ (កន្លែងម៉ាស្សា), និងសុខសាន្ត (ក្លឹបកំសាន្តក្នុងខេត្តសៀមរាប)។

រូបភាពផ្សាយពាណិជ្ជកម្មធំៗដែលមានសារបែបនេះ ក៏អាចជួយដល់កិច្ចប្រឹងប្រែងដែលកំពុងតែអនុវត្តដែរ។ នាយកដ្ឋានទេសចរណ៏បានជូនដំណឹងដល់ភ្នាក់ងារទេសចរណ៏ថា ប្រសិនបើពួកគេត្រូវបានរកឃើញថា មានពាក់ព័ន្ធក្នុងបញ្ហាទេសចរណ៏ផ្លូវភេទលើកុមារពួកគេនឹងបាត់បង់នូវអជ្ញាប័ណ្ណជាបណ្តោះអាសន្ន។

នាយកដ្ឋានទេសចរណ៏ក្រុងព្រះសីហនុ ក៏បានសហការជាមួយអង្គការ ILO /IPEC ក្នុងការអនុវត្តន៏ គំរោងដែលបានពិពណ៌នាខាងលើដែលមានរយៈពេល ១៦ ខែ។ គោលបំណងនោះដើម្បីអប់រំដល់សាធារណៈជនអំពីភ្ញៀវទេសចរហើយក្រុមគោលដៅគឺ មានម្ចាស់សណ្ឋាគារ, ផ្ទះសំណាក់, និងភោជនីយដ្ឋានព្រមទាំងអ្នករត់ម៉ូតូឌុប និងអ្នករត់តាក់ស៊ី។ ម្ចាស់សណ្ឋាគារ និងផ្ទះសំណាក់ប្រហែល ៥0 នាក់ នឹងត្រូវបានអញ្ជើញចូលរួម។ ជាអកុសល មូលនិធិបច្ចុប្បន្នមិនគ្រប់គ្រាន់ ដើម្បីអញ្ជើញមនុស្សអោយបានច្រើនចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះទេ។ ជនទាំង ៥0 នេះ នឹងត្រូវបានជ្រើសរើសមកពីកន្លែងរកស៊ីដែលងាយទទួលរងគ្រោះថ្នាក់បំផុត (កន្លែងទាំងនោះកំពុងប្រឈមមុខជាមួយនឹងបញ្ហាដែលពាក់ព័ន្ធទេសចរណ៏ផ្លូវភេទលើកុមារ)។ ប្រសិនបើការខ្វះខាតត្រូវបានគេរកឃើញវីសេចក្តីត្រូវការផ្សេងៗទៀតត្រូវបានរកឃើញបញ្ហាទាំងអស់នេះនឹងអាចត្រូវបានគេយកមកកែតំរូវឱ្យបានសមស្របនៅក្នុងតំណាក់កាលបន្ទាប់ទៀតនៃផែនការនេះ។

អ្នកអនុវត្តច្បាប់ក៏កាន់តែសកម្មថែមទៀត ក្នុងការទប់ស្កាត់ទេសចរណ៏ផ្លូវភេទលើកុមារ។ ក្នុងខែសីហា ឆ្នាំ ២00៥ អគ្គស្នងការនគរបាលជាតិរបស់



ប្រទេសកម្ពុជា ដែលត្រូវបានគេកត់ត្រានៅក្នុងឯកសារមានដូចជា Australia, Belgium, Canada, China, France, Germany, Korea, Japan, The Netherlands, New Zealand, Switzerland, the UK, និង US។ ប្រជាជននៃប្រទេសទាំងនេះមកប្រទេសកម្ពុជា ហើយជាប់ពាក់ព័ន្ធនឹងសកម្មផ្លូវភេទជាមួយអនីតិជន។ តាំងពីអង្គការ APLE ត្រូវបានបង្កើតឡើង ដែលជាអង្គការក្រៅរដ្ឋាភិបាលរបស់បារាំង បានជួយធ្វើការស៊ើបអង្កេតដែលឈានទៅរកការចាប់ខ្លួនជនសង្ស័យថា ជាភ្ញៀវទេសចរផ្លូវភេទចំនួន២៣នាក់។ ក្នុងចំណោមពួកគេទាំងអស់នោះមានជនសង្ស័យ ៦នាក់ មកពីសហរដ្ឋអាមេរិក, មាន ៤នាក់ជាពលរដ្ឋបារាំង, ៤នាក់ ជាជនជាតិហូឡង់, ២នាក់ ជាជនជាតិអូស្ត្រាលី, ២នាក់ជាជនជាតិអូទ្រីស, ១ នាក់ ជាជនជាតិបែលស៊្សិក, ១នាក់ ជាជនជាតិកាណាដា, ១នាក់ ជាជនជាតិញូហ្ស៊ីឡែន, ហើយជនសង្ស័យ ២នាក់ ទៀតមកពីប្រទេសអង់គ្លេស។

ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសបរទេសអាចមានភាគរយនៃជនល្មើសផ្លូវភេទតិចតួចក្នុងប្រទេសកម្ពុជា។ ការហៅទៅកាន់ Hotline ដែលត្រូវបានបង្កើតឡើងដោយក្រសួងមហាផ្ទៃបានរាយការណ៏ថា មានជនសង្ស័យក្នុងស្រុកជាច្រើន[១៨]។ បញ្ហានេះមិនអាចឆ្លុះបញ្ចាំងនៅស្ថានភាពពិត ព្រោះអ្នកត្រូវបានគេសំភាសជាច្រើនបានអះអាងថា មិនអាចទាក់ទងតាម Hotline ជាមួយនឹងអ្នកដែលនិយាយភាសាអង់គ្លេសបានទេ។ (អ្នកស្រាវជ្រាវបានហៅលេខ Hotline ២ដង ប៉ុន្តែគ្មាននរណាលើក និងលើកទី៣ មានគេលើក ប៉ុន្តែអត់មានការឆ្លើយ

[18] Interview with Béatrice Magnier, Country Director, Action pour les Enfants (APLE); 05 December 2005.

តប នៅពេលដែលត្រូវបានគេសុំនិយាយជាមួយនឹងអ្នកនិយាយភាសាអង់គ្លេស) ។ ទោះបីជាយ៉ាងណាក៏ដោយរឿងពិតស្ថិតនៅត្រង់ថា តំរូវការភាគច្រើន គឺមកពីប្រជាជនខ្មែរ ហើយជនបរទេសភាគច្រើនពាក់ព័ន្ធទៅនឹងទេសចរណ៏ផ្លូវភេទនោះមានដូចជាជនជាតិកូរ៉េ, ជប៉ុន, និង ចិន ហើយភ្ញៀវទេសចរផ្លូវភេទខាងបច្ចឹមទទួលបានទទួលការចាប់អារម្មណ៏យ៉ាងខ្លាំងបំផុតពីសារព័ត៌មាន[19] ។

ជាធម្មតា នគរបាលទទួលព័ត៌មានពីអង្គការក្រៅរដ្ឋាភិបាលដែលជាអ្នកផ្តល់ឱ្យពួកគេដើម្បីចុះចាប់ ។ ចំពោះការងារស៊ើបអង្កេតរកជនដែលប្រព្រឹត្តអំពើគួរឱ្យសង្ស័យនោះ គឺការងារស៊ើបអង្កេតដែលធ្វើទៅលើពួកបច្ចឹមប្រទេសនោះគឺវាមានភាពងាយស្រួលជាងការងារស៊ើបអង្កេតដែលធ្វើទៅលើពួកបូព៌ាប្រទេស ព្រោះក្នុងចំណោមមនុស្សម្នាជាច្រើនពួកបច្ចឹមប្រទេស និងការប្រព្រឹត្តិរបស់ពួកគេ គឺលេចធ្លោជាងគេធ្វើឱ្យយើងងាយចំណាំ និងកត់សំគាល់ ។ លើសពីនេះទៅទៀតនិន្នាការនៃការប្រព្រឹត្តិរបស់ពួកបច្ចឹមប្រទេសគឺមិនបានរៀបចំ ហើយធ្វើរបៀបត្រង់ៗ ដែលជាហេតុធ្វើអោយគេងាយរកឃើញនូវការប្រព្រឹត្តិខុស ឬការប្រព្រឹត្តិដែលគួឱ្យសង្ស័យរបស់ពួកគេនោះ ។ ជនល្មើសផ្លូវភេទដែលបានរៀបចំល្អគឺមិនត្រូវបានគេចាប់ខ្លួនបានឡើយ ហើយប្រហែលជាពួកគេមិនស្ថិតនៅក្នុងប្រទេសនេះយូររហូតទាល់ធ្វើឱ្យគេសង្ស័យ ហើយឈានទៅដល់ការចាប់ខ្លួននោះទេ[20] ។ យោងទៅលើអង្គការទស្សនៈពិភពលោកកម្ពុជា ដែលកំពុងធ្វើការលើទេសចរណ៏

[19] Grillot, Caroline for Action pour les Enfants (APLE), *"Street Paedophilia" in Cambodia – A Survey on Phnom Penh's suspects and victims*, sponsored by the British Embassy in Cambodia, September 2005. See also United States Embassy Stockholm, *World Congress Against the Commercial Sexual Exploitation of Children, Feature 3:Cambodia*, August 27-31, 1996.

[20] Interview with Mr. Christian Guth, Law Enforcement Advisor, LEASEC Project, Ministry of Interior; 05 December 2005.



ចំពោះនិយោជកពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការកេងប្រវ័ញ្ចផ្លូវភេទលើនិយោជិកនិងត្រូវបង្រៀននិយោជិតឱ្យដឹងថា តើភ្ញៀវទេសចរមួយណាដែលលែងមានការចាប់អារម្មណ៏, តើត្រូវប្រើល្បិចអ្វី, និងរបៀបការពារខ្លួនមិនឱ្យធ្លាក់ខ្លួនចូលក្នុងការកេងប្រវ័ញ្ចផ្លូវភេទបានដោយរបៀបណា ។ ជាបន្តបន្ទាប់នឹងមានវគ្គបណ្តុះបណ្តាលបន្ថែមសំរាប់និយោជិតចំនួន ២០០នាក់ ក្នុងផ្នែកសណ្ឋាគារ ។ ក្នុងខែសីហា ឆ្នាំ ២០០៦ បុគ្គលិកផ្ទះសំណាក់នឹងទទួលបានការបណ្តុះបណ្តាល ហើយខែកញ្ញា ឆ្នាំ ២០០៦ បុគ្គលិកភោជនីយដ្ឋាន ២០០នាក់ បន្ថែមទៀតនឹងបានទទួលការបណ្តុះបណ្តាល ។ នាយកដ្ឋានទេសចរណ៏ខេត្តសៀមរាប ក៏មានផែនការផ្តល់វគ្គបណ្តុះបណ្តាលសំរាប់អ្នកនាំភ្ញៀវទេសចរណ៏ ដើម្បីបញ្ជ្រាបចូលការយល់ដឹងអំពីការប្រឆាំងនឹងការជួញដូរកុមារទៅក្នុងពួកគេ ។ គេមានគំរោងផងដែរក្នុងការចែកចាយអាវយឺតដោយមានដាក់ពាក្យស្លោក ដែលទាក់ទងនឹងការប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទសំរាប់ឱ្យប្រជាជនពាក់ជុំវិញទីរួមខេត្ត ។ លើសពីនេះទៅទៀត ផ្ទាំងរូបភាពនៅតែត្រូវបានឱ្យដាក់នៅក្នុងសណ្ឋាគារ, និងផ្ទះសំណាក់, ខិតប័ណ្ណតូចៗត្រូវផ្តល់ឱ្យភ្ញៀវទេសចរណ៏ទាំងអស់ ដែលសួររកព័ត៌មាននៅការិយាល័យទេសចរណ៏ ហើយស្លាកបិទ (ស្ទិកឃ័រ) ត្រូវតែចែកចាយទៅអោយអ្នករត់តាក់ស៊ី ឬអ្នករត់ម៉ូតូឌុប ។ ការផ្សព្វផ្សាយមានដូចជា ផ្ទាំងរូបភាព និងស្លាកបិទ (ស្ទិឃ័រ) គឺមានប្រសិទ្ធិភាពបំផុត ។ នៅពេលដែលប្រជាជនបានដឹងច្បាស់ថា ក្រៅពីការប្រព្រឹត្តផ្លូវភេទលើអនីតិជនការគ្រាន់តែបង្ហាញភ្ញៀវទេសចរនូវកន្លែង ឬរបៀបរកស្រីក៏ខុសដែរនោះពួកគេនឹងឈប់ធ្វើរបៀបនេះទៀត ។ ផ្ទាំងរូបភាព និងផ្ទាំង

គំរោងមួយត្រូវបានផ្តួចផ្តើមឡើងដោយ ILO/IPEC-TICW និងក្រសួងទេសចរណ៍ ដើម្បីអភិវឌ្ឍនូវផែនការយុទ្ធសាស្ត្រ, មគ្គុទ្ទេសន៍ប្រតិបត្តិការ, និងសៀវភៅនិយាយអំពីរបៀបបណ្តុះបណ្តាលដើម្បីលើកកំពស់ទេសចរណ៍សុវត្ថិភាពកុមារឱ្យប្រសើរឡើងនៅក្នុងប្រទេសកម្ពុជា : គំរោងនេះបង្កើនអោយមានភាពប្រសើរឡើងដល់គោលការណ៍ និងកម្មវិធីទេសចរណ៍សុវត្ថិភាពកុមារដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីក្នុងផ្នែកទេសចរណ៍នៅថ្នាក់ជាតិ និងខេត្តបី (ភ្នំពេញ, សៀមរាប, និងក្រុងព្រះសីហនុ)។ នាយកដ្ឋានទេសចរណ៍ខេត្តសៀមរាបកំពុងសហការជាមួយអង្គការ ILO-IPEC លើគំរោងមួយដែលបានចាប់ផ្តើមក្នុងខែតុលា ឆ្នាំ ២០០៥ នឹងបន្តរហូតដល់ខែមករា ឆ្នាំ ២០០៧ ដែលមានឈ្មោះថា "ភាពរីកចំរើននៃសុវត្ថិភាព ដែលពាក់ព័ន្ធទៅនឹងទេសចរណ៍ផ្លូវភេទលើស្ត្រី និងកុមារ" ក្នុងខេត្តសៀមរាប។ គំរោងនេះនឹងត្រូវបានអនុវត្តដោយនាយកដ្ឋានតាមខេត្តរបស់ក្រសួងទេសចរណ៍, ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាពេលបច្ចុប្បន្ន ការអង្កេតមួយកំពុងត្រូវបានធ្វើឡើងនៅក្នុងចំនោមសណ្ឋាគារ, ផ្ទះសំណាក់, និងភោជនីយដ្ឋាន ដោយពិនិត្យលើធនធាន និងបុគ្គលិក។ អ្នកផ្តល់ព័ត៌មានមានស្ត្រី និងកុមារ ដែលមានអាយុពី ១៥ ទៅ ២៤ ឆ្នាំ ដែលធ្វើការនៅកន្លែងទេសចរណ៍ទាំងនេះ។ ដំណាក់កាលបន្ទាប់នឹងត្រូវផ្តល់ការបណ្តុះបណ្តាលដល់ម្ចាស់សណ្ឋាគារ ២០នាក់, ម្ចាស់ផ្ទះសំណាក់ ៦០នាក់, និងម្ចាស់ភោជនីយដ្ឋាន ៦០នាក់។ គោលបំណងនៃការបណ្តុះបណ្តាលនេះគឺ ពន្យល់



ផ្លូវភេទអស់រយៈពេលជាយូរបានអោយដឹងថា ជនល្មើសផ្លូវភេទមានមកពីប្រទេសចិន (រាប់បញ្ចូលទាំងតៃវ៉ាន់ ហើយនឹង សិង្ហបូរី ), ប្រទេសជប៉ុន, បារាំង, អូស្ត្រាលី, ហើយនឹងសហរដ្ឋអាមេរិក ។

សញ្ជាតិដ៏ទៃៗគេប្រើនូវវិធីសាស្ត្រផ្សេងៗគ្នា។ ជនល្មើសជនជាតិចិនរាប់បញ្ចូលទាំងភ្ញៀវទេសចរ និងអ្នកដែលរស់នៅក្នុងប្រទេសកម្ពុជា ពួកគេមិនបានជ្រើសរើសយកតែស្រីក្មេងគ្រប់ៗគ្នានោះទេ ប៉ុន្តែអ្នកខ្លះស្វែងរកស្រីក្រមុំបរិសុទ្ធ (ដើម្បីយុវកម្ម) ដែលមានអាយុពី ១២ ដល់ ១៦ឆ្នាំ ។ ពួកគេមិនប្រព្រឹត្តទៅលើកុមារជាសាធារណៈទេ ផ្ទុយមកវិញពួកគេចាត់អោយគេនាំយកកុមារទៅឱ្យនៅសណ្ឋាគារ ឬកន្លែងស្នាក់នៅរបស់ពួកគេ។ ជនល្មើសផ្លូវភេទដែលមកពីបណ្តាប្រទេសនៅទ្វីបអាស៊ីជាទូទៅប្រើនូវសព្ទ័ដើម្បីទាក់ទងឱ្យគេយកក្មេងស្រី ឬស្ត្រីវ័យក្មេងទៅឱ្យពួកគេ ចំណែកឯពួកបច្ចឹមប្រទេសវិញទំនងជាចេញទៅក្រៅ ដើម្បីទាក់ទងផ្ទាល់ជាមួយនឹងកុមារ (ឧទាហរណ៍ អ្នកខ្លះអនុវត្តបច្ចេកទេស ដែលមានឧបាយកលបោកបញ្ឆោតដើម្បីឱ្យគេទុកចិត្ត)។ បុគ្គលដែលបានពាក់ពន្ធ័អានាចារលើកុមារតាមចិញ្ចើមថ្នល់ គឺជាពួកបច្ចឹមប្រទេសដែលមានទិសដៅស្វែងរកក្មេងប្រុសអនីតិជន ចំនែកឯជនជាតិចិន និងជនជាតិជប៉ុនវិញចូលចិត្តទៅផ្ទះបន ដែលជាកន្លែងដែលគេអាចរកបានស្រីក្មេងៗច្រើនជាងនៅតាមចិញ្ចើមថ្នល់ ។

## ២.២ ទិសដៅ/កន្លែងដែលត្រូវធ្វើដំណើរឆ្ពោះទៅកាន់

ទេសចរណ៍ផ្លូវភេទកើតមានឡើងក្នុងទីក្រុងជាច្រើននៅក្នុងប្រទេសកម្ពុជា ដូចជាក្រុងភ្នំពេញ, សៀមរាប, និងក្រុងព្រះសីហនុ ដែលជាទិសដៅទេសចរណ៍

ព្រមទាំងតាមខេត្តដែលនៅជាប់ព្រំដែន ដូចជាបាត់ដំបង និងបន្ទាយមានជ័យ។ ទេសចរណ៏ផ្លូវភេទកើតមានឡើងច្រើនបំផុតក្នុងទីក្រុងភ្នំពេញ, សៀមរាប និង ក្រុងព្រះសីហនុ ដែលជាទិសដៅសំខាន់ៗបីដែលភ្ញៀវទេសចរធ្វើដំណើរទៅកាន់ នៅក្នុងអំឡុងពេលដែលពួកគេមកទស្សនៈកិច្ចនៅកម្ពុជា។ យោងទៅលើក្រសួង ទេសចរណ៏បានអោយដឹងថា ទេសចរណ៏ផ្លូវភេទបានកើតឡើងនៅក្នុងទិសខាង កើតនៃប្រទេសដែលអាចទាក់ទាញទេសចរណ៏បរិស្ថាន[២១]។ ប៉ុន្តែការសិក្សានេះ ពិនិត្យតែទិសដៅទេសចរណ៏ចំនួន ៣ ដែលល្បីបំផុតប៉ុណ្ណោះ ដែលនឹងជាចំណុច សំខាន់សំរាប់ការពិភាក្សាខាងក្រោម រាប់បញ្ចូលទាំងការខុសគ្នារវាងអត្រានៃ ទេសចរណ៏ផ្លូវភេទក្នុងតំបន់នីមួយៗផងដែរ ។

ក្នុងក្រុងនីមួយៗមានតំបន់ជាក់លាក់ ឬតំបន់ជិតខាង ដែលភ្ញៀវទេសចរ ផ្លូវភេទអាចត្រូវបានគេឃើញ។ ឧទាហរណ៏ ពួកគេស្ថិតនៅក្នុងផ្ទះបន ឬនៅជិតៗ ជុំវិញផ្ទះបន ឬក៏ក្លឹបកំសាន្តដូចជា បារ, ខារ៉ាអូខេ, បៀរហ្គាឌិន, ឬក៏កន្លែង ម៉ាស្សា ឬក៏ពួកគេប្តូរទៅកន្លែងតំបន់ទេសចរណ៏ជាញឹកញាប់ ដូចជាមាត់ទន្លេក្នុង ក្រុងភ្នំពេញ, តាមបណ្តោយផ្លូវស៊ីសុវត្ថិ ហេតុដូច្នេះហើយទើបគេឃើញមានក្មេង តាមចិញ្ចើមថ្នល់ជាច្រើនដើរសុំទាន ឬក៏លក់វត្ថុអនុស្សាវរីយ៏នៅទីនោះ។ លោក Michael Clark ជាជនជាតិអាមេរិក ត្រូវបានកាត់ទោសពីបទអសីលធម៌ផ្លូវភេទ ជាមួយអនីតិជន បានធ្វើដំណើរតាមមាត់ទន្លេដើម្បីស្វែងរកជនរងគ្រោះ។ គាត់ បានផ្តល់អាហារ, លុយ, និងស្ករគ្រាប់ដល់កុមារ ហើយលើសពីនេះទៅទៀតបាន

[21] Presentation by Mr. Hor Sarun, Deputy Director General of Admin. & Finance and Head of CSTC-MOT Secretariat, Ministry of Tourism at the National Workshop on Child Safe Tourism, 7-8 December 2005; 7 December 2005.



ពីភាពសំខាន់នៃការស៊ើបអង្កេត និងការប្រមូលភស្តុតាងអោយបានច្រើនតាម លទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីអាចអោយករណីទាំងអស់នេះត្រូវបានបញ្ជូន ដោយផ្ទាល់ទៅតុលាការ។ លោកជំទាវ អ៊ុន សុគន្ធា ក៏បានផ្តល់អនុសាសន៏ក្នុង ការធ្វើការយ៉ាងជិតស្និតជាមួយរដ្ឋាភិបាលនៃប្រទេសកំណើតរបស់ភ្ញៀវទេសចរណ៏ ផ្លូវភេទដើម្បីទប់ស្កាត់នៅហេតុការណ៏ទាំងនេះ[៥២]។ រហូតដល់ពេលនេះផែនការ សកម្មភាពត្រូវបានអនុវត្តតែមួយផ្នែកប៉ុណ្ណោះដោយក្រសួងមហាផ្ទៃ ដូច្នេះត្រូវ រង់ចាំមើលថា តើគោលដៅដែលត្រូវបានគេកំណត់រួចហើយទាំងអស់នោះនឹងត្រូវ បានគេអនុវត្តឱ្យបានសំរេចដែរឬទេ។

ក្រសួងទេសចរណ៏ ក៏សហការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ដែរគឺ ក្នុងគោលបំណងទប់ស្កាត់ទេសចរណ៏ផ្លូវភេទលើកុមារ។ ឧទាហរណ៏ក្រសួង បានធ្វើការជាក្រុមជាមួយអង្គការប្រ៊្យេនអន្តរជាតិ ៈ ពួកគេបានចុះហត្ថលេខាលើ អនុស្សារណៈយោគយល់គ្នា ដោយរៀបរាប់អំពីការលើកទឹកចិត្ត និងលំអិតអំពីកិច្ច សហប្រតិបត្តិការក្នុងការទប់ស្កាត់ទេសចរណ៏ផ្លូវភេទលើកុមារ។ អង្គការប្រ៊្យេន អន្តរជាតិបានបង្កើតនៅគំរោងមួយដែលមានទិសដៅ ចំពោះអ្នករត់ម៉ូតូឌុប និង អ្នករត់ម៉ូតូរ៉ឺម៉កកង់បី ដែលនឹងពិពណ៌នាលំអិតនៅខាងក្រោមនេះ។ ក្រសួង ទេសចរណ៏ បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយសមាគម អន្តរជាតិដើម្បីកិច្ចអភិវឌ្ឍន៏, ទេសចរណ៏, និងសុខភាព (AIDé TouS) ក្នុង ឆ្នាំ២០០៣ ដោយប្តេជ្ញាចិត្ត "បញ្ឈប់ទេសចរណ៏អនាចារក្នុងប្រទេសកម្ពុជា"។

[52] Presentation by HE General Unsokunthea, Director of the DAHT, MoI, given at the National Workshop on Child Safe Tourism, 7-8 December 2005; 7 December 2005.

គណៈកម្មាធិការលុបបំបាត់អំពើពេស្យាចារ, រំលោភ, និងការជួញដូរកុមារនៅកម្ពុជា, AIDéTouS, អង្គការមិត្តសំឡាញ់, និងអង្គការមិត្តសំឡាញ់អន្តរជាតិ ។

ក្រសួងទេសចរណ៍បានសំរបសំរួលសន្និសីទជាតិស្តីពី ទេសចរណ៍សុវត្ថិភាពកុមារក្នុងកិច្ចសហប្រតិបត្តិការជាមួយ គណៈកម្មាធិការលុបបំបាត់អំពើពេស្យាចារ, រំលោភ, និងការជួញដូរកុមារ, និងអង្គការទស្សនៈពិភពលោកកម្ពុជាក្នុងខែធ្នូ ឆ្នាំ២០០៥ នៅទីក្រុងភ្នំពេញ។ គោលបំណងរបស់សិក្ខាសាលានេះគឺ ដើម្បីចែករំលែកបទពិសោធន៍, ពិនិត្យឡើងវិញនូវភាពរីកចំរើនរបស់គណៈកម្មាធិការទេសចរណ៍លើកុមារផ្សេងៗ, ពិចារណាយ៉ាងហ្មត់ចត់ថា តើផ្នែកដ៏ទៃៗផ្សេងៗអាចធ្វើការរួមគ្នាអោយបានល្អដោយរបៀបណា ហើយពិភាក្សាអំពីគំនិតសំរាប់ផែនការសកម្មភាពឆ្នាំ ២០០៦-២០០៨។ អ្នកស្រាវជ្រាវមានលទ្ធភាពចូលរួមបានតែមួយរសៀលនៃសន្និសីទ ដែលមានរយៈពេល ២ថ្ងៃ តែប៉ុណ្ណោះ។ ក្នុងចំនោមនោះលោកជំទាវឧត្តមសេនីយ៍ អ៊ុន សុគន្ធា បានបកស្រាយយ៉ាងច្បាស់អំពីផែនការសកម្មភាពនោះ។ លោកជំទាវបានពន្យល់ថា ដើម្បីទប់ស្កាត់ការជួញដូរ និងការកេងប្រវ័ញ្ចជាពិសេសលើស្ត្រី និងកុមារ គឺត្រូវជំរុញអោយមានការចូលរួមពីសាធារណៈជន។ សកម្មភាពនេះត្រូវតែអនុវត្តដើម្បីប្រឆាំងនឹងបុគ្គលដែលមានអំណាចដែលបានប្រព្រឹត្តអំពើមិនស្មោះត្រង់។ សកម្មភាពនេះរួមមានការផ្សព្វផ្សាយព័ត៌មានបន្ថែម ដែលផ្តោតទៅលើតំបន់ព្រំដែនអន្តរជាតិដែលជាកន្លែងមានការជួញដូរកើតឡើងច្រើន។ ក្រសួងមហាផ្ទៃបញ្ជាក់ថា នឹងបិទក្រុមហ៊ុនណាមួយដែលអនុញ្ញាតឱ្យមានការកេងប្រវ័ញ្ចលើកុមារ។ លោកជំទាវបានបញ្ជាក់



បង្រៀនភាសាអង់គ្លេសដល់ពួកគេ[២២]។ ក្នុងខេត្តសៀមរាប កុមារដើរលក់វត្ថុអនុស្សាវរីយ៍ ឬសៀវភៅនៅជុំវិញប្រាសាទអង្គរវត្ត ឬក៏ជិតកន្លែងដែលភ្ញៀវទេសចរទៅបរិភោគអាហារ ឬពិសារភេសជ្ជៈ។ ជាក់ស្តែង នៅខេត្តសៀមរាបមានតំបន់ពិសេសដែលត្រូវបានគេបង្កើតឡើងសំរាប់ជនជាតិជប៉ុន ហើយនឹងភ្ញៀវទេសចរអាស៊ីដ៏ទៃៗទៀតរាប់បញ្ចូលទាំងសណ្ឋាគារដែលមានអ្វីៗជាច្រើន ក៏ប៉ុន្តែជាកន្លែងសុវត្ថិភាពកុមារ[២៣]។ ក្នុងក្រុងព្រះសីហនុឆ្នេរសមុទ្រ មានប្រជាប្រិយភាពចំពោះទាំងភ្ញៀវទេសចរណ៍ធម្មតាទាំងជនល្មើសផ្លូវភេទ។ កុមារនៅទីនោះដើរលក់ផ្លែឈើ ឬក៏ខ្សែដៃ ឬក៏ដើរប្រមូលកំប៉ុង ហើយពួកគេងាយទទួលរងនូវគ្រោះថ្នាក់នៃការរំលោភបំពានជាច្រើន។ គេនិយាយថា ភ្ញៀវទេសចរណ៍មកទិញរបស់របរពីក្មេងៗទាំងនេះដោយសារការអាណិតអាសូរ រាប់បញ្ចូលទាំងអ្នកខ្លះនឹងផ្តល់លុយ និងអាហារផងដែរ។ ជាលទ្ធផលពួកគេនាំកុមារទៅកាន់សណ្ឋាគារ។ ក្រោយពីទទួលបានកាដូ ឬក៏លុយកុមារមានអារម្មណ៍ថា ពួកគេមិនអាចបដិសេធនូវសំណើរបស់ភ្ញៀវទេសចរដែលសុំឱ្យកុមារទាំងនោះតាមគេបានទេ។ គេនិយាយថា ជនល្មើសផ្លូវភេទនាំកុមារដែលដើរត្រេតត្រតគោកយ៉ាកនៅតាម ឬជិតៗផ្សារកណ្តាលក្រុង។ ដោយសារក្រុងព្រះសីហនុ ស្ថិតនៅតំបន់ដាច់ស្រយាលវាមានការងាយស្រួលសំរាប់មនុស្សនាំកុមារទៅរកកន្លែងស្ងាត់តំបន់ដាច់ស្រយាលដោយអាចមិនឱ្យគេដឹងបាន[២៤]។

[22] Minutes of Presentation by Gary Phillips, US Immigration & Customs Service at the Child Sex Tourism Prevention Workshop, 28 February & 01 March 2005.
[23] Interview with Ms. Marie Bizet-Pechoux, ChildSafe Coordinator, Friends International; 14 December 2005.
[24] Presentation by Béatrice Magnier, Country Director, Action pour les Enfants (APLE) at the National Workshop on Child Safe Tourism, 7-8 December 2005; 7 December 2005.

វិធីសាស្ត្រដែលគេជ្រើសរើសមានលក្ខណៈប្លែកៗ គឺអាស្រ័យទៅលើថា តើកុមារដែលជាមុខសញ្ញានោះជាក្មេងប្រុស ឬក្មេងស្រី។ ភ្ញៀវទេសចរផ្លូវភេទបានជួបជនរងគ្រោះរបស់ពួកគេក្នុងកន្លែងទេសចរណ៍សាធារណៈ ឬក៏ក្នុងក្លឹបកំសាន្តក៏ប៉ុន្តែជារឿយៗ ប្រសិនបើនាងជាក្មេងស្រី ពួកគេនឹងនាំនាងទៅកាន់សណ្ឋាគារ ឬក៏ផ្ទះសំណាក់ ឬក៏ផ្ទះរបស់ពួកគេ ប្រសិនបើពួកគេកំពុងរស់នៅក្នុងប្រទេសកម្ពុជា។ បារនៅក្នុងក្រុងភ្នំពេញដែលពោរពេញទៅដោយក្មេងស្រីដូចជា បារម៉ាធីនី (បើក២៤ម៉ោង) ហើយនឹងបារស្បាក់គី។ យោងទៅលើបុគ្គលិក ដែលកំពុងធ្វើការនៅផ្ទះសំណាក់ក្នុងទីក្រុងភ្នំពេញបានអោយដឹងថា ជាធម្មតាភ្ញៀវនាំអ្នករកស៊ីផ្លូវភេទពេញវ័យដែលមានអាយុប្រហែលជា ២0ឆ្នាំ ទៅកាន់បន្ទប់របស់ពួកគេ។ បុគ្គលិកសណ្ឋាគារយល់ថា បញ្ហានេះជាធម្មតាពាក់ព័ន្ធជាមួយក្មេងស្រី មិនមែនក្មេងប្រុសទេ។ នៅពេលដែលភ្ញៀវមានបំណងយកក្មេងខាត់សារ៉ាស្បែកជើងទៅកាន់បន្ទប់របស់គេទាំងភ្ញៀវទាំងក្មេងប្រុសត្រូវបានគេស្នើសុំឱ្យចាកចេញ ។

ខេត្តសៀមរាបគឺ ជាទិសដៅដ៏មានប្រជាប្រិយសំរាប់មនុស្សមកកាន់ប្រទេសកម្ពុជា ដោយសារតែប្រាសាទអង្គរវត្ត។ ទោះបីជាយ៉ាងណាក៏ដោយថ្មីៗនេះវាត្រូវបានគេស្គាល់ថា ជាតំបន់ទេសចរណ៍ផ្លូវភេទ។ កន្លែងម៉ាស្សា, ក្លឹបកំសាន្ត, ហាងខារ៉ាអូខេ និងកន្លែងកំសាន្តផ្សេងៗទៀតត្រូវបានគេបង្កើតឡើង[២៥] ។ ក្នុងខេត្តសៀមរាបជនល្មើសផ្លូវភេទមិនមែនមានតែភ្ញៀវទេសចរនោះទេ គឺមាន

[25] Nuon Rithy Niron, Yit Viriya and Laurence Gray for World Vision Cambodia with the cooperation of the MoT and the Cambodian National Council for Children (CNCC), *Children's Work, Adult's Play; Child Sex Tourism – The Problem in Cambodia*, September 2001, World Vision International; p.18.



ទោសជនល្មើសទាំងអស់។ ផ្ទាំងរូបភាពទាំងអស់ត្រូវបានចែកចាយទៅដល់ការិយាល័យទេសចរណ៍ តាមខេត្តសំរាប់ចែកចាយតាមហាងកាហ្វេ, អិនធឺណេតកាហ្វេ, និង ផ្ទះសំណាក់ជាដើម ។ល។

ក្រសួងទេសចរណ៍ក៏បានបង្កើតនូវគណៈកម្មាធិការទេសចរណ៍សុវត្ថិភាពកុមារផងដែរ។ ឥឡូវនេះគណៈកម្មាធិការសុវត្ថិភាពកុមារមាន ១២ ខេត្តក្រុងក្នុងចំណោម ២៤ ខេត្តក្រុងទូទាំងប្រទេស។ មានការទទួលជោគជ័យគួរឱ្យកត់សំគាល់តាមខេត្ត ដូច្នេះគេសង្ឃឹមថា គណៈកម្មាធិការទេសចរណ៍សុវត្ថិភាពកុមារនឹងត្រូវបានគេបង្កើតឆាប់ៗក្នុងខេត្តដែលនៅសេសសល់។ គោលដៅនៃគណៈកម្មាធិការទេសចរណ៍សុវត្ថិភាពកុមាររួមមាន ការអភិវឌ្ឍន៍គោលការណ៍ទេសចរណ៍សុវត្ថិភាពកុមារ និងការជំរុញលើកទឹកចិត្តដល់កុមារអោយប្រាប់មនុស្សពេញវ័យអំពីហេតុការណ៍ទេសចរណ៍ផ្លូវភេទលើកុមារ។ រហូតមកដល់ពេលនេះ គណៈកម្មាធិការទេសចរណ៍សុវត្ថិភាពកុមារបានធ្វើសិក្ខាសាលាចំនួន ៨ ក្នុងក្រុងភ្នំពេញ, សៀមរាប, និងក្រុងព្រះសីហនុ ដែលឱ្យឳពុកម្តាយ (ដែលអាចបន្តផ្តល់ព័ត៌មានដល់មិត្តភ័ក្តិរបស់ពួកគេនៅក្នុងសហគមន៍របស់ពួកគេ), អាជ្ញាធរក្នុងស្រុក និងគ្រូបង្រៀនចូលរួមពាក់ព័ន្ធនៅក្នុងនោះដែរ។ លើសពីនេះទៅទៀត គណៈកម្មាធិការទេសចរណ៍សុវត្ថិភាពលើកុមារ បានជួបជាមួយមន្ត្រីរដ្ឋាភិបាលនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក គណៈកម្មាធិការនេះបានសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាលដូចជា អង្គការទស្សនៈពិភពលោកកម្ពុជា, ភាពឆ្លាតវៃរបស់កុមារអូស្ត្រាលី,

ព្រមទាំងម្ចាស់ជំនួញនៅក្បែរកន្លែងទេសចរណ៍ ដោយចាប់ផ្តើមបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល។ ក្រុមគោលដៅមានច្រើន គឺមានក្រុមទាំងឡាយណាដែលពាក់ព័ន្ធផ្នែកទេសចរណ៍ ឬក៏ទំនាក់ទំនងភ្ញៀវទេសចរ។

សារាចរបានដាក់បំរាមស្ថាប័នទេសចរណ៍ទាំងអស់ មិនអនុញ្ញាតអោយអនីតិជនស្នាក់ក្នុងសណ្ឋាគារ ឬផ្ទះសំណាក់ ប្រសិនបើមិនមានឪពុកម្តាយមកជាមួយ។ ក្រសួងទេសចរណ៍បានផលិតខិតប័ណ្ណស្តីពីទេសចរណ៍សុវត្ថិភាព កុមារ (ដែលមានច្បាប់ជូញដូរឆ្នាំ១៩៩៦ក្នុងខិតប័ណ្ណទាំងមូល) ព្រមទាំងមានស្លាកបិទ (ស្ទីកឃ័រ) ដោយមានសរសេរថា (ភ្ញៀវទេសចរផ្លូវភេទលើកុមារ : សូមប្រគល់ជនល្មើសឱ្យសមត្ថកិច្ច) លេខ Hotline របស់ក្រសួងមហាផ្ទៃដើម្បីទូរស័ព្ទ ប្រសិនបើមានលក្ខណៈសង្ស័យកើតឡើង[៥១] ។ ផ្ទាំងរូបភាពធំៗត្រូវបានលើកបញ្ឈរឡើងតាមដងផ្លូវធំៗពីប្រលានយន្តហោះរហូតដល់កណ្តាលទីក្រុងក្នុងទីរួមខេត្តសៀមរាប (សូមអ្នកស្រលាញ់ស្នាមញញឹមនៃកុមារកម្ពុជា) ហើយនៅក្នុងភ្នំពេញ និងតាមមាត់ទន្លេក្នុងរាជធានី និងក្បែរច្រកឆែកឆេរប៉ោយប៉ែត (ប្រឆាំងនឹងភ្ញៀវទេសចរផ្លូវភេទលើកុមារដាច់ខាត)។ រាល់ផ្លាកសញ្ញា និងផ្ទាំងរូបភាពទាំងអស់មានដាក់នូវលេខ Hotline របស់ក្រសួងមហាផ្ទៃ។ សារនេះមានសរសេរថា មិនអាច និងមិនត្រូវធ្វើមិនដឹងមិនឮចំពោះបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារឡើយ ហើយត្រូវតែរាយការណ៍រាល់ហេតុការណ៍ទាំងអស់ដែលបានកើតឡើង និងត្រូវតែប្តឹងថ្កោល

[51] The Ministry of Interior launched this 24-hour hotline in 2000 and receives over 800 calls on new cases each year. Provincial hotlines have also been put in place in Siem Reap, Sihanouk ville and Beanteay Manchey. See *Government is Committed to Fighting Sexual Exploitation*, Letter to the Editor, Prum Sokha, Secretary of State, Interior Ministry, 7 June 2005; http://www.interior.gov.kh/news_content.asp?NewsID=81



ជនបរទេសដែលមានទីលំនៅនៅទីនោះដែលជាអ្នកបង្រៀនភាសារអង់គ្លេស ឬក៏ជាអ្នករកស៊ី។ ជនបរទេសដែលមានទីលំនៅក្នុងសៀមរាបមានចំនួនតិចតួចណាស់ដែលត្រូវបានគេចាប់ខ្លួនពីបទពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទជាមួយកុមារ ដែលពួកគេបាននាំមកផ្ទះរបស់ពួកគេ។ ពួកគេទាំងនេះ គឺជាអ្នកដែលរស់នៅទីនោះក្នុងរយៈពេលយូរមិនមែនភ្ញៀវទេសចរណ៍ដែលគ្រាន់តែស្នាក់នៅ ២-៣ ថ្ងៃ ប៉ុណ្ណោះនោះទេ។ ភ្ញៀវទេសចរដែលស្នាក់នៅក្នុងរយៈពេលខ្លី ដែលស្វែងរកការរួមភេទតែងតែទៅផ្ទះបនផ្ទាល់ ឬក៏ទៅកាន់ក្លឹបរាត្រី ឬក៏ខារ៉ាអូខេ។ អ្នកផ្តល់ព័ត៌មានជាច្រើនពីក្រុមហ៊ុនទេសចរណ៍បាននិយាយថា ជនប្រព្រឹត្តិផ្លូវភេទ គឺជាប្រភេទភ្ញៀវទេសចរដែលធ្វើដំណើរជាលក្ខណៈបុគ្គល មិនមែនធ្វើដំណើរជាលក្ខណៈក្រុមនោះទេ ព្រោះការធ្វើដំណើរជាលក្ខណៈក្រុម គឺត្រូវធ្វើដំណើរគោរពតាមកម្មវិធីធ្វើដំណើរ/កាលវិភាគធ្វើដំណើរ ហើយនឹងមានអ្នកមគ្គុទេសទេសចរណ៍ទៀតផង។ ក្មេងៗទំនងជាបានស្គាល់/ធ្លាប់ទៅនឹងសំណើរពិសេសរបស់ភ្ញៀវទេសចរផ្សេងៗទាំងឡាយ ដូច្នេះឥឡូវនេះក្មេងៗអាចបង្ហាញនូវស្នាមញញឹមជាពិសេសណាមួយទៅកាន់ភ្ញៀវទេសចរ ដែលអាចអោយភ្ញៀវទេសចរ ដែលដើរកាត់ទីនោះដឹងថា មានសេវាកម្មបំរើផ្លូវភេទ។ ក្មេងខ្លះដែលលក់វត្ថុអនុស្សាវរីយ៍ក៏អាចផ្តល់នូវការរួមភេទផងដែរ ពួកគេមិនទាន់មានអាយុគ្រប់គ្រាន់ដើម្បីបំរើការក្នុងផ្ទះបន ដូច្នេះពួកគេចេញក្រៅដើម្បីព្យាយាមរកអតិថិជនដោយផ្ទាល់។ ទោះបីជាជនបរទេសជាច្រើនកំពុងរស់នៅទីនោះមានការកើនឡើង[២៦] ក៏ដោយក៏ក្រុង

[26] Presentation by Béatrice Magnier, Country Director, Action pour les Enfants (APLE) at the National Workshop on Child Safe Tourism, 7-8 December 2005; 7 December 2005.

ព្រះសីហនុ គឺជាទិសដៅរម្មណីយដ្ឋានទេសចរណ៏ឆ្នេរសមុទ្រមួយ។ ជនបរទេសទាំងនេះអាចមកស្នាក់នៅរយៈពេល ២-៣ ខែ ឬមួយឆ្នាំ ហើយក្នុងចំណោមពួកគេ គឺមានជនដែលរំលោភបំពានលើកុមារ។ ពួកគេដឹងពីកន្លែងរបស់កុមារដូច្នេះពួកគេអាចស្វែងរកកុមារបានយ៉ាងងាយស្រួល។ ជារឿយៗមនុស្សម្នាក់នឹងរំលោភកុមារដដែលៗជាញឹកញាប់។ វាជារឿងធម្មតាទៅហើយសំរាប់ជនប្រព្រឹត្តផ្តល់ថ្លៃពី ២ ដុល្លារ ទៅ ៥ ដុល្លារ សំរាប់សេវាកម្មផ្លូវភេទ ក្នុងមួយយប់នោះទោះបីជាយ៉ាងណាក៏ដោយ ក្មេងៗកម្រស្នាក់នៅជាមួយពួកគេពេញមួយយប់ណាស់។ ប្រសិនបើក្មេងវាធ្វើដូច្នេះពួកគេនឹងទាថ្លៃបន្ថែម។ ក្មេងមកពីមណ្ឌលម្លប់តាប៉ាងទទួលបាន ១០ ដុល្លារ សំរាប់រយៈពេល ១យប់ពេញ[២៧]។ ជួនកាលក្មេងៗទទួលនូវកាដូជាមួយនឹងលុយទៀត ឬក៏ទទួលកាដូជំនួសលុយ ក៏ប៉ុន្តែភាគច្រើនគេតែងតែដោះដូរយកលុយ។ មានកត្តាមួយចំនួនដែលធ្វើអោយជនប្រព្រឹត្តមានការងាយស្រួលក្នុងការលាក់បាំងនូវអំពើរបស់ពួកគេ ហើយជាការលំបាកបន្ថែមទៀតចំពោះជនទាំងឡាយណា ដែលធ្វើការដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភលើកុមារ។ ទីមួយមានអង្គការក្រៅរដ្ឋាភិបាលតិចតួចណាស់ ដែលធ្វើការងារនៅក្នុងក្រុងព្រះសីហនុ។ ដោយសារអង្គការដែលផ្តល់ជំនួយនៅទីនោះបានដឹកនាំធ្វើការពិនិត្យតាមដានលើករណីរំលោភកុមារ (ជាជាងប៉ូលីស) មានចំនួនដ៏តិចតួចធ្វើឱ្យកង្វះខាតក្នុងការពិនិត្យតាមដាននេះកាន់តែមានច្រើនឡើង។ ទីពីរ ដោយសារជនល្មើសជារឿយៗគឺជាអ្នកដែលស្នាក់នៅយូរមានករណីតិចតួចណាស់ ដែលកើត

[27] Interview with Maggie Eno, Project Coordinator, M'lop Tapang; 20 January 2006.



ភាពកុមារដែលនឹងត្រូវអនុវត្តដោយក្រសួងមហាផ្ទៃ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ហើយនឹងក្រសួងខ្លួនឯង។ ក្រោយពីបានធ្វើការអង្កេតមួយរួចមកកម្មវិធីមួយ ត្រូវបានបង្កើតឡើងសំរាប់អនុវត្តផែនការនេះ។ កម្មវិធីនោះរួមមាន ការអប់រំ, បង្កើនការយល់ដឹង, វគ្គបណ្តុះបណ្តាល, សិក្ខាសាលាសំរាប់ម្ចាស់សណ្ឋាគារ និងផ្ទះសំណាក់, អ្នកនាំភ្ញៀវ, និងអ្នករត់តាក់ស៊ី។ ការអប់រំបន្តកំពុងត្រូវបានផ្តល់ទៅអោយក្រុមគោលដៅរួមមាន កុមារ, ភ្នាក់ងារអនុវត្តច្បាប់, អ្នកដែលធ្វើការក្នុងឧស្សាហកម្មទេសចរណ៏, ក្រុមហ៊ុនអាកាសចរណ៏ និងអ្នកដែលរស់នៅក្នុងតំបន់ទិសដៅទេសចរណ៏ដ៏ទៃទៀត។ ក្រសួងទេសចរណ៏កំពុងសហការជាមួយអង្គការដ៏ទៃទៀត ដើម្បីបង្កើនការយល់ដឹងក្នុងចំណោមម្ចាស់ និងបុគ្គលិកសណ្ឋាគារ និងផ្ទះសំណាក់ព្រមទាំងអ្នកបើកតាក់ស៊ី និងអ្នករត់ម៉ូតូឌុប។ ឥឡូវនេះ វាទំនងជាមិនទាន់បានទទួលជោគជ័យធំដុំទេ ៖ ករណីតិចតួចនៃទេសចរណ៏ផ្លូវភេទលើកុមារត្រូវបានរាយការណ៏ដោយម្ចាស់សណ្ឋាគារនេះប្រហែលជាភាគច្រើនពួកគេមានការភ័យខ្លាចបាត់បង់នូវការរកស៊ី។ អ្នករត់តាក់ស៊ី ឬអ្នករត់ម៉ូតូឌុបនៅតែបន្តផ្តល់ស្រី (ហើយពួកគេមួយចំនួនគឺ ជាកុមារ) ដល់ភ្ញៀវទេសចរ។ រហូតមកដល់ពេលនេះ ក្រសួងបានផ្តល់នូវការបណ្តុះបណ្តាលដល់មន្ត្រីប៉ូលីសទេសចរណ៏, មន្ត្រីក្នុងនាយកដ្ឋានប្រឆាំងនឹងការជួញដូរមនុស្ស, មន្ត្រីក្រសួងទេសចរណ៏, សមាជិកគណៈកម្មាការទេសចរណ៏សុវត្ថិភាពកុមារ, អ្នកនាំភ្ញៀវទេសចរ, សមាគមទេសចរណ៏, ភ្នាក់ងារទេសចរណ៏, កុមារនៅកន្លែងទេសចរណ៏

សកម្មភាពជាតិ ៥ឆ្នាំ ដើម្បីប្រឆាំងនឹងការកេងប្រវ័ញ្ចការរកស៊ីផ្លូវភេទលើកុមារ។ ផែនការនោះត្រូវបានអនុម័តក្នុងឆ្នាំ ២០០០ ហើយគូសបញ្ជាក់នូវកត្តាសំខាន់ៗនៃការការពារកុមារដែលរងគ្រោះ ដោយសារការកេងប្រវ័ញ្ចផ្លូវភេទក្នុងចំណោមបញ្ហាដ៏ទៃៗទៀត។ ផែនការនេះគឺជាផ្នែកនៃយុទ្ធនាការជាតិ ដោយភ្នាក់ងាររាជរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដើម្បីលុបបំបាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះក្រុមប្រឹក្សាជាតិកម្ពុជាសំរាប់កុមារកំពុងព្រៀងផែនការសកម្មភាពជាតិរយៈពេល ៥ឆ្នាំ ថ្មីមួយ (២០០៥-២០០៩) សំរាប់រាជរដ្ឋាភិបាល ដោយថែងអំពីការជួញដូរមនុស្សក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទដែលក្នុងនោះមានផ្នែកមួយស្តីពីការការពារទេសចរណ៍ផ្លូវភេទលើកុមារ និងធ្វើឱ្យប្រសើរឡើងនូវវិស័យទេសចរណ៍ជាវិជ្ជមានក្នុងប្រទេសកម្ពុជា។ ផែនការនេះមានន័យថា ត្រូវតែមានគោលការណ៍តឹងតែង និងការទទួលខុសត្រូវច្បាស់លាស់ដែលនឹងត្រូវបានចែកជូនក្រសួងនីមួយៗដើម្បីអនុវត្ត។

ក្រសួងទេសចរណ៍ គួរតែត្រូវបានទទួលការកោតសរសើរអំពីការងាររបស់ខ្លួនក្នុងការទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។ ក្រសួងនេះបានចាប់ផ្តើមការងាររបស់ខ្លួនលើទេសចរណ៍ផ្លូវភេទលើកុមារក្នុងឆ្នាំ ២០០០ បើកប្រតិបត្តិការទូទាំងប្រទេសទាំងនៅតាមថ្នាក់ខេត្ត និងថ្នាក់ជាតិ។ ក្រសួងនេះបានបង្កើតនូវគំរោងទេសចរណ៍សុវត្ថិភាពកុមារ ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការទស្សនៈពិភពលោកកម្ពុជា និងជំនួយកុមារសំរាប់ការប្រមូលផ្តុំ និងការចូលរួមក្នុងឆ្នាំ ២០០១។ ក្រសួងទេសចរណ៍បានបង្កើតនូវផែនការសំរាប់ទេសចរណ៍សុវត្ថិ



ឡើងក្នុងសណ្ឋាគារ និងផ្ទះសំណាក់ ប៉ុន្តែផ្ទុយមកវិញវាបានកើតឡើងក្នុងផ្ទះឯកជនដែលធ្វើឱ្យការស៊ើបអង្កេតមានលក្ខណៈស្មុគស្មាញបន្ថែមទៀត។ សំរាប់អ្នកស៊ើបអង្កេតក្នុងការធ្វើសកម្មភាពចុះឡើងនៅក្បែរលំនៅដ្ឋានឯកជននោះ វាមានការលំបាកច្រើនពីព្រោះវាងាយឱ្យគេឃើញ ឬសំគាល់បាន ហើយពិបាករកលេសដោះសារថា ហេតុអ្វីបានជានៅទីនោះ។ កត្តាចុងក្រោយក្រុងព្រះសីហនុគឺជាសហគមដ៏តូចមួយដែលមនុស្សនៅទីនោះអាចស្គាល់គ្នាបានយ៉ាងច្បាស់ ហើយធ្វើឱ្យមានការលំបាកសំរាប់អ្នកស៊ើបអង្កេតដែលព្យាយាមលាក់បាំងនូវអត្តសញ្ញាណនិងសកម្មភាព[២៨]។ ជនល្មើសដ៏ច្រើនបានពាក់ព័ន្ធក្នុងមុខរបរ ដែលធ្វើឱ្យគេកាន់តែខិតជិតជាមួយក្មេង ហើយអាចធ្វើអោយពួកគេអាចបង្កើតបាននូវទំនាក់ទំនងដ៏គួរអោយទុកចិត្តជាមួយកុមារ។ កុមារមួយចំនួនបានអះអាងថា ខ្លួនត្រូវបានរំលោភដោយជនជាតិហូឡង់ដែលបានបង្កើតសាលានៅក្នុងក្រុងព្រះសីហនុ ហើយករណីនេះនៅតែស្ថិតនៅក្រោមការស៊ើបអង្កេតនៅឡើយ។ ឬជនល្មើសអាចបង្កើតទំនាក់ទំនងជាមួយនឹងកុមារ ហើយនឹងគ្រួសាររបស់ពួកគេ ហើយបានផ្តល់ថវិកាសំរាប់ការសិក្សារបស់កុមារ ។

ចំពោះភ្ញៀវទេសចរ ដែលបានស្វែងរកការរួមភេទក្នុងក្រុងព្រះសីហនុទំនងជាស្នាក់នៅក្នុងផ្ទះសំណាក់មួយដ៏ថោកហើយតូច។ កន្លែងស្ងប់ស្ងាត់ ហើយនឹងឆ្នេរសមុទ្រអូឈើទាល គឺជាកន្លែងដែលប្រហែលជាមានប្រជាប្រិយភាពចំពោះជនទាំងឡាយណាដែលស្វែងរកសេវាកម្មផ្លូវភេទ។ ក្មេងស្រីដែលធ្វើការក្នុងបារ

[28] Presentation by Béatrice Magnier, Country Director, Action pour les Enfants (APLE) at the National Workshop on Child Safe Tourism, 7-8 December 2005; 7 December 2005.

ខ្លះក្នុងតំបន់នោះត្រូវបានគេអោយធ្វើការជាអ្នកបំរើ ឬអ្នកអនាម័យ។ អ្វីដែលពួកគេត្រូវបានគេផ្តល់ឱ្យគឺ ប្រាក់មួយចំនួនដែលពួកគេចាត់ទុកថា វាច្រើនសំរាប់ពួកគេគឺ ពួកគេមានឱកាសដើម្បីផ្គត់ផ្គង់គ្រួសារ, សំរាប់ខ្លួនគេ, និងអាចឱ្យគេរក្សាការសំងាត់បាន។ យោងទៅលើនិយោជិតក្រុមហ៊ុនទេសចរណ៍ម្នាក់បានឱ្យដឹងថា ម្ចាស់ជំនួញជាច្រើននៅក្នុងតំបន់នោះ ប្រាប់ភ្ញៀវរបស់ពួកគេទាំងកន្លែងដែលត្រូវរកស្រី (អនីតិជន) ឬក៏នាំស្រីឱ្យភ្ញៀវ។ យោងទៅលើភ្នាក់ងារទេសចរណ៍ក្នុងស្រុកមួយបានអោយដឹងថា មានកន្លែងមួយឈ្មោះថា ប៊ីបារស្ថិតនៅក្នុងតំបន់ជាយក្រុងនៃក្រុងព្រះសីហនុដែលមានពាក្យចរចាមអារាមថា ជាកន្លែងផ្តល់ស្រីដែលមានអាយុពី ១៤ ដល់ ១៦ឆ្នាំ អតិថិជនគឺ ចំរុះភ្ញៀវទេសចរ ហើយនឹងបុរសខ្មែរក្មេងៗ។

វាហាក់បីដូចជាមានគំនិតទូទៅមួយក្នុងចំណោមជនដែលជួយទាក់ទងរកកុមារ ដើម្បីបំរើផ្លូវភេទឱ្យគេទាក់ទងទៅនឹងអាយុរបស់ក្មេងស្រីដែលពួកគេអាចផ្តល់អោយ។ ក្នុងការសិក្សាដែលត្រូវបានគេធ្វើឡើងដើម្បីវាយតំលៃលើស្ថានភាពនៃអំពើអានាចារលើកុមារក្នុងក្រុងព្រះសីហនុក្នុងខែមិថុនា ឆ្នាំ២០០៥ អ្នកស្រាវជ្រាវបច្ចឹមប្រទេស ២នាក់ បានធ្វើជាជនអានាចារលើកុមារដើម្បីបានចូលទៅផ្ទះបនដំល្បីក្បែរកំពង់ផែ ហើយបានឃើញក្មេងស្រី ២-៣ នាក់ ដែលប៉ាន់ស្មានទៅប្រហែលជាមានអាយុ ១០ ទៅ ១៤ ឆ្នាំ ដែលត្រូវបានផ្តល់អោយពួកគេសំរាប់រួមភេទ។ នៅពេលដែលពួកគេសួររកស្រីដែលក្មេងជាងហ្នឹងទៀត ពួកគេត្រូវបានគេបង្ហាញនូវក្មេងស្រីអាយុ ១១ ទៅ ១២ ឆ្នាំ។ នៅពេលដែលពួកគេសួរអ្នកម៉ូតូ



ភាព និងព្យាយាមធានាអោយមានសុវត្ថិភាពបរិស្ថានសំរាប់កុមារកម្ពុជា។ កត្តាទាំងអស់នេះគឺ ជាលទ្ធផលនៃការប្រឹងប្រែងរួមរវាងរាជរដ្ឋាភិបាលកម្ពុជា, អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិដ៏ទៃទៀត។ ទោះបីជាយ៉ាងណាក៏ដោយកិច្ចសហប្រត្តិបត្តិការត្រូវការចាំបាច់បន្ថែមទៀត ដើម្បីជៀសវាងនូវការធ្វើការងារជាន់គ្នាធានាមិនអោយមានភាពខ្វះចន្លោះ និងអោយមានប្រសិទ្ធិភាពខ្ពស់បំផុត។ គំនិតផ្តួចផ្តើមក៏ត្រូវការអោយមានភាពច្បាស់លាស់ផងដែរ គឺយុទ្ធនាការត្រូវផ្តោតគោលដៅយ៉ាងជាក់លាក់ទៅលើមនុស្សមួយចំនួន, សញ្ជាតិ, និងផ្នែកផ្សេងៗដែលមានការពាក់ព័ន្ធផ្ទាល់ និងទំនាក់ទំនងជាមួយវិស័យទេសចរណ៍។ ខាងក្រោមនេះគឺ បង្ហាញអំពីយុទ្ធនាការមួយចំនួន ដែលផ្តួចផ្តើមធ្វើដោយរាជរដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជនរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះក្នុងគោលបំណងទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

## ៤.១ រាជរដ្ឋាភិបាលកម្ពុជា

ប្រទេសកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងក្នុងតំបន់ និងអន្តរជាតិជាច្រើន ដើម្បីបំពេញបន្ថែមឱ្យច្បាប់របស់ខ្លួនក្នុងគោលបំណងការពារកុមាររបស់ខ្លួន។ បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកំពុងពិនិត្យច្បាប់ជួញដូរថ្មីនិងកំពុងព្រៀងច្បាប់ទេសចរណ៍ថ្មី ដែលនឹងចែងលើការកេងប្រវ័ញ្ចលើកុមារក្នុងបរិបទទេសចរណ៍អោយមានប្រសិទ្ធិភាពបន្ថែមទៀត។ ភ្នាក់ងារអនុវត្តច្បាប់ និងកងកំលាំងប៉ូលីសបង្កើននូវកិច្ចប្រឹងប្រែងដើម្បីចាប់ជនល្មើស និងសង្គ្រោះជនដែលរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទ។ ប្រទេសកម្ពុជាបានអនុម័តផែនការ

ឆ្នាំ ២០០៤ ជនល្មើសបានទទួលទោសចំពោះការចោទប្រកាន់ចំពោះគាត់ ។ លោក Kent Frank មានអាយុ ៤៨ ឆ្នាំ ត្រូវបានចាប់ខ្លួនក្នុងសហរដ្ឋអាមេរិក នៅពេលដែលគាត់វិលត្រឡប់ពីកម្ពុជាវិញ ។ គាត់ត្រូវបានគេចោទប្រកាន់ដោយមានសុំណុំរឿង ៩ ពាក់ព័ន្ធនឹងសកម្មភាពជាមួយអនីតិជន ៤ នាក់ ក្នុងប្រទេសកម្ពុជារួមមានទេសចរណ៍ផ្លូវភេទលើកុមារ, និងទិញអនីតិជនក្នុងគោលបំណងជំរុញសកម្មភាពបទល្មើសផ្លូវភេទ ។ ការជំនុំជំរះត្រូវបានកំណត់ចាប់ផ្តើមក្នុងខែមីនា ឆ្នាំ ២០០៦ ។

វាជាការជំរុញលើកទឹកចិត្ត ដែលសហរដ្ឋអាមេរិកកំពុងប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ ហើយប្រសិនបើប្រទេសជាច្រើនទៀតមានការប្រឹងប្រែងស្រដៀងគ្នានេះ ដើម្បីទប់ស្កាត់លើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនោះវាប្រសើរខ្លាំងណាស់ ។ នៅទ្វីបអឺរ៉ុប រដ្ឋាភិបាលអាឡឺម៉ង់ទំនងជាកំពុងខិតខំប្រឹងប្រែងកាន់តែខ្លាំងឡើងៗក្នុងបញ្ហានេះ ។ ប៉ុន្តែច្បាប់ប្រព្រឹត្តបទល្មើសក្រៅទឹកដីមានការស្មុគស្មាញ និងលំបាកក្នុងការអនុវត្តន៍ ។ ហើយពួកគេត្រូវតែមានធ្វើកិច្ចការទាំងនៅក្នុងប្រទេសជនល្មើរស់នៅទាំងនៅក្នុងប្រទេសដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត ដើម្បីឱ្យមានប្រសិទ្ធិភាព (ក្នុងករណីនេះប្រទេសកម្ពុជាមិនទាន់បានធ្វើច្បាប់ប្រព្រឹត្តបទល្មើសក្រៅទឹកដីនៅឡើយទេ) ។

## ៤. គំនិតផ្តួចផ្តើមដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ

យុទ្ធនាការជាច្រើនត្រូវបានធ្វើឡើងអស់រយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះដោយជំរុញឱ្យវិស័យទេសចរណ៍រីកចំរើនប្រកបដោយការទទួលខុសត្រូវ និងមាននិរន្ត



ឪបរកស្រីក្មេងៗជាងហ្នឹងទៀត អ្នកម៉ូតូឌុបបដិសេធមិនជួយរកឱ្យហើយបើកបរចេញទៅ[២៩] ។

## ៣. ទំនាក់ទំនងរវាងភ្ញៀវទេសចរផ្លូវភេទលើកុមារហើយនឹងកុមារ

ភ្ញៀវទេសចរផ្លូវភេទខ្លះនឹងទំនាក់ទំនងជាមួយកុមារផ្ទាល់តែម្តង ដោយផ្តល់ឱ្យជាអាហារ ឬលុយដែលអាចបញ្ចុះបញ្ចូលដល់កុមារដើម្បីអោយទៅតាមពួកគេទៅកាន់សណ្ឋាគារ, ផ្ទះសំណាក់ ឬកន្លែងស្នាក់ៗដ៏ទៃទៀត នៅខណៈពេលដែលជនប្រព្រឹត្តដ៏ទៃទៀតនឹងប្រើអន្តរការី ។ ជនល្មើសផ្លូវភេទជាច្រើនប្រើនូវបច្ចេកទេសម្យ៉ាងដែលជា "**ឧបាយកលបោកបញ្ឆោតធ្វើឱ្យកុមារទុកចិត្ត**" ជានីតិវិធីមួយដែលជនប្រព្រឹត្តិអានាចារប្រើប្រាស់ពេលវេលា ដើម្បីបង្កើតនូវទំនាក់ទំនងឱ្យមានភាពទុកចិត្តដល់កុមារ ដើម្បីអោយកុមារនឹងរួមភេទជាមួយនឹងពួកគេបានយ៉ាងងាយស្រួលថែមទៀត ។ ពីព្រោះដំណើការរបៀបនេះ គឺចំនាយពេលច្រើនវាគឺ ជាឧបាយកលដែលត្រូវប្រើប្រាស់ភាគច្រើន ដោយជនបរទេសដែលរស់នៅក្នុងស្រុកខ្មែររយៈពេលយូរជាជាងភ្ញៀវទេសចរ ។ ជនល្មើសនឹងចាប់ផ្តើមទាក់ទងកុមារ និងធ្វើឱ្យមិត្តភាពនេះកាន់តែជិតដិត ហើយប្រហែលជាទាក់ទងជាមួយនឹងគ្រួសាររបស់កុមារផងដែរ ។ ការងារដែលទាក់ទងនឹងផ្នែកកុមារ (ដូចជាការបង្រៀន ឬការងារសង្គមកិច្ចជាដើម) គឺជាការងារសាមញ្ញក្នុងចំនោមជនបែបនេះ

[29] Von Gyer, Judith for NGO Coalition to Address Sexual Exploitation of Children in Cambodia (COSECAM) with the cooperation of Village Focus International (VFI), *Situation Analysis of Paedophilia in Sihanouk ville – Study of Perceived Demand for Child Sex in Sihanouk ville*, June 2005; p.20.

ព្រោះវាអាចធ្វើឱ្យដំណាក់កាលចាប់ផ្តើមដំបូងក្នុងការទាក់ទងជាមួយកុមារកាន់តែងាយស្រួល និងកាន់តែលឿន។ បន្ទាប់មកទៀត ជនប្រព្រឹត្តនឹងព្យាយាមកំណត់នូវអ្វីដែលកុមារ ហើយនឹងគ្រួសារត្រូវការ ហើយជននោះនឹងផ្តល់ឱ្យរបស់របរទាំងនោះដល់កុមារ និងគ្រួសារ។ ជននោះអាចនឹងផ្តល់កាដូដល់គ្រួសារកុមារ, ជួយឧបត្ថម្ភការសិក្សារបស់កុមារ, ឬផ្តល់កន្លែងឱ្យកុមារស្នាក់នៅថែមទៀតផង។ ហេតុនេះហើយទើបធ្វើអោយគ្រួសារនោះមានកាពឹងផ្អែកចំពោះជននោះ (គឺមិនឯករាជ្យ គឺស្ថិតនៅក្រោមឥទ្ធិពលរបស់គេ)។ នៅពេលដែលការទំនាក់ទំនងរវាងជនប្រព្រឹត្ត ហើយនឹងកុមារមានស្នេហភាពគ្រប់គ្រាន់ ហើយជនប្រព្រឹត្តនឹងចាប់ផ្តើមដំណាក់កាលលួងលោម។ នៅពេលដែលជននោះរំលោភកុមារ គ្រួសាររបស់កុមារទំនងជាមិនធ្វើការប្តឹងប្តល់ជននោះទេ ទោះបីជាក្រុមគ្រួសារទាំងនោះបានដឹងនូវការរំលោភនេះយ៉ាងណាក៏ដោយ ពីព្រោះគ្រួសារទាំងនោះត្រូវការជននោះហើយមានអារម្មណ៍ថា ពួកគេជំពាក់គុណជននោះ។ ឧទាហរណ៍ ក្មេងស្រីដ៏វ័យក្មេងម្នាក់នៅក្នុងខេត្តបាត់ដំបងត្រូវបានរំលោភតាំងពីអាយុ ៨ ឆ្នាំ រហូតដល់អាយុ ១២ ឆ្នាំ ហើយគ្រួសាររបស់នាងបានដឹងនូវការរំលោភជាបន្តបន្ទាប់នោះ ក៏ប៉ុន្តែមិនមានវិធានការណាមួយដើម្បីទប់ស្កាត់ ឬក៏រាយការណ៍ពីរឿងនេះទេ[៣០]។

អន្តរការី ឬក៏អ្នកសំរបសំរួល (អ្នករកស្រី/ម៉ូយឱ្យអតិថិជន) គឺជាមនុស្សដែលនាំជនល្មើសផ្លូវភេទ និងកុមាររងគ្រោះមកជួបគ្នា។ ពួកគេរួមមានអ្នកបើកបរតាក់ស៊ី និងអ្នករត់ម៉ូតូឌុប, អ្នកនាំភ្ញៀវទេសចរ, និយោជិកក្រុមហ៊ុន

[30] Interview with Béatrice Magnier, Country Director, Action pour les Enfants (APLE); 05 December 2005.



លោក Schmidt ហើយចោទប្រកាន់គាត់ពីបទរួមភេទជាមួយអនីតិជន ហើយក្រោយមកគាត់បានភៀសខ្លួនមកកាន់ប្រទេសកម្ពុជា។ ក្រោយមកប៉ូលីសកម្ពុជាបានចាប់អតីតគ្រូបង្រៀនរូបនេះ ហើយបានផ្តល់ព័ត៌មានដល់អ្នកស៊ើបអង្កេតអាមេរិកដែលជាអ្នកចាប់ផ្តើមកសាងសំណុំរឿង ដើម្បីចោទប្រកាន់ជននោះនៅក្នុងសហរដ្ឋអាមេរិក។ ប៉ុន្តែចៅក្រមកម្ពុជាបានដោះលែងលោក Schmidt ដោយគ្រាន់តែដកទុកលិខិតឆ្លងដែនរបស់គាត់ ហើយដាក់គាត់ឱ្យស្ថិតនៅក្រោមការឃ្លាំមើលយ៉ាងតឹងរឹងប៉ុណ្ណោះ។ ពីរថ្ងៃក្រោយ មកអ្នកស៊ើបអង្កេតអង្គការក្រៅរដ្ឋាភិបាលបានឃើញលោក Schmidt ចូលទៅក្នុងផ្ទះសំណាក់ជាមួយនឹងក្មេងប្រុសអាយុ ១២ឆ្នាំ។ គេទូរសព្ទ័ហៅប៉ូលីស ហើយប៉ូលីសក៏មកចាប់គាត់ម្តងទៀត។ ចុងបញ្ចប់ជនជាតិអាមេរិករូបនោះត្រូវបានគេបញ្ជូនទៅកាន់ Baltimore ដើម្បីប្រឈមមុខនឹងការចោទប្រកាន់ក្រោមច្បាប់ PROTECT។ លោក Schmidt បានឆ្លើយទទួលទោស ហើយត្រូវបានកាត់អោយជាប់ពន្ធនាគារ ១៥ ឆ្នាំ ហើយប្រសិនបើផុតអាយុកាលនៃការជាប់ពន្ធនាគារ ហើយជននេះត្រូវបានដោះលែងក៏ដោយ ក៏ជននោះត្រូវស្ថិតក្នុងការត្រួតពិនិត្យអស់មួយជីវិត ។

លោក Gary Jackson មានអាយុ ៥៦ ឆ្នាំ ត្រូវបានចោទប្រកាន់ពីបទល្មើសទេសចរណ៍ផ្លូវភេទលើកុមារស្ថិតនៅក្រោមច្បាប់ PROTECT។ គាត់ត្រូវបានចាប់ខ្លួនដោយប៉ូលីសកម្ពុជាពីបទពាក់ពន្ធ័សកម្មភាពផ្លូវភេទជាមួយក្មេងប្រុស ៣ នាក់ ដែលមានអាយុចន្លោះពី ១០ ទៅ ១៥ ឆ្នាំ។ អាជ្ញាធរកម្ពុជាបានអោយគេធ្វើបត្យាប័នលោក Jackson ទៅកាន់សហរដ្ឋអាមេរិក។ ក្នុងខែមិថុនា

ក្នុងការរួមផ្លូវភេទ, ស្ករសុកុឡា និងរូបិយវត្ថុក្នុងស្រុកជាច្រើនផងដែរ។ នៅរដូវក្ដៅ ឆ្នាំ ២០០៣ អ្នកសង្កេតការណ៍របស់នាយកដ្ឋានពង្រើងការងារផ្នែកគយ និងអន្តោប្រវេសន៍បានដឹងរឿងលោក **សេលចេន** តាមរយៈការប្រាស្រ័យទាក់ទងរវាងគាត់ និងក្មេងស្រីហ្វីលីពីនពីរនាក់ រួមទាំងរឿងដែលគាត់មានគំរោងរួមភេទជាមួយក្មេងស្រីទាំងអស់នោះនៅទីនោះ។ លោក **សេលចេន** ត្រូវបានកាត់ឱ្យជាប់ពន្ធនាគារ ២០ ឆ្នាំ ក្នុងខែមីនា ឆ្នាំ ២០០៥។ លើសពីនេះទៅទៀត គាត់ត្រូវបានគេឱ្យចុះបញ្ជីជាជនល្មើសផ្លូវភេទ ហើយនៅតែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការអស់មួយជីវិត។ ទោះបីជាករណីនេះមិនបានពាក់ព័ន្ធជាមួយប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ក៏វាបង្ហាញនូវលទ្ធភាពក្នុងការទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារមិនឱ្យកើតឡើងជាលើកដំបូង បន្ថែមលើនេះទៅទៀត លោក សេលចេន ឥឡូវនេះត្រូវបានដឹងដល់អាជ្ញាធរ និងអំពើរបស់គាត់ត្រូវបានគេតាមដាន ដូច្នេះវាអាចមានលទ្ធភាពតិចតួចណាស់ដែលគាត់នឹងប្រព្រឹត្តបទល្មើសនេះម្តងទៀត។

លោក Richard Schmidt មានអាយុ ៦១ ឆ្នាំ ធ្លាប់មានប្រវត្តិធ្វើបាបក្មេងប្រុសជាច្រើន។ គាត់ជាប់ពន្ធនាគារ ១៣ ឆ្នាំ (អាយុកាលនៃការជាប់ពន្ធនាគារគឺ ១៨ឆ្នាំ) ក្រោយពីត្រូវបានតុលាការប្រកាសថា មានទោសដោយសារការរំលោភជាច្រើនដងលើក្មេងប្រុសម្នាក់ក្នុង Baltimore។ ក្នុងឆ្នាំ ២០០៣ គាត់បានរត់គេចខ្លួន ក្រោយពីចេញដីការចាប់ខ្លួន បន្ទាប់ពីអ្នកសង្កេតការណ៍បានរកឃើញថា គាត់បានព្យាយាមថតរូបអាសអាភាសក្មេងប្រុស។ ប៉ូលីសហ្វីលីពីនបានចាប់



ទេសចរណ៍, បុគ្គលិកសណ្ឋាគារ, បុគ្គលិកផ្ទះសំណាក់, មេបន, ព្រមទាំងកុមារផ្ទាល់តែម្តង។ ជនបរទេស ទាំងជនដែលស្នាក់នៅយូរ ហើយនឹងភ្ញៀវទេសចរអាចដើរតួនាទីជាអន្តរការីសំរាប់ភ្ញៀវទេសចរនាពេលអនាគត ដោយប្រាប់មិត្តភ័ក្តិរបស់ពួកគេអំពីបទពិសោធន៍ផ្លូវភេទ ហើយនឹងរបៀបស្វែងរកសេវាកម្មផ្លូវភេទ ទាំងតាមអ៊ីមែល ឬក៏នៅពេលដែលពួកគេត្រឡប់ទៅដល់ប្រទេសកំនើតវិញ។

## **៣.១ អ្នកបើកបរតាក់ស៊ី និងអ្នករត់ម៉ូតូឌុប**

ផ្អែកលើការស្រាវជ្រាវតាមឯកសារ ហើយនឹងកិច្ចសំភាសន៍ជាមួយមនុស្សផ្សេងៗ ដែលធ្វើការផ្នែកខុសៗគ្នាអ្នករត់តាក់ស៊ី និងអ្នករត់ម៉ូតូឌុបជារឿយៗទំនងជាមនុស្សដែលដើរតួជាអន្តរការីរវាងជនដែលនឹងអាចក្លាយជាជនល្មើស និងកុមាររងគ្រោះ[៣១]។ ភ្ញៀវទេសចរអាចនឹងរកអ្នករត់តាក់ស៊ី ហើយស្នើអោយពួកគេនាំទៅរកផ្ទះបន ដែលមានស្ត្រីរកស៊ីផ្លូវភេទដែលមានអាយុលើស ១៨ ហើយនឹងក្រោមអាយុ ១៨ ឆ្នាំ ទាំងជនជាតិខ្មែរទាំងជនជាតិចិន ដែលអ្នកបើកបរនោះធ្វើ ដូច្នេះទំនងជាដើម្បីរកលុយក្រៅ (យោងទៅលើភ្នាក់ងារទេសចរណ៍ភ្នំពេញ)។ ជនបរទេសអាចស្នើអោយអ្នករត់តាក់ស៊ីស្វែងរកស្ត្រីរកស៊ីផ្លូវភេទជាអនីតិជនដើម្បីរួមភេទ។ អ្នកបើកបរនឹងស្វែងរកកុមារ ហើយនាំនាងទៅអោយភ្ញៀវទេសចរ

[31] Grillot, Caroline for Action pour les Enfants (APLE), *“Street Paedophilia” in Cambodia – A Survey on Phnom Penh’s suspects and victims*, sponsored by the British Embassy in Cambodia, September 2005; Lisa Smith, *Suffer the Children*, Weekend Standard, June 18-19, 2005 at http://www.thestandard.com.hk/stdn/std/Weekend/GF18Jp03.html; interviews with Sunway Hotel, Apsara Tours Co. Ltd. (Phnom Penh and Siem Reap), Hanuman Tourism Voyages, Sokun Travel and Tours LTD, Angkor Tourist Guide Association (ATGA) and the Department of Tourism in Siem Reap and Sihanouk ville.

ដើម្បីរួមភេទ។ ប៉ុន្តែញឹកញាប់ណាស់ ដែលភ្ញៀវទេសចរភាគច្រើននឹងស្នើអោយអ្នករត់ម៉ូតូឌុបនាំពួកគេទៅកាន់កន្លែង ដែលពួកគេអាចស្វែងរកសេវាកម្មផ្លូវភេទដោយមិនបានកំណត់នូវអាយុ ដែលពួកគេចង់បាននោះទេ (អ្នករត់ម៉ូតូឌុបម្នាក់នៅក្រុងព្រះសីហនុបានប៉ាន់ស្មានថា មាន ៣០៥ នៃអតិថិជនរបស់គាត់បានស្នើដូច្នេះ)។ ជាធម្មតា គាត់នាំអតិថិជនទៅកាន់ភូមិថ្មី ដែលជាតំបន់ផ្ទះបនដ៏មានប្រជាប្រិយភាពក្នុងក្រុងព្រះសីហនុ។ ក៏ប៉ុន្តែមានភ្ញៀវដែលស្នើសុំស្ត្រីក្មេងផងដែរ។ អ្នកបើកបរដែលត្រូវបានសំភាសនោះ មិនអាចប៉ាន់ស្មាននូវអាយុរបស់ស្ត្រីបានទេ ក៏ប៉ុន្តែគាត់បាននិយាយថា ពួកគេក្មេងហើយតូចៗ។ អ្នករត់ម៉ូតូឌុបដ៏ទៃទៀតដែលត្រូវបានសួរក្នុងក្រុងព្រះសីហនុបាននិយាយថា គាត់បានសួរភ្ញៀវរបស់គាត់ថា តើពួកគេមានចំណាប់អារម្មណ៏ចង់ស្វែងរកស្ត្រីដើម្បីរួមភេទដែរឬទេ ប្រហែលមួយក្នុងចំនោមដប់ឆ្លើយនូវចំលើយវិជ្ជមាន ដូច្នេះគាត់ក៏នាំពួកគេទៅរកផ្ទះបន។ គាត់ក៏បាននាំស្ត្រីដែលមានអាយុពី ១៥ ទៅ ១៧ឆ្នាំ ទៅកាន់ផ្ទះសំណាក់របស់ភ្ញៀវតាមសំណើរ (តាមការប៉ាន់ស្មានមានមួយ ឬពីរនាក់ក្នុងចំនោម ១០នាក់)។ អ្នករត់ម៉ូតូឌុបម្នាក់ពីសៀមរាបបាននិយាយថា ជាធម្មតាភ្ញៀវបានស្នើអោយគាត់រកស្ត្រីសំរាប់ដេកមួយយប់ ក្រោយមកគាត់ក៏ស្វែងរកស្ត្រីដែលរកស៊ីផ្លូវភេទ ហើយនាំនាងទៅកាន់សណ្ឋាគារ ឬក៏ផ្ទះសំណាក់របស់ភ្ញៀវ។ អ្នករត់ម៉ូតូឌុបម្នាក់ទៀតបាននិយាយថា ភ្ញៀវគ្រាន់តែសួររកកន្លែងបំរើសេវាកម្មផ្លូវភេទប៉ុណ្ណោះ ហើយការទំនាក់ទំនងជាក់ស្តែងជាមួយកុមារ ឬក៏ស្ត្រីវ័យក្មេងធ្វើឡើងដោយភ្ញៀវផ្ទាល់តែម្តង។ ប៉ុន្តែអ្នករត់ម៉ូតូឌុបម្នាក់ទៀតមកពីសៀមរាបបានអះអាងថា ជនទាំងនោះ



កុមារ រួមមានរូបភាពអាសអាភាសលើកុមារ និងទេសចរណ៏ផ្លូវភេទលើកុមារ។ វាបង្កើតឱ្យមានស្ថាប័នអនុវត្តច្បាប់ ដែលមានបំណងការពារកុមារនៅក្នុងស្រុក និងនៅបរទេស។

តំណាក់កាលនេះ វាមានតំលៃណាស់ក្នុងការលើកឡើងយ៉ាងលំអិតអំពីករណី ពីរ បី ខាងក្រោមនេះ។ លោក Michael Clark ដែលមានអាយុ ៧0 ឆ្នាំ គឺជាពលរដ្ឋអាមេរិកដំបូងគេ ដែលត្រូវបានគេចោទប្រកាន់ពីបទប្រព្រឹត្តិផ្លូវភេទលើកុមារស្ថិតនៅក្រោមច្បាប់ PROTECT។ គាត់ត្រូវបានចាប់ខ្លួន ហើយធ្វើបត្យាប័នទៅកាន់សហរដ្ឋអាមេរិកពីបទរួមភេទជាមួយនឹងក្មេងប្រុសពីរនាក់ដែលមួយនាក់មានអាយុ ១០ ឆ្នាំ និង ម្នាក់ទៀត ១៣ ឆ្នាំ។ ចុងក្រោយគាត់បានសារភាពថា គាត់បានប្រព្រឹត្តដូចការចោទប្រកាន់ទៅលើគាត់ពិតប្រាកដមែន។ លោក **ក្លាក** បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជាជាច្រើនដងអស់រយៈពេលជាច្រើនឆ្នាំ ហើយក្នុងអំឡុងពេលនោះគាត់ត្រូវបានគេចោទប្រកាន់ថា គាត់បានធ្វើបាបកុមាររវាងពី ៤0 ទៅ ៥0នាក់។ ក្នុងខែមិថុនា ឆ្នាំ ២00៤ គាត់ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារ៨ឆ្នាំ។ លោក ចន សេលចេន មានអាយុ ៨៥ ឆ្នាំ ត្រូវបានចាប់ខ្លួននៅឯ ព្រលានយន្តហោះអន្តរជាតិឡូសអង់ចេឡេសក្នុងខែតុលា ឆ្នាំ ២00៣ ដោយមានភ្ជាប់នូវរូបភាពអាសអាភាស ហើយត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងធ្វើដំណើរទៅកាន់ប្រទេសហ្វីលីពីន ក្នុងគោលបំណងមានសកម្មភាពផ្លូវភទជាមួយនឹងកុមារីជាអនីតិជន (មានអាយុពី ៩ ទៅ ១២ ឆ្នាំ)។ លើសពីសំភារៈអាសអាភាសលោក **សេលចេន** ក៏មានឧបករណ៏ជំនួយសំរាប់ប្រើប្រាស់

លើអនីតិជននៅបរទេស ហើយកិច្ចការនេះគឺត្រូវបានអនុវត្តដោយជោគជ័យជាច្រើនលើកមកហើយ។ ជនសង្ស័យចំនួន ៣នាក់ ដែលត្រូវបានចាប់ខ្លួនក្រោយពីមានការស៊ើបអង្កេតដោយអង្គការ APLE ត្រូវបានធ្វើបត្យាប័នទៅកាន់សហរដ្ឋអាមេរិក ដែលក្នុងចំណោមពួកគេនោះគឺ មានពីរនាក់ មួយនាក់ ត្រូវបានកាត់អោយជាប់ពន្ធនាគារ ៨ឆ្នាំ និងមួយនាក់ទៀតគឺ ១៥ឆ្នាំ ចំណែកឯអ្នកទីបីវិញ គឺកំពុងរង់ចាំការកាត់សេចក្តី។ តាំងពីច្បាប់នេះត្រូវបានអនុម័តព្រះរាជអាជ្ញាត្រូវការតែបញ្ជាក់ និងបង្ហាញភស្តុតាងថា ជនជាប់ចោទបានប្រព្រឹត្តសកម្មភាពបទល្មើសផ្លូវភេទលើអនីតិជននៅបរទេសដោយមិនចាំបាច់ ( ដូចជាករណីមុនៗ) បង្ហាញថា ពួកគេចាកចេញពីសហរដ្ឋអាមេរិក ដោយមានគោលបំណង (រួចជាស្រេចថា) ធ្វើដូច្នេះនោះទេ។ ភាពជោគជ័យក្នុងការកាត់ទោសជនជាតិអាមេរិកគឺដោយសារតែការប្តេជ្ញាចិត្តរបស់អាមេរិក ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ, ការទំនាក់ទំនងសហប្រតិបត្តិការដ៏ធំដែលមានរវាងរដ្ឋាភិបាលអាមេរិកនិងកម្ពុជា, ព្រមទាំងទំនាក់ទំងល្អដែលសហរដ្ឋអាមេរិកមានជាមួយផ្នែកអង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា។ នាយកដ្ឋានពង្រើងការងារអន្តោប្រវេសន៏និងគយសហរដ្ឋអាមេរិកមានទីស្នាក់ការធំក្នុងតំបន់របស់ខ្លួនក្នុងទីក្រុងបាងកកនិងភ្នាក់ងារជាច្រើនទៀតនឹងមកដល់ប្រទេសកម្ពុជា ដើម្បីជួយប៉ូលីសក្នុងស្រុកក្នុងការស៊ើបអង្កេតរឿងក្តីដែលពាក់ព័ន្ធនឹងពលរដ្ឋអាមេរិក មុនពេលជនសង្ស័យត្រូវបានគេធ្វើបត្យាប័នទៅកាន់សហរដ្ឋអាមេរិក។ ក្រសួងសន្តិសុខជាតិផ្តួចផ្តើមឱ្យមាន "ប្រតិបត្តិការក្រុមប្រម៉ាញ់" ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើ



ស្វែររកបុរសពេញវ័យរកស៊ីផ្លូវភេទ មិនមែនកុមារទេ ហើយគាត់ត្រូវបានគេផ្តល់លុយឱ្យពី ៥០ ទៅ ១០០ ដុល្លា ដើម្បីដេកជាមួយភ្ញៀវ (ដែលត្រូវបានគាត់បដិសេធ)។ គាត់ក៏បាននាំភ្ញៀវទៅកាន់ផ្ទះបនឈ្មោះហូលីវូដ ដែលជាកន្លែងដ៏មានប្រជាប្រិយភាព ហើយដែលគាត់ស្នើអោយមេបនគិតលុយបន្ថែម/លើសចំពោះអ្នករកស៊ីផ្លូវភេទ ដើម្បីគាត់អាចទទួលបានលុយកំរៃជើងសារលើសបន្ថែមទៀតផងដែរ។

ពុំមានការធានាណាមួយ ដែលថាអ្នកម៉ូតូឌុបនឹងទទួលបានប្រាក់បន្ថែមក្រៅសំរាប់ការនាំភ្ញៀវទៅកាន់ផ្ទះបននោះទេ ទោះបីជាពេលខ្លះពួកគេមិនបានទទួលប្រាក់បន្ថែមនោះក៏ដោយ ក៏ជាញឹកញាប់ពួកគេបានទទួលប្រាក់បន្ថែមនោះ (បានទទួលច្រើនជាងពេលមិនបានទទួល)។ ជាធម្មតា ប្រសិនបើបុរសម្នាក់ជ្រើសរើសនារីម្នាក់ពីផ្ទះបន ដែលអ្នកម៉ូតូឌុបនាំគាត់ទៅអ្នកម៉ូតូឌុបនឹងទទួលបានលុយកំរៃជើងសារពីផ្ទះបននោះ។ ប៉ុន្តែបើសិនជាផ្ទះបននោះគឺ ជាផ្ទះបនដ៏មានប្រជាប្រិយភាព គឺពួកគាត់មិនបានទទួលប្រាក់នោះទេ។ យោងទៅលើអ្នកម៉ូតូឌុបម្នាក់មកពីទីក្រុងព្រះសីហនុបានអោយដឹងថា គាត់ទទួលលុយកំរៃជើងសារពី ១ដុល្លា ទៅ ២ដុល្លា ពីផ្ទះបន។ ប៉ុន្តែអ្នកម៉ូតូឌុបដ៏ទៃទៀតបានពន្យល់ថា ដើម្បីទទួលបានលុយកំរៃជើងសារ គាត់ត្រូវប្រាប់ឱ្យភ្ញៀវឱ្យថ្លៃឈ្នួលទៅអ្នករកស៊ីផ្លូវភេទ ១២ដុល្លា ទោះបីជានាងទទួលបានតែ ១០ដុល្លា តែប៉ុណ្ណោះក៏ដោយធ្វើដូច្នេះគាត់ទទួលបានលុយក្រៅ ២ដុល្លា។ តាមពិតទៅជាធម្មតាភ្ញៀវនឹងផ្តល់ពី ១ដុល្លា ទៅ ២ដុល្លា ទៅអោយអ្នកម៉ូតូឌុប។ វាហាក់បីដូចជាតំលៃកំរៃជើងសារខ្ពស់ក្នុងក្រុង

សៀវមរាបសំរាប់សេវាកម្មអ្នកសំរបសំរួល។ យោងទៅលើអ្នកម៉ូតូឌុបម្នាក់នៅទីនោះបានអោយដឹងថា ស្រ្តីទទួលបាន ២០ដុល្លា សំរាប់មួយយប់ពេញ។ ទាំងស្រ្តីទាំងភ្ញៀវនឹងផ្តល់អោយអ្នកម៉ូតូឌុបប្រហែលជា ២ដុល្លា។ អ្នកម៉ូតូឌុបម្នាក់ទៀតនៅទីក្រុងភ្នំពេញបាននិយាយថា វាជារឿងកម្រណាស់ក្នុងការទទួលបានលុយកំរៃជើងសារសំរាប់ការនាំមនុស្សទៅកាន់ផ្ទះបន។ បើសិនគាត់ទទួលបានគាត់ទទួលបានតែ ១ដុល្លា ប៉ុណ្ណោះ។ ប៉ុន្តែគាត់មិនដែលនាំកុមារទៅកាន់សណ្ឋាគារ ឬផ្ទះសំណាក់របស់ភ្ញៀវទេ។ អ្នកម៉ូតូឌុបម្នាក់ទៀតក្នុងទីក្រុងភ្នំពេញត្រូវបានស្នើសុំដោយអ្នកទទួលភ្ញៀវសណ្ឋាគារ ជាញឹកញាប់អោយនាំអ្នករកស៊ីផ្លូវភេទទៅកាន់សណ្ឋាគារពីព្រោះជាធម្មតាគាត់ទទួលបាន ១ដុល្លា ពីសណ្ឋាគារនៅពេលដែលគាត់នាំទៅដល់។ នៅពេលដែលអ្នករត់តាក់ស៊ីនាំស្រីទៅកាន់សណ្ឋាគារ ឬផ្ទះសំណាក់ជាធម្មតាពួកគេនឹងរង់ចាំនៅទីនោះ រហូតដល់នាងបំរើភ្ញៀវចប់។ បន្ទាប់មកអ្នកបើកបរយកថ្លៃឈ្នួលធ្វើដំណើរពីនាងព្រមទាំងថ្លៃរង់ចាំ ឧទាហរណ៍ ប្រសិនបើនាងទទួលបាន ២០ដុល្លា គាត់យ៉ាងហោចណាស់ក៏យក ៥ដុល្លា ដែរ។

គេទទួលស្គាល់ថា មិនមែនឱ្យតែអ្នករត់ម៉ូតូឌុបសុទ្ធតែពាក់ព័ន្ធក្នុងការសំរបសំរួលក្នុងទេសចរណ៍ផ្លូវភេទទាំងអស់គ្រប់គ្នានោះទេ។ ឧទាហរណ៍ នៅក្នុងទីក្រុងភ្នំពេញក្នុងចំណោមអ្នកម៉ូតូឌុប ៧ នាក់ ដែលត្រូវបានគេជួបសួរមានតែ ៣ នាក់ ប៉ុណ្ណោះដែលបានទទួលស្គាល់ថា ខ្លួនជាអ្នកសំរបសំរួល ហើយបានឆ្លើយនូវសំនួររបស់អ្នកស្រាវជ្រាវ។ ក្នុងចំណោម ៤ នាក់ ទៀត មាន ២ នាក់ បានអះអាងថា ពួកគេមិនដែលមានភ្ញៀវបរទេសទេ ម្នាក់ទៀតបាននិយាយថា គាត់មិន



ដើម្បីកុមារមួយចំនួនប៉ាន់ស្មានថា ក្នុងចំណោមភ្ញៀវទេសចរផ្លូវភេទនៅបរទេសគឺ ២៥ % មកពីសហរអាមេរិក។ ទោះបីជាទិន្នន័យនេះមិនអាចត្រឹមត្រូវក៏ដោយជនជាតិអាមេរិក ដែលរួមភេទជាមួយកុមារនៅបរទេសត្រូវបានគេគិតថា មានចំនួនរាប់ពាន់ ដែលមានជនអនាចារចំតួពិតប្រាកដ, ភ្ញៀវទេសចរធម្មតា, និងអ្នករកស៊ី ដែលយកចំណេញពីការអនុវត្តន៍ច្បាប់ធូររលង់"[៥០] ។ វាមិនច្បាស់ថា តើពីព្រោះតែមានជនជាតិអាមេរិកជាច្រើន ដែលធ្វើដំណើរទៅកាន់ប្រទេសមិនសូវមានការអភិវឌ្ឍន៍ ហើយពាក់ព័ន្ធក្នុងសកម្មភាពផ្លូវភេទជាមួយនឹងអនីតិជននៅទីនោះរឺថា តើដោយសារតែមានការពាក់ព័ន្ធយ៉ាងសកម្មដោយរដ្ឋាភិបាលអាមេរិកដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។ មានករណីជាច្រើននៃទេសចរណ៍ផ្លូវភេទទាក់ទងនឹងជនជាតិអាមេរិក ដែលត្រូវបានធានាឱ្យមានចំណាត់ការយ៉ាងតឹងរឹងពីរដ្ឋាភិបាលអាមេរិក ដែលនេះគឺអាចធ្វើជាគំរូមួយ ដើម្បីត្រូវបានអនុវត្តដោយរដ្ឋាភិបាលដ៏ទៃទៀត។ ច្បាប់ស្តីពីវិធីសាស្រ្តកាត់ទោស និងមធ្យោបាយដ៏ទៃទៀតក្នុងការលុបបំបាត់ការកេងប្រវ័ញ្ចលើកុមារបច្ចុប្បន្នត្រូវបានអនុម័តក្នុងឆ្នាំ ២០០៣ ដោយរដ្ឋាភិបាលអាមេរិក ដើម្បីលើកកំពស់នូវលទ្ធភាពដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។ ច្បាប់នេះចែងថា ការធ្វើដំណើរទៅកាន់ប្រទេសដ៏ទៃទៀតដើម្បីគោលបំណងប្រព្រឹត្តបទល្មើសផ្លូវភេទជាមួយអនីតិជន គឺជាបទល្មើសឧក្រិដ្ឋ។ ផ្នែក ១០៥ ផ្តល់នូវទោសជាប់ពន្ធនាគារជាអតិប្បរមា ៣០ ឆ្នាំ។ សហរដ្ឋអាមេរិកនឹងកាត់ទោសជនជាតិរបស់ខ្លួនពីបទរំលោភផ្លូវភេទ

[50] Lichtblau, E. and Dao, J., *US is Now Pursuing Americans Who Commit Sex Crimes Overseas*, The New York Times, National, Tuesday June 8, 2004.

កុំព្យូទ័រពីផ្ទះរបស់ជនអនាចារ ប៉ុន្តែពួកគេមិនដឹងនូវរបៀបប្រើប្រាស់កុំព្យូទ័រនោះ។ ឯកសារនៅក្នុងកុំព្យូទ័រខ្លះគឺ វាអាចបំផ្លិចបំផ្លាញដោយខ្លួនឯង/ដោយស្វ័យប្រវត្តិ (ជនល្មើសធ្វើយ៉ាងនេះក្នុងគោលបំណងបំបាត់ភស្តុតាង) ដូច្នេះប្រសិនបើយើងមិនបានវាយបញ្ចូលលេខកូដរបស់វាឱ្យបានត្រឹមត្រូវទេនោះ ឯកសារទាំងអស់នេះនឹងអាចលុបចោលបាត់ដោយខ្លួនឯង/ដោយស្វ័យប្រវត្តិ។ ដោយសារហេតុផលនេះហើយទើបយើងចាត់ទុកថា វាជាការសំខាន់ណាស់ដែលថា អ្នកដែលប៉ុនប៉ងព្យាយាមដកយកទិន្នន័យពីកុំព្យូទ័រនេះ គឺត្រូវតែជាអ្នកមានជំនាញឯកទេស។ ជាកុសលកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក គឺល្អខ្លាំងណាស់ជាពិសេសជាមួយនឹងនាយកដ្ឋានពង្រឹងការងារអន្តោប្រវេសន៍ និងគយសហរដ្ឋអាមេរិក។ ដូច្នេះនៅពេលដែលប៉ូលីសចូលទៅក្នុងសណ្ឋាគារ ឬលំនៅឋានឯកជន ដើម្បីចាប់ជនសង្ស័យពួកគេដកយកនូវអ្វីផ្សេងៗ ដែលពួកគេបានរកឃើញ ទោះបីជាពួកគេមិនច្បាស់នូវរបស់របរនោះអាចជួយនូវការស៊ើបអង្កេតដោយរបៀបណាក៏ដោយ ពីព្រោះពួកគេអាចបញ្ជូនភស្តុតាងទាំងនោះទៅឱ្យអ្នកស៊ើបអង្កេតសហរដ្ឋអាមេរិកវិភាគ[៤៩]។

## ៧.១ និយាយដោយខ្សែកពីករណីសហរដ្ឋអាមេរិក

ជនជាតិអាមេរិក ទំនងជាមានលក្ខណៈពិសេសលេចធ្លោជាងពួកបច្ចឹមប្រទេសដទៃ ដែលត្រូវបានគេស្គាល់ថា ជាជនល្មើសផ្លូវភេទ។ "ក្រុមអ្នកតស៊ូមតិ

[49] Minutes of Presentation by Gary Phillips, US Immigration & Customs Service, *US Campaign Against Child Sex Tourism*, given at the Child Sex Tourism Prevention Workshop, 28 February & 01 March 2005.



ដែលដឹងអ្វីសោះពីរឿងទេសចរណ៍ផ្លូវភេទលើកុមារ ហើយអ្នកទី៤ មានការភ័យខ្លាចក្នុងការឆ្លើយនូវសំនួរ ដោយសារគាត់ខ្លាចមានបញ្ហា។ បុគ្គលិកក្រុមហ៊ុនទេសចរណ៍ម្នាក់បានអះអាងថា អ្នកម៉ូតូឌុបមួយចំនួននឹងនាំភ្ញៀវទៅកាន់ផ្ទះបន ប៉ុន្តែពួកគេមិននាំភ្ញៀវទៅកាន់កន្លែងដែលផ្តល់ស្រីអនីតិជនសំរាប់ការរួមភេទនោះទេ ពីព្រោះពួកគេខ្លាចត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅក្នុងពន្ធនាគារ។ ការសិក្សាមួយ ដែលត្រូវបានគេបោះផ្សាយកាលពីឆ្នាំទៅមិញបានលើកឡើងអំពីបទបញ្ជាផ្ទៃក្នុងថ្មី ដែលហាមឃាត់អ្នកម៉ូតូឌុបក្នុងការឌុបបុរសបច្ចឹមប្រទេស ហើយនឹងកុមារកម្ពុជារួមគ្នាតាមម៉ូតូ[៣២]។ ទោះបីជាបទបញ្ជាបែបនេះទំនងជាមានការលំបាកដើម្បីអនុវត្តយ៉ាងណាក៏ដោយ ក៏វាបានបង្ហាញនូវឆន្ទៈក្នុងនាមជាអាជ្ញាធរមូលដ្ឋានដើម្បីប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទលើកុមារដែរ។

## ៣.២ បុគ្គលិកសណ្ឋាគារ និងផ្ទះសំណាក់

តួនាទីរបស់អន្តរការីដែលបានធ្វើដោយបុគ្គលិកសណ្ឋាគារ ឬផ្ទះសំណាក់នោះប្រហែលជាពាក់ព័ន្ធនឹងបុគ្គលិកទទួលភ្ញៀវខាងមុខ ដែលរៀបចំឱ្យមានស្រីមករកភ្ញៀវក្នុងបន្ទប់សណ្ឋាគាររបស់ពួកគេ។ ម្យ៉ាងវិញទៀត ម្ចាស់សណ្ឋាគារប្រហែលជាបិទភ្នែកធ្វើមិនឃើញនូវអ្វីដែលកំពុងកើតឡើងចំពោះមុខ ពីព្រោះពួកគេខ្លាចបាត់បង់នូវអតិថិជន។ បុគ្គលិកសណ្ឋាគារ និងផ្ទះសំណាក់ភាគច្រើនដែលត្រូវបានសួរបានអះអាងថា ភ្ញៀវរបស់ពួកគេបាននាំអ្នករកស៊ីផ្លូវភេទពេញវ័យ

[32] Grillot, Caroline for Action pour les Enfants (APLE), *"Street Paedophilia" in Cambodia – A Survey on Phnom Penh's suspects and victims*, sponsored by the British Embassy in Cambodia, September 2005; p. 32. The information has not yet been confirmed, however.

មកកាន់បន្ទប់ជាប្រក្រតី។ មិនសូវមានគេរាយការណ៏ថា កុមារត្រូវបានគេនាំមកជាមួយភ្ញៀវនោះទេ។ បុគ្គលិកសណ្ឋាគារ និងផ្ទះសំណាក់ជាច្រើនជឿជាក់ថាភ្ញៀវដឹងថា វាជារឿងខុសច្បាប់ក្នុងការពាក់ព័ន្ធក្នុងសកម្មភាពផ្លូវភេទជាមួយកុមារ (ដឹងមកពីផ្ទាំងរូបភាព និងខ្សែភាពយន្ត ដែលមាននៅតាមផ្លូវធំៗ និងក្នុងព្រលានយន្តហោះ)។ ជាធម្មតា ភ្ញៀវនឹងសួរបុគ្គលិកសណ្ឋាគារនូវកន្លែងដែលពួកគេអាចស្វែងរកសេវាកម្មផ្លូវភេទ ប៉ុន្តែកម្រសួររកអំពីការរួមភេទជាមួយកុមារណាស់។ បុគ្គលិកភេទស្រីដែលយើងនិយាយជាមួយ មិនដែលត្រូវបានភ្ញៀវសួររកសេវាកម្មផ្លូវភេទទេ តាមដែលគេអះអាងបានអោយដឹងថា ពីព្រោះពួកគេជាស្រី។ សមាជិកបុគ្គលិកខ្លះបាននិយាយថា ភ្ញៀវមិនសួររកសេវកម្មផ្លូវភេទដោយត្រង់ៗនោះទេ ប៉ុន្តែពួកគេសួររកស្រីដែលអាចផ្តល់នូវការម៉ាស្សា ឬបំពេញនូវការសប្បាយ។ បុរសម្នាក់ដែលកំពុងធ្វើការនៅក្រុមហ៊ុនទេសចរណ៏ក្នុងខេត្តសៀមរាប ហើយដែលធ្លាប់ធ្វើការជាអ្នកទទួលភ្ញៀវនៅក្នុងសណ្ឋាគារបានឱ្យដឹងថា តាមបទពិសោធន៏របស់គាត់ជារឿយៗភ្ញៀវសួររកការរួមភេទ ហើយវាមាននៅគ្រប់សណ្ឋាគារទាំងអស់។ បុគ្គលិកភ្នាក់ងារទេសចរណ៏ម្នាក់ទៀតបានពន្យល់ថា បុគ្គលិកសណ្ឋាគារដែលធ្វើការវេនយប់ត្រូវបានគេដឹងថា មានការសំរបសំរួលដើម្បីយកស្ត្រីទៅឱ្យភ្ញៀវជាពិសេសសំរាប់លុយទឹកតែតិចតួច។

មានរបាយការណ៏ ២-៣ ចំពោះភ្ញៀវដែលព្យាយាម ហើយទទួលបានជោគជ័យក្នុងការនាំស្រីក្មេងទៅកាន់បន្ទប់សណ្ឋាគាររបស់គេ។ យោងទៅលើការអនុវត្តន៏របស់សណ្ឋាគារធុនកណ្តាលនៅក្នុងទីក្រុងភ្នំពេញបានឱ្យដឹងថា ឧទាហរណ៏



វាមានការលំបាកក្នុងការដោះស្រាយជាមួយកុមាររងគ្រោះ។ ពួកគេបានជួបប្រទះនៅរឿងដ៏តក់ស្លុតដ៏គួឱ្យរន្ធត់បែបនេះ ហើយត្រូវបានគេធ្វើឱ្យមានការផ្លាស់ប្តូរគំនិតដែលពាក់ព័ន្ធអំពីបញ្ហាផ្លូវភេទ ដូច្នេះធ្វើឱ្យពួកគេលែងដឹងអ្វីដែលខុស និងអ្វីដែលត្រូវ។ ក្នុងវប្បធម៌កម្ពុជាកុមារស៊ាំទៅនឹងការថ្នាក់ថ្នម/ការប៉ះពាល់រាងកាយដ៏ច្រើនដែលគួឱ្យកត់សំគាល់រវាងឪពុកម្តាយ និងកុមារ ដូច្នេះកុមារមិនអាចសំគាល់បានថា ការប៉ះពាល់របៀបនេះ/ក៏រិតនេះ ឬរបៀបនោះវាជាការការស្មោះត្រង់ ឬមានបំណងចង់បំពាន/ចង់ចំណេញលើរាងកាយកុមារជាដើម។ ម្តាយខ្មែរមានទំលាប់វាយនូវតំបន់កេរ្តិ៍ខ្មាស់របស់កុមារលេង ដោយមិនមានបំណងទាក់ទងនឹងបញ្ហាផ្លូវភេទនោះទេ។ ជាលទ្ធផលការប៉ះពាល់ស្រដៀងៗគ្នានេះដែរដែលធ្វើដោយជនបរទេសធ្វើឱ្យកុមារពិបាកសំគាល់ថា សកម្មភាពបំពានលើផ្លូវភេទដែលជនល្មើសបានប្រព្រឹត្ត វាជាសកម្មភាពបំពានលើផ្លូវភេទពិតប្រាកដ ឬយ៉ាងណានោះទេ។

ទំហំនៃភស្តុតាងដែលអាចត្រូវបានប្រើក្នុងច្បាប់នៃតុលាការកម្ពុជាគឺ គេកត់សំគាល់ថា មិនមានលក្ខណៈទូលំទូលាយនោះទេ។ ជាអកុសលមិនមែនគ្រប់ភស្តុតាងទាំងអស់ត្រូវបានគេទទួលយកនោះទេ។ គេត្រូវការភស្តុតាងពិតជាក់ស្តែងដើម្បីយកទៅកាត់ទោសចំពោះជនដែលត្រូវបានសង្ស័យថាប្រព្រឹត្តបទល្មើសផ្លូវភេទអោយបានជោគជ័យ។ នេះគឺជាឧបសគ្គដែលប៉ូលីសត្រូវពុះពារមន្ត្រីមួយចំនួនខ្វះនូវចំណេះដឹងដែលតំរូវអោយមានក្នុងការស៊ើបអង្កេតដូចជា ចំណេះដឹងក្នុងការថែរក្សាការពារ និងវិភាគភស្តុតាង។ ឧទាហរណ៏ពួកគេអាចដកហូតយក

ឆាប់អាចចាប់ផ្តើមស្ថានីតិសម្បទា និងសមាហរណកម្មចូលក្នុងសង្គមជាតិ។ ជនរងគ្រោះដែលមិនមែនជាជនជាតិកម្ពុជា ត្រូវរង់ចាំរហូតដល់ការកាត់ទោសនោះបានចប់សព្វគ្រប់ (ក្នុងករណីដែលគេមានគំរោងបង្ហាញពីភស្តុតាងប្រឆាំងជនប្រព្រឹត្ត) មុនពេលដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍។

វាទំនងជាមិនសូវមានការទុកចិត្តចំពោះការអនុវត្តន៍ច្បាប់ និងរចនាសម្ព័ន្ធយុត្តាធិការនៅក្នុងចំណោមសាធារណៈជន។ ប្រជាជនមានការភ័យខ្លាចក្នុងការរាយការណ៍ជនសង្ស័យទៅអោយប៉ូលីស ប្រសិនបើខ្លួនបានឃើញគេដោះលែងជនល្មើស ពីព្រោះពេលជនល្មើសរួចខ្លួនមកវិញ គេប្រហែលជាអាចសំរេចចិត្តធ្វើការសងសឹក។ លើសពីនេះទៅទៀត ដំណើរការយុត្តាធិការមានរយៈពេលយូរហើយថ្លៃទៀតផង-មនុស្សជាច្រើនគេមិនចូលចិត្តធ្វើអ្វីដែលពួកគេដឹងថា វាត្រូវការចំណាយលុយច្រើននោះទេ។ ឥឡូវនេះមានវិធានការមួយចំនួនតូចដែលអាចយកមកអនុវត្តបាន ដើម្បីធ្វើឱ្យបទពិសោធន៏ដែលជនរងគ្រោះនោះបានឆ្លងកាត់មិនសូវមានការតក់ស្លុត។ អង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលជួយជនរងគ្រោះដោយការរំលោភផ្លូវភេទមានអារម្មណ៏ថា រហូតដល់មានការការពារគ្រប់គ្រាន់អាចត្រូវបានគេធានាដល់ជនរងគ្រោះ, មិនមានការគាបសង្កត់ណាមួយចំពោះពួកគេក្នុងការបង្ហាញភស្តុតាងក្នុងរឿងក្តីប្រឆាំងនឹងជនប្រព្រឹត្ត។ បច្ចុប្បន្ននេះលទ្ធភាពនៃជនសង្ស័យដែលត្រូវបានដោះលែងនៅតែកើតមាន ហើយឱកាសរបស់ជនសង្ស័យក្នុងការស្វែងរកការសងសឹកគឺពិតជាមាន។



សមាជិកបុគ្គលិកបានអនុញ្ញាតអោយភ្ញៀវនាំស្រ្តីវ័យក្មេងទៅកាន់បន្ទប់ ដោយមិនដឹងថា តើស្រ្តីទាំងនោះជានីតិជន ឬអនីតិជន។ បុគ្គលិកដែលត្រូវបានគេសួរបានប៉ាន់ស្មានថា អាយុរបស់ស្រ្តីដែលត្រូវបាននាំមកកាន់បន្ទប់ភ្ញៀវមានអាយុពី ១៦ ទៅ ២២ ឆ្នាំ។ ប្រសិនបើគេចូលដេកក្នុងសណ្ឋាគារជាមួយនឹងស្រី ដែលមិនទាន់គ្រប់អាយុពិតប្រាកដបុគ្គលិកមិនចង់ធ្វីនោះទេ ពីព្រោះវាអាចមានឥទ្ធិពលអវិជ្ជមានលើការរកស៊ីរបស់គេ ហើយនឹងទេសចរណ៏ជាទូទៅ។ ជារឿយៗភ្ញៀវសួរនៅកន្លែងទទួលភ្ញៀវខាងមុខ គឺសួររកបារដែលមានស្រី (ប៉ុន្តែមិនមានការបញ្ជាក់ពីអាយុទេ)។ ប្រសិនបើភ្ញៀវត្រូវការម៉ាស្សាក្នុងបន្ទប់បុគ្គលិកនឹងរៀបចំស្រ្តី ឬស្រ្តីវ័យក្មេងឱ្យទៅកាន់បន្ទប់ភ្ញៀវ ហើយនឹងផ្តល់ការរួមភេទផងដែរ ប្រសិនបើត្រូវការ។ ជាក់ស្តែងជាធម្មតា បុគ្គលិកសណ្ឋាគាររៀបចំបញ្ហាប្រភេទនេះ ។

ទោះបីជាយ៉ាងណាក៏ដោយ បុគ្គលិកសណ្ឋាគារមួយចំនួនដឹងនូវរបៀបចាត់វិធានការត្រឹមត្រូវ ប្រសិនបើពួកគេឃើញនូវលក្ខណៈសង្ស័យគឺ ពួកគេរាយការណ៏ពីហេតុការណ៏ដែលកើតឡើងនេះទៅប៉ូលីសតាមលេខ Hotline។ ទោះបីជាបញ្ហានោះមិនអាចកើតឡើងជាញឹកញាប់ដូចគេសង្ឃឹមយ៉ាងណាក៏ដោយ ក៏មានឧទាហរណ៏ ២-៣ របស់បុគ្គលិកសណ្ឋាគារដោយបានពន្យល់នូវច្បាប់កម្ពុជាចំពោះភ្ញៀវដែលស្នើរកការរួមភេទ។ បុគ្គលិកម្នាក់ពីសណ្ឋាគារធុនកណ្តាលក្នុងក្រុងសៀមរាបដែលត្រូវបានសំភាសបានប្រាប់អ្នកស្រាវជ្រាវថា ភ្ញៀវទេសចរបាននាំអនីតិជនទៅកាន់បន្ទប់សណ្ឋាគារ ទោះបីជាយ៉ាងណាក៏ដោយក៏គាត់មិនបានដឹង

អាយុពិតប្រាកដរបស់ស្ត្រីទាំងនោះទេ។ ដោយមិនចង់អោយភ្ញៀវរបស់គេខឹង សមាជិកបុគ្គលិកសណ្ឋាគារមិនតែងតែទប់ស្កាត់បញ្ហានេះទេ។

## ៣.៣ អ្នកនាំភ្ញៀវទេសចរ និងក្រុមហ៊ុនទេសចរណ៍

ភ្ញៀវទេសចរធ្វើដំណើរជាក្រុមមាននិន្នាការពឹងផ្អែកលើអ្នកនាំភ្ញៀវរបស់ពួកគេសំរាប់រឿងសំខាន់ៗ ព្រមទាំងដំបូន្មានក្នុងស្រុក។ ភ្ញៀវធ្វើដំណើរជាផ្នែកនៃក្រុមទេសចរណ៍ស្ទើរតែមិនអាចជៀសរួចពីការសួរអ្នកនាំភ្ញៀវរបស់គេរកកន្លែងសេវាកម្មផ្លូវភេទ។ ក្រុមហ៊ុនទេសចរណ៍ហាក់បីដូចជាត្រូវឆ្លើយតបដដែលៗចំពោះសំណួរស្តីពីបញ្ហានេះ : ប្រសិនបើអតិថិជនត្រូវការអ្វីមួយ-ព័ត៌មានប្រភេទណាមួយ-អ្នកនាំភ្ញៀវនៅទីនោះរង់ចាំជួយជានិច្ច ដូច្នេះពួកគេត្រូវតែឆ្លើយតបរាល់សំណួររបស់អតិថិជន។ "អតិថិជនជាស្តេច" ទ្រឹស្តីនេះត្រូវបានគេដកស្រង់យកមកអនុវត្តនៅក្នុងកាលៈទេសៈជាច្រើនគឺ មានន័យថា ភ្នាក់ងារទេសចរណ៍នឹងជួយអតិថិជនរបស់ពួកគេតាមវិធីណាក៏ដោយដែលពួកគេអាចទៅធ្វើបាន។ បុរសម្នាក់ដែលកំពុងធ្វើការឱ្យក្រុមហ៊ុនទេសចរណ៍បានប្រាប់អ្នកស្រាវជ្រាវថា ប្រសិនបើភ្ញៀវមានសំណួរ ដែលអ្នកនាំភ្ញៀវមិនអាចឆ្លើយបានវានឹងធ្វើអោយមានឥទ្ធិពលអវិជ្ជមានលើការរកស៊ីរបស់ពួកគេ។ ពួកគេប្រាប់អតិថិជននូវកន្លែងមានផ្ទះបនឬក៏ស្រី ប៉ុន្តែស្របពេលជាមួយគ្នានោះដែរ ពួកគេនឹងប្រាប់ដល់ភ្ញៀវអំពីច្បាប់និងបទបញ្ញាដែលពាក់ព័ន្ធក្នុងប្រទេសកម្ពុជា។ អ្នកដែលឆ្លើយនឹងសំណួររបស់អ្នកស្រាវជ្រាវបានទទួលស្គាល់ថា អ្នកនាំភ្ញៀវមានតួនាទីក្នុងការសំរបសំរួលការរកសេវាផ្លូវភេទសំរាប់ភ្ញៀវ ប៉ុន្តែពួកគេមិនអាចបញ្ជាក់អំពីអាយុនៃអ្នករកស៊ីផ្លូវភេទ



នេះ។ ៨ ខែ ក្រោយពួកគេបានត្រឡប់មកប្រទេសកម្ពុជា។ ទីបញ្ចប់ជនល្មើសត្រូវបានចោទប្រកាន់ និងកាត់ឱ្យជាប់ទោសពីបទថតរូបភាពអាសអាភាសលើកុមារ ក៏ប៉ុន្តែមិនមែនពីបទឧក្រិដ្ឋនៃការរំលោភកុមារដូចដែលគេបានចោទប្រកាន់កាលពីពេលមុននោះទេ។ ករណីនេះបង្ហាញនូវបញ្ហាជាច្រើនដែលត្រូវការដោះស្រាយដើម្បីកុំឱ្យបញ្ហាស្រដៀងៗគ្នានេះកើតឡើងនៅក្នុងករណីក្រោយៗទៀត។ ដោយមានភស្តុតាងច្រើនណាស់ដូចជា ភស្តុតាងជាក់ស្តែង និងរូបភាពអាសអាភាសប្រឆាំងនឹងជនសង្ស័យ ដូច្នេះគេមិនគួរមានការសង្ស័យណាមួយទៀតទេក្នុងការរំលោភនេះ។ ហេតុអ្វីបានជាបុរសនេះ មិនត្រូវបានចោទប្រកាន់អោយបានឆាប់? មិនចាំបាច់មានការពន្យារពេលការឃុំខ្លួនមុនពេលកាត់ទោសឱ្យលើសពី ៦ ខែ ដោយមិនបានចោទប្រកាន់គាត់ពីបទល្មើសដែលពាក់ព័ន្ធ។ ហេតុអ្វីបានជាជនដែលត្រូវបានគេចោទប្រកាន់នេះ មិនត្រូវបានគេចោទប្រកាន់ និងកាត់សេចក្តីពីបទអំពើអបាយមុខដែលត្រូវជាប់ទោសធ្ងន់ ព្រោះនៅពេលដែលជននោះត្រូវបានចាប់ខ្លួននៅពេលដែលកំពុងតែប្រព្រឹត្តអំពើជាក់ស្តែងនៅនឹងកន្លែងនោះវាជាអំពើដែលធ្ងន់ធ្ងរជាងការដែលគ្រាន់ តែថតរូបអាសអាភាសរបស់កុមារនោះទៀត? លើសពីនេះទៅទៀត នីតិវិធីផ្លូវការសំរាប់រដ្ឋាភិបាលបរទេស ដើម្បីទទួលបានការអនុញ្ញាតច្បាប់ទាក់ទងទៅនឹងករណីបទល្មើសពីអាជ្ញាធរកម្ពុជា ដើម្បីចូលរួមក្នុងការស៊ើបអង្កេតបែបនេះ គួរតែធ្វើអោយបានរួសរាន់ដើម្បីកុំអោយពេលវេលាដ៏មានតំលៃ និងភស្តុតាងត្រូវបានបាត់បង់។ បញ្ហានេះគួរតែត្រូវបានធ្វើឡើងដើម្បីជាផលប្រយោជន៍ដល់ជនរងគ្រោះ។ រឿងក្តីកាន់តែឆាប់ចប់ជនរងគ្រោះក៏កាន់តែ

ពេលដែលកំពុងប្រព្រឹត្តជាក់ស្តែងនៅនឹងកន្លែង ដោយនៅពេលនោះគាត់មិនមានស្លៀកខោទេ ហើយមានក្មេងស្រីអាយុ ១២ ឆ្នាំ ម្នាក់កំពុងកំដរផង។ ប៉ូលិសបានរកឃើញខ្សែភាពយន្តអាសអាភាសរបស់ជននេះជាមួយកុមារីជាច្រើន ដែលមិនទាន់ទាំងឡើងសុដន និងមានរោមនៅលើថ្ងាសផង ដូច្នេះពួកគេមិនមានអាយុច្រើនជាង ១២ ឆ្នាំ ទេ។ ចៅក្រមនៅកន្លែងបើកសាវនាការមិនអាចដោះលែងជនសង្ស័យនេះអោយនៅក្រៅឃុំបានទេ ពីព្រោះករណីនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈខ្លាំងពេក ដូច្នេះហើយគាត់បានបញ្ជាឱ្យបន្តធ្វើការលើករណីនេះតទៅទៀត។ ប៉ុន្តែ ៨ខែ ក្រោយមកជនជាតិជប៉ុននោះ នៅតែមិនទាន់ត្រូវបានគេជំនុំជំរះ ទោះបីជាពេលវេលាជាអតិប្បរមាដែលគេអនុញ្ញាតអោយមានការឃុំខ្លួនមុនពេលការកាត់ទោសមានត្រឹមតែ ៦ ខែ យ៉ាងក៏ដោយ។ នៅពេលដែលជនសង្ស័យនោះ ត្រូវបានចាប់ខ្លួនប៉ូលិសជប៉ុនក៏មកដល់ប្រទេសកម្ពុជាដែរដើម្បីស៊ើបអង្កេតនូវរឿងក្តីដ៏ទៃមួយទៀត។ អង្គការក្រៅរដ្ឋាភិបាលរបស់ប្រទេសបារាំងមានមូលដ្ឋាននៅក្នុងទីក្រុងភ្នំពេញបានផ្តល់ភស្តុតាង ដែលពួកគេប្រមូលបានលើករណីនោះដល់ពួកគេរាប់បញ្ចូលទាំងភស្តុតាងជាក់ស្តែង (ជាវត្ថុ/រាងកាយ/សំភារៈជាដើម) និងរូបភាព។ អង្គការក្រៅរដ្ឋាភិបាលនេះចង់អោយប៉ូលិសជួបនិយាយជាមួយជនរងគ្រោះ នៅខណៈពេលដែលពួកគេនៅទីនេះពីព្រោះ កុមារទាំងនោះជាជនជាតិវៀតណាមពួកគេនឹងត្រូវបានបញ្ជូនទៅស្រុកកំណើតវិញឆាប់ៗ។ ប្រសិនបើប៉ូលិសទៅកាន់ប្រទេសជប៉ុនវិញ ហើយស្នើសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃដើម្បីត្រឡប់មកវិញវានឹងយឺតពេលទៅហើយ។ ប៉ុន្តែជនជាតិជប៉ុនជឿជាក់លើនីតិវិធីខាងក្រោម



ដែលភ្ញៀវទេសចរទាក់ទងជាមួយបានឡើយ។ ទោះបីជា ពួកគេមិនបាននាំអនីតិជនឱ្យមកជួបភ្ញៀវ ឬមិនបាននាំភ្ញៀវទៅជួបជាមួយនឹងអនីតិជនដោយផ្ទាល់ក៏ដោយក៏អ្វីដែលពួកគេកំពុងធ្វើនេះ គឺមានន័យថា ពួកគេកំពុងតែជំរុញឱ្យមានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬក៏ដាក់កុមារកម្ពុជាអោយស្ថិតនៅក្នុងការគ្រោះថ្នាក់ខ្លាំងជាងធម្មតា។ បុគ្គលិកសិទ្ធិមនុស្សម្នាក់ក្នុងក្រុងភ្នំពេញបានប្រាប់អ្នកស្រាវជ្រាវថា គាត់បានដឹងថាមានទីភ្នាក់ងារទេសចរណ៍ពីរដើរតួនាទីជាអន្តរការីរវាងស្ត្រី និងភ្ញៀវទេសចរណ៍។ គាត់មិនបានដឹងឈ្មោះ ឬក៏មិនមានបំណងដើម្បីលាតត្រដាងនូវឈ្មោះរបស់ទីភ្នាក់ងារទេសចរណ៍ទាំងពីរនេះ។ គាត់ក៏បានបញ្ជាក់ផងដែរថាដោយការប្រើប្រាស់ Internet មានការកើនឡើងការសំរបសំរួលកាន់តែងាយស្រួល ដែលជាហេតុបណ្តាលអោយមានការកើនឡើងដ៏ធំនៃទេសចរណ៍ផ្លូវភេទលើកុមារយ៉ាងនេះ ។

ភ្នាក់ងារទេសចរណ៍មួយបានអះអាងថា ប្រសិនបើអ្នកនាំភ្ញៀវមានការពាក់ព័ន្ធក្នុងទេសចរណ៍ផ្លូវភេទលើកុមារ សេវាកម្មរបស់គាត់នឹងលែងត្រូវបានគេប្រើប្រាស់គេនឹងអនុវត្តន៍ដូចគ្នា ចំពោះដៃគូដែលពាក់ព័ន្ធនឹងបញ្ហានេះ រួមមានទាំងសណ្ឋាគារ និងផ្ទះសំណាក់ដែលពួកគេបញ្ជូនភ្ញៀវទៅកាន់ផងដែរ។ បុគ្គលិកសណ្ឋាគារម្នាក់ក្នុងក្រុងព្រះសីហនុបានប្រាប់អ្នកស្រាវជ្រាវថា មិត្តភ័ក្តិរបស់គាត់នាំភ្ញៀវទេសចរណ៍ពីក្រុងភ្នំពេញមកក្រុងព្រះសីហនុ ហើយពួកគេសួររកស្ត្រីវ័យក្មេងយោងតាមអ្នកនាំភ្ញៀវទេសចរណ៍ ក៏ប៉ុន្តែមិនមែនជាអនីតិជនទេ។ គាត់បានអះអាងថា ភ្ញៀវយល់ដឹងពីច្បាប់ទាំងនៅក្នុងស្រុកពួកគេទាំងនៅប្រទេសកម្ពុជា

ហើយពួកគេដឹងថា ការរួមភេទជាមួយកុមារ គឺជាបទឧក្រិដ្ឋ។ អ្នកផ្តល់ចំលើយម្នាក់ទៀតដែលធ្វើការឱ្យក្រុមហ៊ុនទេសចរណ៍បានលើកឡើងនូវទស្សនៈស្រដៀងគ្នា : គាត់បាននិយាយថា មនុស្សទាំងនោះបានសួររកសេវាកម្មផ្លូវភេទ ក៏ប៉ុន្តែពួកគេខ្លាចក្នុងការសួររកក្មេងស្រីអនីតិជនពីព្រោះពួកគេដឹងថាខុសច្បាប់។ នៅពេលដែលពួកគេសួររកសេវាកម្មផ្លូវភេទ បុរសនេះបង្ហាញភ្ញៀវអំពីតំបន់ផ្ទះបននៅលើផែនទី ពីព្រោះគាត់រវល់ខ្លាំងពេកមិនអាចនាំភ្ញៀវទៅដោយខ្លួនឯងបាន។

## ៣.៤ បញ្ហាដទៃ

អ្នកសំរបសំរួលសំខាន់ៗ គឺអ្នករត់តាក់ស៊ី, អ្នករត់ម៉ូតូឌុប, ម្ចាស់ផ្ទះសំណាក់, ម្ចាស់សណ្ឋាគារ, ហើយនឹងអ្នកនាំភ្ញៀវទេសចរ។ ប៉ុន្តែមិនមែនមានតែជនទាំងនេះប៉ុណ្ណោះទេដែលដើរតួនាទីជាអន្តរការីរវាងកុមាររងគ្រោះ ហើយនឹងភ្ញៀវទេសចរផ្លូវភេទនោះ។ និន្នាការគឺ វាវិវឌ្ឍន៍ជានិច្ច សូម្បីតែនៅក្នុងវិស័យទេសចរណ៍ផ្លូវភេទ។ កុមារដែលត្រូវបានគេកេងប្រវ័ញ្ចប្រហែលជាលួងលោមមិត្តភ័ក្តិក្មេងៗដ៏ទៃទៀតឱ្យធ្លាក់ទៅក្នុងឧស្សាហកម្មផ្លូវភេទ ដើម្បីឱ្យពួកគេក្លាយជាម៉ែយ៉ែមសំរាប់ការស់នៅ។ ម៉ែយ៉ែមទាំងនេះត្រូវបានគេស្គាល់ថា ជាបងធំជាធម្មតាពួកគេមានអាយុពី ១៥ឆ្នាំ ទៅ ១៧ឆ្នាំ ហើយបញ្ជូនកុមារ (អាយុ ១០ ឆ្នាំ ឬក៏លើសពីនេះ) ពីក្រុមរបស់ពួកគេទៅឱ្យជនល្មើសលើកុមារដើម្បីរកលុយ។ កុមារកាន់តែមានការយល់ដឹងច្រើនឡើងៗនូវអ្វីដែលភ្ញៀវទេសចរណ៍ផ្លូវភេទលើកុមារត្រូវការ ហើយអ្វីដែលអាចនាំលុយមកយ៉ាងលឿន ដូច្នេះពួកគេចាប់ផ្តើមទៅរកភ្ញៀវទេសចរ ដែលត្រូវការការរួមភេទ។ បុគ្គលខ្លះដែលធ្លាប់បានកេងប្រវ័ញ្ចលើ



ដែលមានអាយុចន្លោះពី ៥ ឆ្នាំ និង ១៤ ឆ្នាំ[៤៧] (ដោយប្រើប្រាស់នូវកាមេរ៉ាសំងាត់)។ ភាពលំបាកមួយដែលកើតឡើង ដោយសារលទ្ធផលនៃការវាយឆ្មក់បែបនេះដែលអនុវត្តដោយអង្គការបេសកកម្មអន្តរជាតិនោះគឺ ក្នុងពេលតែមួយជនរងគ្រោះដ៏ច្រើនលើសលប់ត្រូវការចូលមកក្នុងមជ្ឈមណ្ឌលស្តាលទ្ធភាព ដើម្បីជំរក, ការថែទាំ, សុខភាព និងសេវាកម្មពិគ្រោះយោបល់។ អង្គការក្រៅរដ្ឋាភិបាលទាំងនោះប្រហែលជាមិនអាចត្រៀមរៀបចំទទួល និងផ្តល់ទីកន្លែង និងឧបករណ៍ដែលជនរងគ្រោះទាំងនេះត្រូវការបានទេ។ ភាពលំបាកបន្ថែមទៀតគឺ ការវាយឆ្មក់បែបនេះមិនពិតជាអាចដោះស្រាយបញ្ហាបានទេ ក៏ប៉ុន្តែផ្ទុយមកវិញការធ្វើបែបនេះប្រហែលជារិតតែបង្ខំអោយជនប្រព្រឹត្តបទល្មើសទាំងនោះ ខិតខំធ្វើយ៉ាងណាលាក់បាំងអំពើរបស់ពួកគេថែមទៀត ឬក៏ធ្វើអោយបញ្ហានេះកាន់តែរីករាលដាលខ្លាំងឡើង។ ការសិក្សាមួយត្រូវបានធ្វើឡើងដើម្បីវាយតំលៃលើផលប៉ះពាល់នៃការបិទផ្ទះបនតំបន់ស្វាយប៉ាក ហើយត្រូវបានគេឃើញថា ស្ត្រីរកស៊ីផ្លូវភេទដែលនៅសល់បានភៀសខ្លួនទៅភ្នំពេញ ឬសៀមរាប[៤៨]។

២ឆ្នាំ កន្លងទៅរឿងក្តីមួយពាក់ព័ន្ធជនសង្ស័យជនជាតិជប៉ុនម្នាក់ទទួលនូវការយកចិត្តទុកដាក់ពីសារព័ត៌មានគួរកត់ឱ្យសំគាល់ ហើយបង្ហាញនូវបញ្ហាមួយចំនួន ដែលធ្វើអោយមានការស្មុគស្មាញក្នុងការកាត់ទោសនៃជនល្មើសផ្លូវភេទក្នុងប្រទេសកម្ពុជា។ ក្នុងផ្ទះបននៅស្វាយប៉ាក ជនសង្ស័យនេះត្រូវបានចាប់ខ្លួននៅ

---

[47] Haugen, Gary A. with Hunter, Gregg, *Terrify No More*, International Justice Mission (IJM), 2005; p. 131.

[48] Dr. Thomas, Frederic, commissioned by AIDéTouS and COSECAM, Impact of Closing Svay Pak – Study of police and international NGO-assisted interventions in Svay Pak, Kingdom of Cambodia, January 2005.

អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិគឺ ជាអង្គការគ្រីស្ទដែលរៀបចំនូវការស៊ើបអង្កេត ផ្តល់នូវការផ្គត់ផ្គង់ចំពោះភ្នាក់ងារពង្រឹងការអនុវត្តន៍ច្បាប់ និងផ្តល់នូវការបណ្តុះបណ្តាលចំពោះមន្ត្រីប៉ូលីសក្នុងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សរបស់ក្រសួងមហាផ្ទៃ។ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិមានវិធីសាស្ត្រពិសេស និងប្រតិបត្តិការដោយសំងាត់ដ៏គ្រោះថ្នាក់ដោយប្រើកាមេរ៉ាវីដេអូសំងាត់ដើម្បីថតយករឿងរ៉ាវ/ភស្តុតាងនៃការប្រព្រឹត្តិបទឧក្រិដ្ឋរបស់ជនល្មើស។ រហូតដល់ពេលនេះ ការស៊ើបអង្កេតរបស់ពួកគេបាននាំអោយមានការចាប់ខ្លួនជនប្រព្រឹត្តបទល្មើស ៣៨នាក់ មានម្ចាស់បន និងម៉ែយ៉ែមជាជនជាតិកម្ពុជា និងជនជាតិវៀតណាម។ ជនសង្ស័យ ២៥នាក់ ត្រូវបានបញ្ជូនទៅកាន់តុលាការក្នុងចំណោមនោះមាន ២៤នាក់ ត្រូវបានគេកាត់អោយជាប់ទោស ហើយម្នាក់ទៀតត្រូវបានគេកាត់ឱ្យរួចទោស។ អ្នកដែលនៅសល់ (៩នាក់) កំពុងរង់ចាំការកាត់ទោស។ ការកាត់ទោសត្រូវបានកំណត់ទោសពីចន្លោះ ៥ និង ១៨ ឆ្នាំ[៤៦] ។ អង្គការបេសកកម្មអន្តរជាតិអនុវត្តនូវការស៊ើបអង្កេតច្រើន និងប្រតិបត្តិការជាសំងាត់ក្នុងតំបន់ស្វាយប៉ាកក្នុងអំឡុងឆ្នាំ ២០០២ និង ២០០៣ ក្នុងកិច្ចសហប្រតិបត្តិការជាមួយប៉ូលីសកម្ពុជា ដែលឈានទៅរកការវាយឆ្មក់ ហើយជាលទ្ធផលនាំឱ្យមានការចាប់ខ្លួនអ្នករកស៊ីជួញដូរ និងមេបនជាច្រើនអ្នកព្រមទាំងសង្គ្រោះបានជនរងគ្រោះប្រហែលជា ៣០-៤០នាក់។ ក្នុងការប្រមូលភស្តុតាងអង្គការបេសកម្មអន្តរជាតិបានថតបាននៅក្នុងវីដេអូនូវសកម្មភាពស្តីអំពី ការលក់ក្មេងស្រី ៤០នាក់

[46] Interview with Mr. Kaign N. Christy, Director OFP, IJM.



កុមារដែលធ្វើការជាអ្នកលក់ ឬក៏ខាត់សារាស្បែកជើងតាមចិញ្ចើមថ្នល់នោះនឹងបង្ខំឱ្យកុមារតាមចិញ្ចើមថ្នល់នោះធ្លាក់ខ្លួនទៅក្នុងអំពើពេស្យាកម្ម ដូច្នេះបុគ្គលនោះអាចរកលុយបានថែមទៀតពីកុមារតាមចិញ្ចើមថ្នល់ទាំងនោះ។ មេបនអាចដើតួរនាទីជាមេអណ្តើកក្នុងការទាក់ទងភ្ញៀវ ហើយនឹងក្មេងស្រីផងដែរ។ ភ្ញៀវទេសចរទំនាក់ទំនងមេបន ក្រោយមកមេបនក៏ផ្តល់ក្មេងស្រីដល់ពួកគេ។ លើសពីនេះទៅទៀត ជនបរទេសដែលរស់នៅស្រុកខ្មែរយូរអាចផ្តល់ព័ត៌មានដល់មិត្តភ័ក្តិឬជន ដែលអាចនឹងក្លាយជាជនល្មើសផ្លូវភេទលើកុមារដ៏ទៃទៀតនៅក្នុងប្រទេសកម្ពុជា ឬពេលដែលពួកគេត្រឡប់ទៅប្រទេសកំណើតវិញថា ក្នុងប្រទេសកម្ពុជាមានសេវាកម្មផ្លូវភេទវាថោកហើយស្រួលរកទៀតផង។ សកម្មភាពដែលកំពុងតែកើតមានឡើងក្នុងការទំនាក់ទំនងជាមួយនឹងកុមារក្មេងៗ ដែលងាយរងគ្រោះនោះ គឺកាន់តែត្រូវបានគេមើលឃើញច្បាស់។ ជនបរទេសមានការកើនឡើងក្នុងការធ្វើដំណើរចេញក្រៅតំបន់ទេសចរណ៍នៃទីក្រុង ហើយឆ្ពោះទៅកាន់ភូមិជនបទតូចៗ។ នៅទីនោះពួកគេដឹងថា ពួកគេនឹងអាចស្វែងរកកុមារ និងគ្រួសារដែលកីក្រ និងអស់សង្ឃឹម។ នេះគឺជាការព្រួយបារម្ភខ្លាំងណាស់ ពីព្រោះសកម្មភាពនេះនឹងធ្វើឱ្យទេសចរណ៍ផ្លូវភេទលើកុមាររីករាលដាលនឹងធ្វើអោយប៉ះពាល់តំបន់ជាច្រើន ហើយទំនងជានឹងអាចជំរុញឱ្យកុមារធ្វើដំណើរមកកាន់ទីក្រុង (គឺនៅតាមដងផ្លូវ) ដើម្បីរកភ្ញៀវទេសចរដែលមានជាច្រើន។

## ៤. ទំនាក់ទំនងរវាងទេសចរណ៍ផ្លូវភេទលើកុមារ និងការជួញដូរកុមារ

ទិដ្ឋភាពមួយក្នុងចំនោមទិដ្ឋភាពទាំងអស់នៃការសិក្សានេះបញ្ចូលនូវការស្វែងយល់ថា តើវាមានការទំនាក់ទំនងរវាងទេសចរណ៍ផ្លូវភេទលើកុមារ និងការជួញដូរលើកុមារដែរឬទេ។ ឯកសារនេះមិនមានបំណងកំណត់នូវវិសាលភាពនៃទំនាក់ទំនងនោះទេ ប៉ុន្តែគ្រាន់តែដើម្បីបង្ហាញដោយសង្ខេបនូវបញ្ហាដែលពាក់ព័ន្ធទៅនឹងទេសចរណ៍ផ្លូវភេទលើកុមារតែប៉ុណ្ណោះ។ វាមានការលំបាកណាស់ដើម្បីទទួលបានតួលេខពិតប្រាកដអំពីចំនួនមនុស្ស ដែលឋិតក្នុងឧស្សាហកម្មផ្លូវភេទលើសពីនេះទៅទៀត ការប៉ាន់ស្មានដែលត្រូវបានគេលើកឡើងនៅក្នុងការសិក្សានេះពុំមានការពន្យល់ថា តើវាបានមកដោយរបៀបណា ឬក៏ពីកន្លែងណាមក។ ការស្រាវជ្រាវដែលបានធ្វើលើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍បានរកឃើញថា ចំនួនអ្នករកស៊ីផ្លូវភេទក្នុងប្រទេសកម្ពុជាមានពី ៤0 000 នាក់ទៅ ១00 000 នាក់ (អង្គការ UNICEF ប៉ាន់ស្មានថា ៣0-៣៥ ភាគរយ គឺជាកុមារ)[៣៣]។ ក្នុងឆ្នាំ ១៩៩៧ សភាជាតិ បានរៀបចំនូវការអង្កេតមួយយ៉ាងទូលំទូលាយអំពីចំនួនអ្នករកស៊ីផ្លូវភេទក្នុងប្រទេសកម្ពុជា ហើយបានអោយឃើញថាមានស្រ្តីវ័យក្មេង និងក្មេងស្រីប្រហែល ២៣ 000 នាក់ ធ្វើការក្នុងផ្ទះបន។ ប៉ុន្តែការស្រាវជ្រាវនេះមិនបានរាប់បញ្ចូលស្រីខារ៉ាអូខេ ឬស្រីឡង់សេស្រាបៀរទេ (អ្នករកស៊ីផ្លូវភេទប្រយោល)[៣៤]។ លោកសាស្រ្តាចារ្យ ស្តេនហ្វាតថិ បានធ្វើការ

[33] World Tourism Organisation, *15th Meeting of the Task Force to Protect Children from Sexual Exploitation in Tourism*, Treva D. Braun, Director, The Future Group; November 8, 2004.
[34] Interview with Mrs. Chan Haran Vaddey, Secretary General, Cambodian National Council for Children (CNCC); 06 February 2006.



ប្រព្រឹត្តបទល្មើសផ្លូវភេទ។ នៅពេលភស្តុតាងត្រូវបានប្រមូលគ្រប់គ្រាន់ ហើយសំនុំរឿងនោះត្រូវបានប្រគល់ទៅអោយប៉ូលីស។ អង្គការនេះធ្វើការយ៉ាងជិតស្និទ្ធផងដែរជាមួយស្ថានទូតនានា ដោយបានបញ្ជូនទៅឱ្យស្ថានទូតទាំងនោះនូវករណីដែលពាក់ព័ន្ធទាំងឡាយណា ដែលគេអាចយកច្បាប់ប្រព្រឹត្តបទល្មើសក្រៅទឹកដីមកអនុវត្តបាន។ ជនបរទេស ២៣នាក់ ត្រូវបានចាប់ខ្លួនក្រោយពីមានការស៊ើបអង្កេតរបស់អង្គការ APLE តាំងពីអង្គការក្រៅរដ្ឋាភិបាលនេះ ត្រូវបានបង្កើតក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមជនទាំងអស់នេះមានជនសង្ស័យ ២នាក់ ត្រូវបានកាត់សេចក្តីនៅក្នុងតុលាការក្រុងភ្នំពេញកម្ពុជា ហើយត្រូវបានកាត់ឱ្យជាប់ទោសដោយដាក់ទោសឱ្យជាប់ពន្ធនាគារម្នាក់រហូតដល់ ១0 ឆ្នាំ និងម្នាក់ទៀតរហូតដល់ ១៥ឆ្នាំ។ ជនម្នាក់ត្រូវបានកាត់សេចក្តីថា មិនបានប្រព្រឹត្តខុសនោះទេ ប៉ុន្តែក្រោមមកនៅក្នុងតុលាការឧទ្ធរណ៍ក្នុងប្រទេសកម្ពុជាត្រូវបានកាត់ឱ្យជាប់ទោស ហើយត្រូវបានកាត់អោយជាប់ទោស ១0 ឆ្នាំ។ ២នាក់ ទៀត នៅក្នុងតុលាការក្រុងក្នុងប្រទេសកម្ពុជាត្រូវបានកាត់ទោសអោយរួចខ្លួន។ ជនសង្ស័យ ៣នាក់ ទៀត ត្រូវបានធ្វើបត្យាប័នទៅកាន់សហរដ្ឋអាមេរិកក្នុងចំណោមនោះមាន ២នាក់ ត្រូវបានគេកាត់អោយជាប់ពន្ធនាគារម្នាក់ ៨ ឆ្នាំ និងម្នាក់ទៀត ១៥ ឆ្នាំ ហើយអ្នកទី ៣ កំពុងរង់ចាំការកាត់ទោស។ ៤នាក់ ទៀតកំពុងរង់ចាំការកាត់ទោសក្នុងប្រទេសកម្ពុជា ហើយអ្នកដែលនៅសល់ ១១នាក់ ទៀតត្រូវបានដោះលែង ដោយគ្មានការចោទប្រកាន់។

អាជ្ញាធរកម្ពុជាក៏បានចាប់ជនមួយចំនួនពីបទជួញដូរ និងពាក់ព័ន្ធសកម្មភាពខុសច្បាប់។ ក្នុងខែសីហា ឆ្នាំ ២០០៣ ស្ត្រីម្នាក់ដែលមានវ័យចំណាស់ត្រូវបានចោទប្រកាន់ពីបទជួញដូរស្ត្រីកម្ពុជាទៅប្រទេសម៉ាឡេស៊ី ក្នុងគោលបំណងឱ្យធ្វើជាអ្នករកស៊ីផ្លូវភេទ។ ខែតុលា នៅឆ្នាំនោះ បុរសវៀតណាម ២នាក់ និងស្ត្រីវៀតណាម ២នាក់ ទទួលទោសជាប់ពន្ធនាគារ ១៥ឆ្នាំ ពីបទបើកបណ្តាញរកស៊ីផ្លូវភេទលើកុមារដ៏ធំបំផុតមួយក្នុងចំណោមបណ្តាញរកស៊ីផ្លូវភេទដ៏ធំបំផុតនៅប្រទេសកម្ពុជា។ មានស្ត្រីជាច្រើន (ពីវៀតណាម និងតៃវ៉ាន់) ត្រូវបានចាប់នៅក្នុងខេត្តសៀមរាបក្នុងខែធ្នូ ឆ្នាំ ២០០៣ ពីបទបើកកន្លែងម៉ាស្សា ដែលជាកន្លែងផ្ទះបន (និងត្រូវបានគេចោទប្រកាន់ថា បើកឱ្យមានការរួមភេទជាមួយអនីតិជនក្មេងស្រីពីអាយុ ១២ ឆ្នាំ ដល់ ១៥ ឆ្នាំ)។ ក្នុងខែមេសា ឆ្នាំ ២០០៤ ការវាយឆ្មក់មួយលើកន្លែងម៉ាស្សានាំឱ្យមានការចាប់បាននូវស្ត្រីកម្ពុជាម្នាក់ពីបទបើកនូវកន្លែងដែលប្រព្រឹត្តអំពើអបាយមុខ (រំលោភលើមាត្រា ៧ នៃច្បាប់ជួញដូរ ឆ្នាំ ១៩៩៦)។ ខែឧសភា ឆ្នាំ ២០០៤ ជនជាតិបារាំងម្នាក់ត្រូវបានចាប់ខ្លួនពីបទបើកផ្ទះបននៅទីក្រុងភ្នំពេញ។ ស្ត្រីម្នាក់មកពីកំពង់ចាមត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ១៥ ឆ្នាំ ក្នុងខែកក្កដា ឆ្នាំ ២០០៤ ពីបទជួញដូរកូនរបស់ខ្លួនឯង ២នាក់ ព្រមទាំង ៥នាក់ ផ្សេងទៀត[៤៥]។

សហប្រតិបត្តិការជាមួយផ្នែកដ៏ទៃៗទៀតគឺ សំខាន់ណាស់។ អ្នកស៊ើបអង្កេតរបស់អង្គការ APLE ប្រមូលភស្តុតាងលើជនដែលគេសង្ស័យថា បាន

[45] 2005 Human Rights Report on Trafficking in Persons, Especially Women and Children – Cambodia; www.theprotectionproject.org



សិក្សាមួយ ដោយមានបំណងឱ្យបានដឹងពីចំនួនមនុស្សដែលត្រូវបានគេជួញដូរក្នុងប្រទេសកម្ពុជា ឆ្នាំ ២០០២។ កាស្រាវជ្រាវនេះយកចិត្តទុកដាក់លើស្ត្រីដែលត្រូវបានគេជួញដូរផ្នែកផ្លូវភេទ (ដោយមិនរាប់បញ្ចូលស្ត្រីដែលត្រូវបានគេជួញដូរសំរាប់គោលបំណង់ដ៏ទៃនោះទេ) មកកាន់ប្រទេសកម្ពុជា (ប្រទេសកម្ពុជា គឺជាទិសដៅចុងក្រោយរបស់ពួកគេ)។ ស្ត្រីដែលត្រូវបានគេជួញដូរពីប្រទេសកម្ពុជាទៅប្រទេសដ៏ទៃទៀតនោះគឺ មិនត្រូវបានរាប់បញ្ចូលក្នុងការសិក្សានេះទេ។ ការប៉ាន់ស្មានដែលគេចាត់ទុកថា វាជា "ការប៉ាន់ស្មានដ៏ល្អបំផុត" នៃចំនួនអ្នករកស៊ីផ្លូវភេទសរុបក្នុងប្រទេសកម្ពុជានោះត្រូវបានគេឃើញថា មានស្ត្រី ២០ ៨២៩ នាក់ ហើយ ២ ៤៨៨ នាក់ ទំនង់ជាត្រូវបានជួញដូរមកកាន់ប្រទេសកម្ពុជាសំរាប់គោលបំណងផ្លូវភេទ[៣៥]។

យោងទៅលើទិន្នន័យដែលទទួលបានពីនាយកដ្ឋានសុខាភិបាល មានអ្នករកស៊ីផ្លូវភេទផ្ទាល់និងប្រយោលប្រហែលជាង ១០០០ នាក់ ក្នុងក្រុងព្រះសីហនុ[៣៦]។ កុមាររងគ្រោះនៃការរំលោភផ្លូវភេទ គឺជាកុមារអនាថាមកពីក្រុងព្រះសីហនុ និងភូមិនៅជុំវិញទីនោះ (ក្មេងធ្វើដំណើរទៅកាន់ទីប្រជុំជនក្នុងក្តីសង្ឃឹមរកការងារធ្វើ)។ ស្ត្រីកម្ពុជាជាប្រក្រតីត្រូវបានគេជួញដូរទៅកាន់ប្រទេសថៃ និងប្រទេសម៉ាឡេស៊ីដោយស្ទាត់ៗ សំរាប់គោលបំណងធ្វើការក្នុងឧស្សាហកម្មទេសចរណ៍ជាក់ស្តែងជាងនេះទៅទៀត គឺដើម្បីផ្តល់នូវសេវាកម្មរួមភេទសំរាប់ភ្ញៀវទេសចរ។

[35] Professor Steinfatt, Thomas M., Baker, Simon and Beesey, Allan, *Measuring the Number of Trafficked Women in Cambodia: 2002; Part I of a Series*, sponsored by The Office to Combat and Monitor Trafficking, US State Department; November 2002; p. 15.

[36] Interview with Mr. Kleang Rim, National Project Coordinator, ILO-IPEC TICW; 05 December 2005.

លើសពីនេះទៅទៀត នៅខណៈពេលដែលស្រ្តី និងកុមារវៀតណាមត្រូវបានគេជួញដូរមកប្រទេសកម្ពុជាមានចំនួនជាច្រើននោះ សព្វថ្ងៃនេះវាទំនងជាមានមនុស្សតិចតួចទេដែលកំពុងតែឆ្លងកាត់ព្រំដែននោះ។ ការជួញដូរមនុស្សមកប្រទេសកម្ពុជានៅតែកើតឡើង ទោះបីជាមានក្មេងស្រី និងស្រ្តីវ័យក្មេងមកប្រទេសកម្ពុជា ដោយសារពួកគេយល់ថា ពួកគេនឹងមានឱកាសរកប្រាក់ចំណូល ហើយរដ្ឋាភិបាលមិនសូវតឹងតែង។ ការជួញដូរនៅតែកើតមាន ក៏ប៉ុន្តែស្របពេលជាមួយគ្នានោះដែរ ការជួញដូរនេះគឺ មិនមែនធ្វើយ៉ាងចាំបាច់ដើម្បីតែភ្ញៀវទេសចរនេះទេ ហេតុដូច្នេះគេសន្និដ្ឋានថា ការជួញដូរក្នុងប្រទេសកម្ពុជានោះមិនមែនកើតឡើងដោយសារតែទេសចរណ៍ផ្លូវភេទលើកុមារនោះទេ។ តែទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលវិស័យទេសចរណ៍នៅតែកើនមានឡើងក្នុងតំបន់ទិសដៅទេសចរណ៍ដ៏មានប្រជាប្រិយភាពបំផុតនោះ គឺមានភ្នំពេញ, សៀមរាប, និងក្រុងព្រះសីហនុ ជនរងគ្រោះនៃការជួញដូរនឹងត្រូវបានគេនាំយកទៅកាន់ទីនោះកាន់តែច្រើនឡើង។ បុគ្គលជាច្រើននឹងធ្វើដំណើរមកពីជនបទដូចជា ខេត្តពោធិសាត់, ព្រៃវែង, ឬកំពង់ធំមកកាន់ភ្នំពេញ, សៀមរាប, និងក្រុងព្រះសីហនុ ប្រហែលជាដើម្បីស្វែងរកឱកាសការងារ។ ទេសចរណ៍ផ្លូវភេទលើកុមារអាចត្រូវបានគេចាត់ទុកជាសមាសភាគនៃការជួញដូរ ដែលស្ថិតនៅក្រោមទំរង់រូបភាពផ្សេងៗនៃការកេងប្រវ័ញ្ចផ្លូវភេទ។ បើយើងពិនិត្យមើលមាត្រា ៣ នៃពិធីសារជួញដូររបស់អង្គការសហប្រជាជាតិគឺថា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារគឺ កុមារត្រូវបានគេយកមកបំរើសេវាកម្មផ្លូវភេទ ដោយមានការទាក់ទងដោយផ្ទាល់ដោយអនុវត្ត



សង្ស័យ ៤០១នាក់ ត្រូវបានចាប់ខ្លួនរាប់បញ្ចូលទាំង ១៨នាក់ ត្រូវបានចាប់ខ្លួនពីបទអំពើអបាយមុខ និង ២៦៦ នាក់ ពីបទរំលោភ និងរំលោភបំពានផ្លូវភេទ។ ចំនួនទាំងអស់នេះបង្ហាញនូវការរីកចំរើនដ៏សំខាន់ក្នុងការអនុវត្តន៏ច្បាប់រយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ : ឆ្នាំ ២០០១ ជនល្មើស ៨២នាក់ និង ២០០២ ជនល្មើស ២០៨ នាក់ ត្រូវបានចាប់ខ្លួន។ យោងតាមតួលេខទាំងនេះគេមិនអាចសន្និដ្ឋានបានថាបញ្ហាដែលកើតមាននៅក្នុងទេសចរណ៍ផ្លូវភេទលើកុមារ មានការកើនឡើងនោះទេ ពីព្រោះចំនួននៃករណី ដែលត្រូវបានគេរាយការណ៍មានការកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ មាន ៣៧២ ករណី ត្រូវបានគេរាយការណ៍ទៅឱ្យអាជ្ញាធរកម្ពុជាក្នុងឆ្នាំ ២០០២ ប្រៀបធៀបទៅនឹង ៦៦៥ ករណី ដែលត្រូវបានរាយការណ៍ក្នុងឆ្នាំ ២០០៥[៤៤] ។ ចន្លោះខែមករា ឆ្នាំ ២០០៤ និង ខែមិថុនា ឆ្នាំ ២០០៥ ជនបរទេស ១១នាក់ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ក្រោមមាត្រា ៣ (ការជួញដូរ) នៃច្បាប់ឆ្នាំ ១៩៩៦។ ក្នុងចំនោមជនទាំងនោះមានជនជាតិអាមេរិក ២នាក់, បារាំង ១នាក់, កាណាដា ២នាក់, ញូហ្ស៊ីឡែន ១នាក់, ហូឡង់ ១នាក់, អូស្ត្រាលី ១នាក់, ចិន ១នាក់, និង ជប៉ុន ២នាក់។ ជនបទេសទាំងនោះត្រូវបានចាប់ខ្លួនពីបទពាក់ព័ន្ធសកម្មភាពផ្លូវភេទជាមួយក្មេងស្រីអនីតិជន (ឬក្មេងប្រុស) មានអាយុ ១០ ឆ្នាំ។ ជនរងគ្រោះភាគច្រើន គឺជាអនីតិជនកម្ពុជា ទោះបីជាម្តងម្កាលមានកុមារវៀតណាមក្លាយជាចំណីរបស់ពួកទេសចរណ៍ផ្លូវភេទយ៉ាងណាក៏ដោយ។

---

[44] Ministry of Interior (MoI), Law Enforcement Against Sexual Exploitation and Trafficking of Children (LEASETC), New Cases – Monthly Report for Year 2005 (as well as for 2004, 2003, 2003, 2001).

គ្មានការចោទប្រកាន់។ ឥឡូវនេះតាមនាយកដ្ឋានប្រឆាំងនឹងការជួញដូរមនុស្ស និងការពារអនីតិជនរបស់ក្រសួងមហាផ្ទៃ ទោះបីជាជនរងគ្រោះយល់ព្រមដកពាក្យបណ្ដឹងប្រឆាំងនឹងជនសង្ស័យក៏ដោយ រឿងក្ដីនេះនឹងនៅតែអនុវត្តដោយតុលាការ (ផ្អែកលើសេចក្ដីសំរេចរបស់ចៅក្រមអំឡុងពេលបើកសវនាការ) វានៅតែបន្តជាស្វ័យប្រវត្តិ។ ប៉ុន្តែអំពើពុករលួយនៅតែជាបញ្ហាដ៏ធំក្នុងដំណើរការកាត់ទោសជនល្មើសផ្លូវភេទ។ ជនប្រព្រឹត្តបទល្មើសត្រូវបានដោះលែងក្រោយពីមានការសូកប៉ាន់ដល់មន្ត្រីប៉ូលីស ឬមន្ត្រីតុលាការ ទោះជាមានភស្តុតាងជារូបថតដែលអាចចោទប្រកាន់ជនសង្ស័យពីបទឧក្រិដ្ឋបានក៏ដោយ! កាលពីពេលមុនមានករណីមួយក្នុងក្រុងព្រះសីហនុពាក់ព័ន្ធទៅនឹងពលរដ្ឋហូឡង់មួយនាក់ ដែលត្រូវបានដោះលែងទោះបីជាមានភស្តុតាងនៃការរំលោភពីកុមារជាច្រើនក៏ដោយ។ ជនរងគ្រោះទាំងអស់មានអាយុតិចជាង ១៥ ឆ្នាំ។ ក្នុងតុលាការចៅក្រមភាគច្រើនអត់មានសមានចិត្តចំពោះកុមារ និងគ្រួសាររបស់គេទេ។ ចៅក្រមបានស្ដីបន្ទោសកុមារថា បានដេកជាមួយជនបរទេសដោយស្ម័គ្រចិត្ត ហើយបានស្ដីបន្ទោសឪពុកម្ដាយកុមារថាអនុញ្ញាតឱ្យកុមាររកស៊ីតាមចិញ្ចើមថ្នល់។ វាជារឿងមួយគួរឱ្យភ្ញាក់ផ្អើលណាស់ដែលថា ចៅក្រមមិនបានបន្តដំណើរការកាត់ទោសទៅលើជនល្មើសដែលចូលក្នុងប្រទេសកម្ពុជារំលោភកុមារនៃប្រទេសនេះ ហើយរំលោភច្បាប់កម្ពុជាទៀតផង។

យោងទៅលើតួលេខ ដែលទទួលបានពីក្រសួងមហាផ្ទៃបានអោយដឹងថា ជនល្មើស ៣៩៧ នាក់ ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ ២០០៥ ក្នុងចំណោមនោះមាន ១៩នាក់ ត្រូវបានចាប់ខ្លួនពីបទប្រព្រឹត្តអំពើអបាយមុខ។ ក្នុងឆ្នាំ ២០០៤ ជន



បច្ចេកទេស "ឧបាយកលបោកបញ្ឆោតឱ្យមានការទុកចិត្តសិន" ឬក៏តាមរយៈអន្តរការីក៏ដោយ។ ការចាប់ពង្រត់អាចមិនមែនចាំបាច់ជាផ្នែកមួយនៃវិធីនេះទេ ទោះបីជាកុមារប្រាកដជាត្រូវបានគេបោកប្រាស់ដោយមានការសន្យាផ្សេងៗធ្វើឡើងដោយជនល្មើស ដើម្បីល្បួងលោមកុមារអោយទៅតាមពួកគេក៏ដោយ។ ជនដែលផ្ដល់នូវអំណោយជាអាហារ ឬលុយ ដូច្នេះពួកគេគឺ ស្ថិតនៅក្នុងស្ថានភាពមួយដែលមានអំណាច ហើយនឹងប្រើប្រាស់នូវភាពរងគ្រោះរបស់កុមារដើម្បីសំរេចបាននូវគោលបំណងរបស់ខ្លួន។ ហើយតែងតែមានការដោះដូរជា លុយខ្លះ, ជាអាហារ ឬក៏អំណោយដ៏ទៃទៀតៗសំរាប់សេវាកម្មដែលផ្ដល់ដោយកុមារ។ ដូច្នេះបញ្ហាគួរឱ្យកត់សំគាល់ទាំងពីរនេះ គឺជាប់គ្នាមិនអាចបំបែកបានឡើយ ។

## ៥. ឥទ្ធិពលនៃក្រមសីលធម៌សំរាប់ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងការធ្វើដំណើរ និងទេសចរណ៍

ក្រមសីលធមិសំរាប់ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទក្នុងការធ្វើដំណើរ និងទេសចរណ៍ (ក្រម) គឺជា លទ្ធផលនៃការប្រឹងប្រែងរួមគ្នារវាងអង្គការទេសចរណ៍ពិភពលោក, គណៈកម្មាធិការលប់បំបាត់ពេស្យាកម្ម, រំលោភ, និងការជួញដូរលើកុមារ, ក្រុមហ៊ុនទេសចរណ៍ Sweden and Nordic។ វាមានគោលការណ៍ ៦ សំរាប់សកម្មភាពក្នុងគោលបំណងទប់ស្កាត់ការកេងប្រវ័ញ្ចការរកស៊ីផ្លូវភេទលើកុមារក្នុងឧស្សាហកម្មទេសចរណ៍[៣៧] ។ ក្រសួងទេសចរណ៍ គឺជាសមាជិក

[37] Code of Conduct for the Protection of Children from Sexual Exploitation in Travel and Tourism: Background and Implementation Examples extracted from www.thecode.org

របស់អង្គការទេសចរណ៍ពិភពលោក ហើយក្រុមនេះត្រូវបានយកមកអនុវត្តក្នុងប្រទេសកម្ពុជា។ បុគ្គលិកភាគច្រើនដែលធ្វើការនៅសណ្ឋាគារ និងក្រុមហ៊ុនទេសចរណ៍ដែលត្រូវបានសំភាសមិនបានដឹងនូវច្បាប់នេះទេ។ មានបុគ្គលិកតិចតួចណាស់ ដែលធ្វើការក្នុងទីភ្នាក់ងារទេសចរណ៍ធំៗក្នុងក្រុងភ្នំពេញបានដឹងអំពីក្រុមនេះ។ សមាជិកបុគ្គលិកម្នាក់បានដឹង ដែរថាក្រុមហ៊ុនរបស់គាត់មិនមានហត្ថលេខានៅក្នុងក្រុមនេះទេ។ ភាគច្រើនភ្នាក់ងារទេសចរណ៍ក្នុងខេត្តសៀមរាប និងក្រុងព្រះសីហនុមិនបានដឹងអំពីក្រុមនេះទេ។ បញ្ហាដូចគ្នានេះក៏បានកើតឡើងចំពោះបុគ្គលិកសណ្ឋាគារក្នុងតំបន់ (រាប់បញ្ចូលទាំងបុគ្គលិកសមាគមសណ្ឋាគារកម្ពុជា ដែលត្រូវបានសំភាសក្នុងខេត្តសៀមរាប)។ ដូច្នេះវាជាភស្តុតាងបង្ហាញឱ្យឃើញថា ក្រុមនេះមានឥទ្ធិពលតិចតួចក្នុងប្រទេសកម្ពុជារហូតដល់ឥឡូវនេះ។ ប្រសិនបើ ជនដែលធ្វើការក្នុងឧស្សាហកម្មទេសចរណ៍មិនបានដឹងអំពីក្រុមនេះ វាហាក់បីដូចជាមានការបញ្ជាក់ថា មានសមាមាត្រដ៏តិចតួចនៃសាធារណៈជនទូទៅ (ដែលរួមមានដូចជាអ្នកផ្គត់ផ្គង់, អ្នកធ្វើដំណើរជាដើម។ល។) ដឹងថា មានក្រុមនេះ។

អ្នកស្រាវជ្រាវបាននិយាយទៅកាន់បុរសម្នាក់ក្នុងផ្នែកអង្គការក្រៅរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ដែលមានភាពងប់ងល់នឹងការងាររបស់គាត់ ហាក់បីដូចជាគិតថា ការផ្ដោតគោលដៅតែទៅលើក្រុមហ៊ុនទេសចរណ៍ និងសណ្ឋាគារ គឺ មិនមានប្រសិទ្ធិភាពនោះទេ ពីព្រោះពួកគេត្រូវការទីផ្សារ។ ការអះអាងរបស់គាត់ស្ថិតត្រង់ថា សេវាកម្មផ្លូវភេទអាចទាក់ទាញអតិថិជន។ ស្ត្រីវ័យក្មេងស្អាតៗ



ជនជាតិរបស់ពួកគេនៅបរទេសក៏ដោយ ក៏ស្ថាតទូតទាំងនោះមិនត្រូវជួយអោយជនជាតិគេគេចខ្លួនទេ នៅពេលដែលជនទាំងនោះត្រូវបានគេសង្ស័យថា ជាជនល្មើសផ្លូវភេទលើកុមារ។

រឿងក្ដីជាច្រើនដែលបានកើតឡើងក្នុងប្រទេសកម្ពុជា មិនដែលត្រូវបានគេដោះស្រាយទៅតាមដំណើរការនីតិវិធីយុត្តាធិការឱ្យបានដល់ទីបញ្ចប់នោះទេ។ វាជារឿងធម្មតាទៅហើយដែលថា ជនសង្ស័យ ឬគ្រួសាររបស់គេគំរាមកំហែងជនរងគ្រោះ និង/ឬគ្រួសាររបស់ជនរងគ្រោះដើម្បីអោយដកពាក្យបណ្ដឹង ឬផ្ដល់សំណងក្នុងការដោះដូរសំរាប់ឱ្យគ្រួសារជនរងគ្រោះនោះដកពាក្យបណ្ដឹងវិញ។ ក្នុងករណីខ្លះមន្ត្រីប៉ូលីស ឬមន្ត្រីតុលាការប្រហែលជាជួយជំរុញឱ្យមានដំណោះស្រាយសំណងបែបនេះទៀតផង ពីព្រោះជនល្មើសបានសន្យាចែករំលែកឱ្យពួកគេដែរ។ ជាអកុសល អំពើពុករលួយកើតមានគ្រប់ជាន់ថ្នាក់ដែលជាលទ្ធផលនាំអោយមានករណីជាច្រើនកំពុងដោះស្រាយក្រៅប្រព័ន្ធតុលាការ ឬដកពាក្យបណ្ដឹងវិញ ដែលធ្វើឱ្យមិនបានដោះស្រាយនៅក្នុងប្រព័ន្ធតុលាការ។ សមាជិកបុគ្គលិកនៃអង្គការអន្តរជាតិមួយបានទៅសួរជនសង្ស័យម្នាក់ក្នុងពន្ធនាគារ។ មន្ត្រីប៉ូលីសបានរាយការណ៍ថា ជនសង្ស័យបានដេកលក់បាត់ទៅហើយ ហើយពួកគេគួរតែត្រលប់មកម្ដងទៀតនៅពេលក្រោយវិញ។ លុះនៅពេលដែល គេត្រឡប់ទៅសួរអ្នកជាប់ពន្ធនាគារនោះ ជននោះបានរត់គេចខ្លួនហើយចាកចេញពីប្រទេស។ ការស៊ើបអង្កេតដែលដឹកនាំដោយអង្គការ APLE នោះ គឺបាននាំមកនូវការចាប់ខ្លួនជនសង្ស័យ ២៣ នាក់ ក្នុងចំនោមនោះមាន ១១ នាក់ ត្រូវបានដោះលែងដោយ

នៃប្រទេសរបស់ជនល្មើសត្រូវតែសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជា ដើម្បីចូលមកក្នុងប្រទេសកម្ពុជាដើម្បីធ្វើការស៊ើបអង្កេត។ ពាក់ព័ន្ធទៅនឹងដំណើរការកាត់ទោសនោះ ដំបូងត្រូវធ្វើនៅក្នុងប្រទេសកម្ពុជាដែលជាកន្លែងបទឧក្រិដ្ឋបានកើតលើកុមាររងគ្រោះ ហើយដែលបានកើតឡើងជាញឹកញាប់បំផុតលើកុមារកម្ពុជា។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាវាមិនមានច្បាស់ថា ជនល្មើសផ្លូវភេទលើកុមារនឹងត្រូវបានកាត់ទោសទោះជាមានភស្តុតាងប៉ុន្មានក៏ដោយ។ ពេលខ្លះជនសង្ស័យត្រូវបានដោះលែងក្រោយពីការចាប់ខ្លួន បន្ទាប់ពីមានការដោះដូរជាលុយ។ ជាអកុសលជនបរទេសភាគច្រើនអាចលៃលកដើម្បីសូកប៉ាន់ដល់មន្ត្រីអនុវត្តច្បាប់ ប៉ុន្តែប្រសិនបើប្រទេសកម្ពុជាបញ្ជូននូវព័ត៌មានទាំងឡាយ ដែលទាក់ទងនឹងជនល្មើសទៅឱ្យស្ថានទូតរបស់ជនល្មើសដូចជា ស្ថានទូតអាមេរិកជាដើម គេអាចធានាថា ភស្តុតាងនឹងត្រូវបានប្រមូលជនប្រព្រឹត្តនឹងត្រូវបានកាត់ទោស ហើយប្រសិនបើត្រូវបានកាត់ទោសហើយគាត់នឹងទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ។ ជនល្មើសខ្លះដែលត្រូវបានគេចោទប្រកាន់ត្រូវបានគេដោះលែង ហើយបន្តរស់នៅក្នុងប្រទេសកម្ពុជា នៅពេលដែលអ្នករាល់គ្នាបានដឹងនូវអ្វីដែលពួកគេបានប្រព្រឹត្ត។ ទោះបីជាក្នុងឯកសារនេះគេមិនផ្តោតលើចំណុចនេះក៏ដោយ ក៏វាមានប្រយោជន៍ដែរក្នុងការដែលឱ្យដឹងថា កាលពីមុនមានការរិះគន់ទៅលើស្ថានទូតនៃបច្ចិមប្រទេសដ៏ច្រើនដែលគួរឱ្យកត់សំគាល់ គឺការរិះគន់ចំពោះការការពារនូវប្រជាជនរបស់ពួកគេដែលត្រូវបានគេសង្ស័យថា បានពាក់ព័ន្ធក្នុងទោសចរណ៍ផ្លូវភេទលើកុមារ។ ទោះបីជាគោលបំណង/ការងាររបស់ស្ថានទូតគឺ ជួយជនជាតិរបស់ពួកគេ នៅពេលដែល



ស្លៀកពាក់ប៊ីគីនីអាចអួសទាញអតិថិជនដ៏មានសក្តានុពល ចំណែកឯស្ត្រីដែលចាស់ដូចជាយាយ ទោះជាស្លៀកសំលៀកបំពាក់ហែលទឹកគ្របលើរាងកាយតែបន្តិចបន្តួចក៏មិនសូវជាអួសទាញអតិថិជននោះទេ។ ទោះបីជាយ៉ាងណាក៏ដោយវាស្ថិតនៅត្រង់ថា គ្រប់ផ្នែកទាំងអស់ដែលពាក់ព័ន្ធត្រូវតែធ្វើឱ្យពួកគេដឹង និងត្រូវចូលរួមតស៊ូដើម្បីលប់បំបាត់ទោសចរណ៍ផ្លូវភេទលើកុមារ។ គ្រប់ផ្នែកទាំងអស់ត្រូវតែមានតួនាទីអនុវត្តទាំងអស់គ្នារាប់បញ្ចូលទាំងផ្នែកឯកជន។ រាជរដ្ឋាភិបាលកម្ពុជាប្រហែលជាអាចជួយបង្កើននូវ ការយល់ដឹងអំពីក្រមនេះនៅក្នុងចំណោមសាធារណៈជនទូទៅបាន។

## ៦. ក្របខ័ណ្ឌនីតិបញ្ញត្តិដែលទាក់ទងទៅនឹងទោសចរណ៍ផ្លូវភេទលើកុមារ និង សកម្មភាពពាក់ព័ន្ធ

សន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិកុមារឆ្នាំ ១៩៨៩ ដែលប្រទេសកម្ពុជាផ្តល់សច្ចាប័នបានកំណត់និយមន័យកុមារនៅក្នុងមាត្រា១ : កុមារគឺជាមនុស្សគ្រប់រូបដែលមិនទាន់មានអាយុ១៨ឆ្នាំនៅឡើយ។ ពុំមានបញ្ញត្តិណាមួយឋិតនៅក្រោមច្បាប់នៃប្រទេសកម្ពុជាដែលផ្តល់នូវនិយមន័យនៃកុមារ ហើយក៏មិនបានផ្តល់និយមន័យនៃអាយុដែលត្រូវកំណត់ថា កុមារអាយុប៉ុន្មានក្លាយជាមនុស្សពេញវ័យ។ ថ្មីៗនេះមានសេចក្តីព្រាងច្បាប់ស្តីពី ការជួញដូរពីរកំពុងត្រូវបានគេពិនិត្យ ហើយត្រូវបានរៀបចំដោយក្រសួងយុត្តិធម៌ ហើយច្បាប់មួយទៀតត្រូវបានរៀបចំរួមគ្នាដោយអង្គការ AFESIP ដែលជាអង្គការក្រៅរដ្ឋាភិបាល

បារាំង។ ការរៀបចំសេចក្តីព្រៀងច្បាប់ទីពីរត្រូវ បានឧបត្ថម្ភដោយស្ថានទូតអង់គ្លេស។ នាពេលបច្ចុប្បន្នច្បាប់ដែលអនុវត្ត គឺជាច្បាប់ឆ្នាំ ១៩៩៦ ស្តីការទប់ស្កាត់នៃ អំពើចាប់ជំរិត, ការជួញដូរ, និងការកេងប្រវ័ញ្ចមនុស្ស។ មាត្រា ៣ ចែងអំពីការជួញដូរ, មាត្រា៤ ចែងអំពីម៉ែយ៉ែម, ហើយមាត្រា៨ ចែងអំពីការប្រព្រឹត្តអំពើទុច្ចរិតសរុបទៅច្បាប់នេះមាន ១០មាត្រា។ ខ ទុច្ចរិតចែងអំពីការប្រព្រឹត្តបទល្មើសរបស់ជនដែលពាក់ព័ន្ធសកម្មភាពផ្លូវភេទជាមួយកុមារដែលមានអាយុតិចជាង ១៥ឆ្នាំ។ ឋិតនៅក្រោមមាត្រានេះ ប្រសិនបើជនរងគ្រោះមានអាយុតិចជាង ១៥ឆ្នាំ ជនជាប់ចោទអាចត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារពី ១០ ទៅ ២០ឆ្នាំ។ ច្បាប់កម្ពុជាកំណត់អាយុស្របច្បាប់ដែលអាច (ដោយមានការយល់ព្រមពីសាមីខ្លួន)រួមភេទបាន គឺអាយុ ១៥ឆ្នាំ មានន័យថា កុមារដែលមានអាយុតិចជាង ១៥ឆ្នាំ មិនមានសមត្ថភាពយល់ព្រមក្នុងសកម្មភាពផ្លូវភេទទេពោលគឺ ទោះបីជាមានការយល់ព្រមក៏ដោយក៏មិនអាចយកជាបានការដែរ។

ខ ដែលពាក់ព័ន្ធទៅនឹងយុត្តាធិការ និងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីអនុវត្តក្នុងប្រទេសកម្ពុជា កំឡុងពេលសម័យអន្តរកាលឆ្នាំ ២០០២ (ច្បាប់អ៊ុនតាក់) មានមាត្រាដែលពាក់ព័ន្ធច្រើន រួមមានមាត្រា ៣៣ ដែលចែងពីការរំលោភ និង ៤២ ដែលចែងពីការបំពាន។ ច្បាប់ស្តីពីស្ថានទំងន់ទោសឆ្នាំ ២០០២ ចែងអំពីទោសធ្ងន់ធ្ងរដែលពាក់ព័ន្ធទៅនឹងការរំលោភ (មាត្រា៥)[៣៨]។ ស្ថិតនៅក្រោមរដ្ឋ

[38] Under Article 5, the punishment for rape is ten to fifteen years' imprisonment rather than five to ten years as provided by the UNTAC law. Where aggravating circumstances exist, the punishment is increased to fifteen to twenty years (Article 5(2)) compared to ten to fifteen years in prison under Article 33(2) of the UNTAC law.



## ៧. ការអនុវត្តន៍ច្បាប់ និងដំណើរការកាត់ទោសភ្ញៀវទេសចរផ្លូវភេទ

ជនល្មើសដែលត្រូវបានសង្ស័យថាបានរំលោភផ្លូវភេទលើអនីតិជន ត្រូវបានចោទប្រកាន់ពីបទទុច្ចរិតដែលកាត់ទោសឱ្យជាប់ពន្ធនាគារជាអតិប្បរមា ២០ឆ្នាំ ឬពីបទរំលោភដោយកាត់ទោសឱ្យជាប់ពន្ធនាគារជាអតិប្បរមា ១៥ឆ្នាំ (ឬ ២០ឆ្នាំ ចំពោះករណីធ្ងន់ធ្ងរមួយចំនួន)[៤១]។ ការចាប់ខ្លួនក្នុងប្រទេសកម្ពុជា ធ្វើឡើងនៅក្នុងសណ្ឋាគារ, ផ្ទះសំណាក់, និងតាមទីលំនៅឯកជនដ៏ទៃទៀត។ ថ្មីៗចុងក្រោយបំផុតនេះ ការចាប់ខ្លួនជនជាតិអាមេរិកម្នាក់ឈ្មោះលោក Michael John Koklich នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ គឺបានកើតឡើងនៅក្នុងអំឡុងពេលដែលកំពុងសរសេរឯកសារនេះឯង។ ជនអនាចារដែលត្រូវបានគេសង្ស័យនេះបានសារភាពថា ខ្លួនពិតជាបានរួមភេទជាមួយអនីតិជន ប៉ុន្តែព្យាយាមធ្វើឱ្យបទល្មើសថយមកនៅកំរិតស្រាល[៤២]។ អ្នកដែលត្រូវបានឃុំខ្លួនមិនទាន់ត្រូវបានគេធ្វើការចោទប្រកាន់ភ្លាមៗនោះទេ ដោយសារតែការចោទប្រកាន់ចំពោះគាត់មិនមានភស្តុតាង។ នៅថ្ងៃអង្គារទី ២១ ខែមករា តុលាការក្រុងភ្នំពេញបានចោទប្រកាន់ជនជាតិអាមេរិកនោះពីបទប្រព្រឹត្តិអំពើទុច្ចរិតដោយបានប្រព្រឹត្តសកម្មភាពផ្លូវភេទជាមួយអនីតិជន២នាក់ (លើសពីនេះទៅទៀត បានធ្វើអោយប៉ូលីសត្រូវរបួស និងក្លែងលិខិតឆ្លងដែន)[៤៣]។ ក្នុងករណីជនល្មើសគឺ ជាជនបរទេសប៉ូលីស

[41] Article 8, Law on Suppression of the Kidnapping, Trafficking, and Exploitation of Human Beings 1996 and Article 5, Law on the Aggravating Circumstances respectively.
[42] The Cambodia Daily, "*Alleged Pedophile Questioned, But Not Charged*", Tuesday February 21st, 2006; p. 16.
[43] The Cambodia Daily, "*Charges Filed Against Suspected Paedophile*", Wednesday February 22nd, 2006; p. 17.

របស់ជនល្មើស បន្ទាប់មកអាជ្ញាធរដែលពាក់ព័ន្ធនឹងសំរេចចិត្តថា តើតុលាការអាច ទទួលយកភស្តុតាងនោះបានដែរឬទេ។ លើសពីនេះទៅទៀតនោះ ប្រទេសមួយចំនួនអនុវត្តគោលការណ៏ឧក្រឹដ្ឋកម្មទ្វេដង : ដើម្បីដំណើរការកាត់ទោសជនសង្ស័យក្នុងប្រទេសកំនើតរបស់គេ គេត្រូវធ្វើការចោទប្រកាន់ជនសង្ស័យពីបទប្រព្រឹត្ត អំពើឧក្រិដ្ឋក្នុងប្រទេសកំនើតរបស់ខ្លួន ព្រមទាំងប្រទេសដែលខ្លួនបានប្រព្រឹត្ត បទល្មើស។ ឧទាហរណ៏ ប្រសិនបើជនល្មើសត្រូវបានធ្វើបត្យាប័នទៅកាន់ប្រទេស ស៊ុយអែតដើម្បីដំណើរការកាត់ទោសពីបទឧក្រឹដ្ឋ ដែលបានប្រព្រឹត្តក្នុងប្រទេស កម្ពុជា ចៅក្រមស៊ុយអែតមិនអាចដាក់ទណ្ឌកម្មជនល្មើសធ្ងន់ធ្ងរជាងទោសដែល ចៅក្រមកម្ពុជាបានធ្វើសេចក្តីសំរេចនៅក្នុងតុលាការកម្ពុជានោះឡើយ។ ច្បាប់បែប នេះវាមានការស្មុគស្មាញណាស់ក្នុងការអនុវត្តន៏ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ សំខាន់បំផុតនោះស្ថានភាពក្នុងប្រទេសកម្ពុជាតំរូវអោយមានការផ្តោតទៅលើការ អភិវឌ្ឍន៏ច្បាប់ជាតិរបស់ខ្លួន។

រដ្ឋាភិបាលអាមេរិក និងរដ្ឋាភិបាលកម្ពុជាសហការគ្នាក្នុងករណីទេសចរណ៏ ផ្លូវភេទលើកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារដូចដែលបានពិពណ៌នា យ៉ាងពិស្តារខាងក្រោម។ ជនល្មើសផ្លូវភេទដ៏ច្រើនដែលជាពលរដ្ឋអាមេរិកត្រូវ បានធ្វើបត្យាប័នទៅកាន់សហរដ្ឋអាមេរិក ដើម្បីកាត់ទោសពីបទរំលោភផ្លូវភេទ លើកុមារដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ។



ធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ ការរកស៊ីផ្លូវភេទគឺ មិនមែនជាបទឧក្រិដ្ឋទេ ទោះបី ជាការកេងប្រវ័ញ្ចលើការរកស៊ីផ្លូវភេទត្រូវបានហាមឃាត់យ៉ាងណាក៏ដោយៈ មាត្រា ៤៦។ ក្នុងប្រទេសកម្ពុជាទាំងអ្នករកស៊ីផ្លូវភេទ ទាំងអតិថិជនមិនបានប្រព្រឹត្តបទ ឧក្រិដ្ឋទេ ទោះបីជាយ៉ាងណាក៏ដោយ មេ៉យ៉េម ឬជនណាមួយ ដែលសំរបសំរួល ការរកស៊ីផ្លូវភេទនេះនឹងត្រូវទទួលទោស។ មានកន្លែងបើកបំរើសេវាកម្មរកស៊ី ផ្លូវភេទ ឬរកប្រាក់ចំនេញពីសេវាកម្មរកស៊ីផ្លូវភេទ គឺជាបទល្មើសឋិតនៅក្រោម ច្បាប់ឆ្នាំ ១៩៩៦ ( មាត្រា៤ និង មាត្រា៧) ។

បច្ចុប្បន្ន ពុំមាននិយមន័យស្របច្បាប់ណាមួយស្តីពីទេសចរណ៏ផ្លូវភេទ លើកុមារ និងស្តីពីបទល្មើសឱ្យចំជាក់លាក់ចំពោះជនបរទេស ឬក៏ភ្ញៀវទេសចរ ដែលប្រព្រឹត្តសកម្មភាពខុសច្បាប់លើទឹកដីកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ទេសចរណ៏ផ្លូវភេទលើកុមារ គឺជាការរំលោភលើរដ្ឋធម្មនុញ្ញកម្ពុជា និងនីតិបញ្ញត្តិ ជាតិ។ ច្បាប់សព្វថ្ងៃនេះ ខ្វះនិយមន័យស្តីអំពីការរកស៊ីផ្លូវភេទលើកុមារ និងរូប ភាពអាសអាភាសកុមារ។ នៅក្នុងសេចក្តីព្រៀងច្បាប់ជួញដូររបស់រាជរដ្ឋាភិបាល កុមារការរកស៊ីផ្លូវភេទ គឺសំដៅចំពោះកុមារដែលមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ។ ប៉ុន្តែឥឡូវនេះ ប្រសិនបើជនណាពាក់ព័ន្ធលើសកម្មភាពផ្លូវភេទលើកុមារដែលមាន អាយុ ១៦ ឬ ១៧ ឆ្នាំ ខ ទុច្ចរិតនេះនឹងមិនអាចយកមកអនុវត្តទេ។ ជនសង្ស័យ អាចត្រូវបានគេចោទប្រកាន់ពីបទរំលោភ។ ប៉ុន្តែអំណាចក្នុងការដាក់ទោសរបស់ ចៅក្រមជំនុំជំរះចំពោះបទល្មើសនេះ កំណត់អោយជាប់ពន្ធនាគារអតិប្បរមា ១៥

ឆ្នាំក្រោមច្បាប់ស្តីពីស្ថានទំងន់ទោស។ លើសពីនេះទៅទៀតការយល់ព្រមគឺ អាចយកជាបានការ ។

ដូច្នេះតំរូវការជាបន្ទាន់ឱ្យមាននីតិបញ្ញត្តិថ្មី ដែលនឹងបំពេញនូវចំណុចខ្វះខាតក្នុងច្បាប់បច្ចុប្បន្ន។ និន្នាការទេសចរណ៍ផ្លូវភេទលើកុមារតំរូវឱ្យមានការអនុវត្តន៍តាមផ្លូវច្បាប់មួយនៅនឹងកន្លែង ដើម្បីឱ្យរាជរដ្ឋាភិបាលដាក់ទណ្ឌកម្មជនល្មើសផ្លូវភេទ នៅពេលដែលពួកគេធ្វើដំណើរនៅក្រៅប្រទេសកំណើតរបស់ពួកគេ។ ឥឡូវនេះ ច្បាប់ទេសចរណ៍ថ្មីកំពុងព្រៀងដោយរដ្ឋាភិបាលកម្ពុជា ដែលនឹងចែងអំពីការការពារកុមារក្នុងបរិបទទេសចរណ៍។ ប៉ុន្តែវានៅតែកំពុងត្រូវបានគេពិនិត្យឡើងវិញ ហើយមិនទាន់បានអនុម័តនៅឡើយទេ។

សេចក្តីព្រៀងច្បាប់ស្តីពី ការជួញដូរទាំងពីរបង្ហាញពីការរីកចំរើនយ៉ាងខ្លាំងលើស្ថានភាពនីតិបញ្ញត្តិបច្ចុប្បន្ន។ សេចក្តីព្រៀងច្បាប់របស់រាជរដ្ឋាភិបាលមាននិយមន័យលើអនីតិជន (មាត្រា៥), ការជួញដូរមនុស្ស (មាត្រា១១), កុមាររកស៊ីផ្លូវភេទ (មាត្រា២៩) ហើយការរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ (មាត្រា៤៣)។ សេចក្តីព្រៀងច្បាប់ចុងក្រោយប្រហែលអាចប្រៀបធៀបនឹង ឧទុច្ចរិតដែលមានស្រាប់។ ទោះបីជាអំពើទុច្ចរិតមិនត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់ឆ្នាំ ១៩៩៦ យ៉ាងណាក៏ដោយ ក៏បទល្មើសចំពោះការរួមភេទជាក់ស្តែងជាមួយអនីតិជនក្រោមអាយុ ១៥ឆ្នាំ មិនអាចត្រូវបានគេអនុគ្រោះ ឬការពារទេ។ វាអាចត្រូវបានរាប់បញ្ចូលនូវតិរិយាបទទុច្ចរិតដូចជា ការប៉ះ ឬការស្ទាបអង្អែលកេរ្តិ៍ខ្មាស់របស់កុមារ។ ការអនុវត្តន៍ទោសចំពោះបទល្មើសដូចៗគ្នានេះ



គេអភិវឌ្ឍអោយស្របតាមមាត្រា ៥ នៃកិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន។ ក្នុងកិច្ចព្រមព្រៀងទេសចរណ៍អាស៊ានមានគោលការណ៍ ៦ ដែលមានទិសដៅចំពោះអ្នកធ្វើដំណើរអាស៊ាន ដែលមកពីប្រទេសអាស៊ានទាំង ១0 ដែលមានគោលបំណងធ្វើឱ្យវិស័យទេសចរណ៍មានការរីកចំរើនជឿនលឿនពិតប្រាកដ ដោយមិនធ្វើឱ្យខូចខាតដល់បរិស្ថានក្នុងស្រុក, វប្បធម៌, ឬប្រជាជនគ្រប់ជាតិសាសន៍ទាំងអស់ឡើយ។

ប្រទេសកាន់តែច្រើនទៅៗនៅលើពិភពលោកកំពុងអនុម័តច្បាប់ប្រព្រឹត្តបទល្មើសក្រៅទឹកដី ដើម្បីកាត់ទោសប្រជាពលរដ្ឋរបស់គេពីបទកេងប្រវ័ញ្ចផ្លូវភេទលើកុមារដែលបានប្រព្រឹត្តក្រៅព្រំដែនប្រទេសរបស់គេ។ ច្បាប់នេះអនុញ្ញាតឱ្យគេចាប់ខ្លួន ហើយយកមកកាត់ទោសក្នុងប្រទេសកំណើតរបស់ពួកគេពីបទឧក្រិដ្ឋដែលប្រព្រឹត្តនៅបរទេស។ ករណីទេសចរណ៍ផ្លូវភេទលើកុមារ និងការកេងប្រវ័ញ្ចលើកុមារ គឺមិនអាចលើកលែងបានឡើយ។ ឥឡូវនេះជាង ៣0 ប្រទេសមានច្បាប់ប្រព្រឹត្តបទល្មើសក្រៅទឹកដីបែបនេះ មានដូចជា Canada, Denmark, France, Germany, Italy, Japan, the Netherlands, New Zealend, Norway, Spain, Sweden, Switzerland, Taiwan, Thailand, The UK និង US។ ជាអកុសលច្បាប់ប្រព្រឹត្តបទល្មើសក្រៅទឹកដីមានការលំបាក និងស្មុគស្មាញណាស់ក្នុងការអនុវត្តន៍។ ដើម្បីឱ្យមានប្រសិទ្ធិភាពប្រទេសទាំងពីរ (គឺប្រទេសកំណើតរបស់ជនល្មើសព្រមទាំងប្រទេស ដែលបទល្មើសត្រូវបានប្រព្រឹត្ត) ត្រូវតែសហការធ្វើការងារនេះ។ បន្ទាប់ពីភស្តុតាងត្រូវបានគេប្រមូលនៅកន្លែងដែលឧក្រិដ្ឋកម្មបានកើតឡើងភ្លាម គេត្រូវបញ្ជូនភស្តុតាងនោះទៅកាន់ប្រទេសកំណើត

ស្រដៀងៗគ្នានេះត្រូវបានអនុម័ត ដែលមានទិសដៅទៅលើការរកស៊ីដទៃៗទៀត និងក្រុមហ៊ុន ដូចជា អ្នកនាំភ្ញៀវទេសចរណ៍, រមណីយដ្ឋានទេសចរណ៍, ភោជនីយដ្ឋាន, ក្លឹបរាត្រី និងឌីស្កូថេក, ខារ៉ាអូខេ, សេវាកម្មម៉ាស្សា, សណ្ឋាគារ និងផ្ទះសំណាក់ជាដើម។ សារាចរក្រសួងទេសចរណ៍ស្តីពីការគ្រប់គ្រងភ្នាក់ងារទេសចរណ៍/ក្រុមហ៊ុនទេសចរណ៍, សណ្ឋាគារ និងផ្ទះសំណាក់លេខ១២ ស-រ-ណ-ន ហាមក្រុមហ៊ុនទាំងអស់នេះ គឺមិនអនុញ្ញាតអោយមនុស្សមានអាយុក្រោម ១៨ឆ្នាំ ចូលកន្លែងដែលរៀបរាប់ខាងលើទាំងអស់នេះទេ ប្រសិនបើគ្មានសមាជិកគ្រួសារទៅជាមួយ (មាត្រា ៧)។ ដំណាក់កាលបន្ទាប់ គឺមានការធានាអះអាងថា សេចក្តីបង្គាប់ទាំងនេះត្រូវបានអនុវត្តដោយម្ចាស់សណ្ឋាគារ និងផ្ទះសំណាក់។ សេចក្តីព្រាងច្បាប់ទេសចរណ៍របស់ប្រទេសកម្ពុជា បានបញ្ជាក់ពីបញ្ហានេះយ៉ាងលំអិតក្នុងមាត្រា ៤៤ និង ៤៥។ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាកិច្ចព្រមព្រៀងក្នុងតំបន់ និងអន្តរជាតិមួយចំនួនដែលជំរុញអោយមានការទទួលខុសត្រូវផ្នែកទេសចរណ៍ ហើយមានបំណងការពារកុមារក្នុងការធ្វើដំណើរ និងទេសចរណ៍។ រដ្ឋាភិបាល គឺជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន[៤០] ២០០២ ដែលត្រូវបានចុះហត្ថលេខាដោយប្រមុខរដ្ឋនៃប្រទេសសមាជិកអាស៊ានទាំង ១០។ ក្នុងមាត្រា ៥ (៦) ភាគីរដ្ឋទាំងអស់យល់ព្រមដាក់ចេញនូវវិធានការយ៉ាងម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់ការរំលោភ និងការកេងប្រវ័ញ្ចលើមនុស្សជាពិសេសស្ត្រី និងកុមារ ដែលពាក់ព័ន្ធវិស័យទេសចរណ៍។ ក្រមទេសចរណ៍អាស៊ាន ឆ្នាំ ២០០៥ ត្រូវបាន

[40] Association of Southeast Asian Nations



នៅក្នុងសេចក្តីព្រាងច្បាប់នេះ គឺស្រាលជាងមុន : (ជាប់ពន្ធនាគារពី ៥ ទៅ ១០ ឆ្នាំ ពីបទរួមភេទជាមួយកុមារក្រោមអាយុ ១៥ឆ្នាំ ហើយការប្រព្រឹត្តិអំពើទុច្ចរិតចំពោះកុមារអាយុក្រោម ១៥ឆ្នាំ (មាត្រា៤៤) ត្រូវជាប់ពន្ធនាគារពី ១ ទៅ ៣ ឆ្នាំ ហើយប្រហែលជាអាចមានបន្ថែមការផាកពិន័យទៀតផង) បើប្រៀបធៀបទៅនឹងច្បាប់ឆ្នាំ ១៩៩៦ ដែលកាត់ឱ្យជាប់ទោសពី ១០ ទៅ ២០ឆ្នាំ ប្រសិនបើបុគ្គលណាមួយត្រូវបានគេកាត់ទោសពីបទទុច្ចរិតនេះ។ ការរីកចំរើនដ៏សំខាន់ក្នុងសេចក្តីព្រាងច្បាប់នេះ គឺជាការរាប់បញ្ចូលទាំងគោលការណ៍ប្រព្រឹត្តិបទល្មើសក្រៅប្រទេស។ មានន័យថា ច្បាប់នេះនឹងអនុវត្តចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា ព្រមទាំងអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅបរទេសដោយប្រជាជនកម្ពុជាផងដែរ : មាត្រា ២ និង មាត្រា ៣។ ដូច្នេះ ជនជាតិខ្មែរ ដែលប្រព្រឹត្តបទល្មើសនៅក្រៅប្រទេសរបស់ខ្លួន នៅតែត្រូវទទួលទោសតាមច្បាប់ប្រទេសកម្ពុជា ។

សេចក្តីព្រាងច្បាប់របស់អង្គការ AFESIP បានចែងអំពីនិយមន័យជាច្រើន ដែលមានទាំងនិយមន័យនៃពាក្យកុមារ, រូបភាពអាសអាភាសលើកុមារ, កុមាររកស៊ីផ្លូវភេទ, ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ, ឧបាយកលបោកបញ្ឆោតធ្វើឱ្យមានសេចក្តីទុកចិត្ត, ការរកស៊ីធ្វើជាអ្នករកសេវាកម្មផ្លូវភេទដើម្បីផ្តល់ឱ្យអតិថិជន, ការលក់ដូរកុមារ, និងការជួញដូរមនុស្ស (គឺនៅក្នុងជំពូកដែលមានចែងអំពីនិយមន័យ)។ បទល្មើសទាំងអស់ក្នុងសេចក្តីព្រាងច្បាប់នេះត្រូវបានចាត់ទុកថា ជាបទល្មើសបត្យាប័នយោងទៅលើមាត្រា ៣។ មានផ្នែក/ជំពូកមួយ

បានថែងយ៉ាងជាក់លាក់អំពីជនរងគ្រោះ ដោយសារបទល្មើសរួមមានទាំង ខ ដែលនិយាយាពីការថែទាំក្រោយពីទទួលរងគ្រោះ, ការបញ្ជូនជនរងគ្រោះបរទេសទៅប្រទេសដើមវិញ, និងសេចក្តីត្រូវការអំពីការបង្កើនការយល់ដឹងអំពី វិធានការការពារ ដើម្បីជៀសវាងនៅភាពរងគ្រោះដែលកាន់តែធ្ងន់ធ្ងរ។ ផ្នែកទី៩ ចែងអំពីកាបង្កើតបញ្ជីឈ្មោះជនល្មើសផ្លូវភេទ។ ជនទាំងអស់ដែលត្រូវបានគេកាត់ឱ្យជាប់ទោសពីបទមនុស្សឃាត, ការរំលោភ, និងការរំលោភបំពាន ដូចដែលបានពិពណ៌នាលំអិតក្នុងសេចក្តីព្រៀងច្បាប់នេះនឹងត្រូវតែចុះក្នុងបញ្ជីអំពីរយៈពេលនៃការជាប់ទោសដែលសមនឹងទទួល ដែលសំរេចដោយចៅក្រមដែលសមល្មមទៅនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត (មាត្រា៤៧)។ ប្រសិនបើជនល្មើសបែបនេះវិលត្រឡប់មកប្រទេសកម្ពុជាវិញនោះ ការចូលមកក្នុងប្រទេសនេះនឹងត្រូវបានបដិសេធ ឬត្រូវតាមដានយ៉ាងយកចិត្តទុកដាក់ដើម្បីឱ្យបាននូវសុវត្ថិភាពរហូតដល់បុគ្គលនោះចាកចេញពីទឹកដី (មាត្រា៥១)។ ផ្នែកទី១០ បានថែងអំពីការរំលោភកុមារក្នុងវិស័យទេសចរណ៍។ រាជរដ្ឋាភិបាលត្រូវបានគេផ្តល់ឱ្យនូវអនុសាសន៏ ដើម្បីធ្វើការជាមួយនឹងឧស្សាហកម្មដែលពាក់ព័ន្ធក្នុងការអប់រំពួកគេអំពីនិន្នាការនៃទេសចរណ៍ផ្លូវភេទ និងព្រមានដល់សាធារណៈជនទូទៅថែមទាំងជនដែលមានកាទំនាក់ទំនងផ្ទាល់ជាមួយភ្ញៀវទេសចរឱ្យបានដឹងថា ការរួមភេទជាមួយកុមារគឺជាបទឧក្រិដ្ឋ (មាត្រា៥៤)។ មាត្រា៥៦ បានដាក់អាជ្ញាបញ្ជាឱ្យជនគ្រប់រូប ឬក្រុមហ៊ុនទេសចរណ៍ ដែលរៀបចំការធ្វើដំណើរក្នុងប្រទេសកម្ពុជាអនុវត្តតាម គឺត្រូវធ្វើយ៉ាងណាផ្សព្វផ្សាយយ៉ាងទូលំទូលាយគឺ នៅក្នុងខិត្តប័ណ្ណ



របស់ពួកគេត្រូវតែមានដាក់បញ្ចូលនូវច្បាប់ និងទោសបញ្ញត្តិចំពោះជនដែលប្រព្រឹត្តបទល្មើសនៅទីនេះ។ មាត្រា ៥៨ ហាមភ្ញៀវទេសចរដែលឱ្យកុមារមកជួបនៅក្នុងសណ្ឋាគារ ឬផ្ទះសំណាក់ដោយពុំមានវត្តមានឪពុកម្តាយរបស់កុមារ។ ប៉ុន្តែប្រសិនបើបញ្ហានេះកើតឡើងទាំងភ្ញៀវទេសចរ ទាំងសណ្ឋាគារនឹងទទួលរងនូវការពិន័យ ។

ប៉ុន្មានឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរផ្សេងៗ និងអនុក្រិត្យ ព្រមទាំងបានបង្កើតនូវគណៈកម្មាធិការមួយចំនួនដែលពាក់ព័ន្ធទៅនឹងការការពារកុមារក្នុងបរិបទទេសចរណ៍។ នាយករដ្ឋមន្ត្រីបានចេញក្រិត្យណែនាំមួយក្នុងឆ្នាំ ២00១ គោលបំណងនៃក្រិត្យនោះគឺ បិទខារ៉ាអូខេ និងក្លឹបរាត្រីដើម្បីការពារស្ត្រី និងកុមារដែលត្រូវបានគេជួលឱ្យធ្វើការក្នុងកន្លែងអស់ទាំងនេះ។ សេចក្តីបង្គាប់នេះទំនងជាមិនបានទទួលជោគជ័យដូចបំណងទេ។ ជាអកុសលពីព្រោះវាមិនត្រូវបានគេអនុវត្តតឹងរឹងនោះទេ។ ក្នុងចំណោមសារាចរដែលត្រូវបានអនុម័តសារាចរក្រសួងទេសចរណ៍ស្តីពីការគ្រប់គ្រងជំនួញភ្នាក់ងារទេសចរណ៍លេខ 0៣ ស-រ-ណ-ន ដែលបញ្ជាឱ្យភ្នាក់ងារទេសចរណ៍ត្រូវតែទទួលខុសត្រូវក្នុងការជំរាបជូនដំណឹងដល់បុគ្គលិក និងភ្ញៀវទេសចរអំពីច្បាប់ និងបទបញ្ជាផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការជួញដូរគ្រឿងញៀន និងការកេងប្រវ័ញ្ចផ្លូវភេទហាមកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងត្រូវតែរាយការណ៏ជាបន្ទាន់នូវហេតុការដែលបានកើតឡើងដែលធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ឬសន្តិសុខ[៣៩]។ សារាចរ

[39] Articles 5, 9 and 10.